01130048 E1/329.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Aug-2015, 15:16
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅជំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥**

**ម៉ោង ០៨:៥៩នាទី**

**សវនាការលើកទី៣១០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន *(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

លោក ម៉ាធូវ ម៉ាកាធី *(Mr. Matthew McCarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

លោក ត្រាវីស ហ្វារ *(Mr.Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោកស្រី ជេត វណ្ណលី

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិច ទ័រកូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ឡុត សួយ (2-TCW-889) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ឡុត សួយ** (2-TCW-889)


សួរបន្តដោយលោក ខេល លីសាក់ ផ្តើមពី ....................................ទំព័រ ៥

សួរដោយលោកស្រី ជេត វណ្ណលី ផ្តើមពី....................................ទំព័រ ១១

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ....................................ទំព័រ ២០

សួរដោយលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី..........................ទំព័រ ២៤

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ....................................ទំព័រ ៣២

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី....................................ទំព័រ ៦៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៩:១៦]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ឡូត សួយ បន្តបញ្ចប់ ហើយអាចនឹងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-937 ។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះគឺ លោក ឡូត សួយ លោកមានវត្តមានរួចហើយនៅបន្ទប់សវនាការនេះ ដោយមានមេធាវីប្រឹក្សាគឺលោក មឿង សុវណ្ណ។ នៅថ្ងៃនេះដែរ សាក្សីបម្រុងមួយរូប មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-937 សាក្សីបានបញ្ជាក់ថាតាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះនឹងធ្វើសម្បថចំពោះមុខលោកតាដំបងដែកនៅថ្ងៃនេះ មុនពេលមកផ្តល់សក្ខីកម្ម។ សាក្សីមានមេធាវីប្រឹក្សា គឺលោក មឿង សុវណ្ណ។

សូមអរគុណលោកប្រធាន។

[០៩:០១:៥៤]

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ នេះ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ បានកំណត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះខ្លាំង ធ្វើឲ្យពិបាកចលនា និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៣:៣៤]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

លោក ហ្សង់ -- លោកចៅក្រម ហ្សង់ម៉ាក តើលោកមានសំណួរ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន ដែលផ្តល់វេទិកានេះឲ្យខ្ញុំ។ ខ្ញុំមានសំណួរមួយទៅកាន់លោក ខេល លីសាក់។ កាលពីម្សិលមិញ នៅពេលដែលលោកសួរសំណួរ លោកបានយោងទៅលើឯកសារមួយ គឺ E3/1900 ដែលជាបញ្ជីអ្នកទោស ត្រូវបានកម្ទេចនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ៧៨។ អ្វីដែលខ្ញុំចង់ដឹងនោះ គឺ

ថាតើវាមានឯកសារដើមជាភាសាខ្មែរដែរឬទេ? នៅក្នុងហ្សាយឡេប គឺមិនមានជាភាសាដើមខ្មែរទេ។ អ៊ីចឹងខ្ញុំចង់ដឹងថាឯកសារហ្នឹងជាឯកសារមកពីមន្ទីរស-២១ ហើយជាឯកសារដែលផ្ដល់ជូនដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏យ៉ាងម៉េច? ជាឯកសារមកពីទួលស្លែង ឬក៏មិនមែន? ហើយចំណងជើងគឺថា ដាក់ថា "*ហ្វាយណល ដ្រាហ្វ*" ជាពង្រាងចុងក្រោយ។ អ៊ីចឹងលោកអាចបញ្ជាក់បន្ថែមបានទេ អំពីបញ្ហាឯកសារនេះ។ ខ្ញុំចង់បានប៉ុណ្ណឹង សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

[០៩:០៥:៤៣]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកចៅក្រម ឡាវែន៍។ ខ្ញុំកត់សម្គាល់ថា ហើយចាប់ផ្ដើមការសួរសំណួរអំពីបញ្ហានេះ ឯកសារយោងកន្លែងនេះ គឺថា ហើយគឺត្រូវបានធ្វើឡើងដោយអ្នកបកប្រែនៅតុលាការយូរហើយ ហើយគាត់បានបកប្រែមកពីឯកសារដើមមកពីទួលស្លែង។ បាទគឺ T203 ហើយយើងនឹងទៅរកមើលឯកសារខ្មែរដើមក្នុងពេលដែលយើងត្រៀមរៀបចំ ហើយយើងនឹងដាក់ជូនឯកសារនេះទៅតុលាការក្នុងដំណើរការនោះ ហើយខ្ញុំនឹងជម្រាបនៅពេលដែលយើងរកឃើញនូវឯកសារមកពី ស-២១ ទាក់ទងពីតាវ៉ាល់ ផងដែរ។ ថាតើ -- ហើយជាពិសេសទាក់ទងទៅនឹងឯកសារ ស-២១ ខែមិថុនា ឆ្នាំ១៩៧៧ ហើយនិងចម្លើយសារភាព ស-២១ របស់ តាវ៉ាល់ ដែរ។ ហើយយើងនឹងពិនិត្យមើលបញ្ហានេះ ទាក់ទងនឹងអ្វីដែលលោកចៅក្រមលើកឡើង ហើយយើងនឹងជម្រាបជូនតុលាការបន្ទាប់ពីយើងបានរកឃើញទាំងអស់នោះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី កូប៉េ!

**លោក រ៉ិចឆ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិង -- ហើយខ្ញុំក៏ត្រូវឆ្លើយទៅនឹងការជំទាស់ពីម្សិលមិញដែរ ទាក់ទងទៅនឹង ម៉ែន ឈឿន។ ហើយខ្ញុំបានផ្អែកទៅលើឯកសារមួយនៅពេលដែលខ្ញុំនិយាយដែរថា គាត់ចាប់ខ្លួននៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧ មានឯកសារ E3/2474។ ឯកសារជាភាសាអង់គ្លេស រៀបរាប់ពីថា ចំណារផ្ទាល់ដៃរបស់ ឌុច ហើយការឆ្លើយតបត្រូវបានរាយការណ៍ទៅ

គាត់នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ប៉ុន្តែទោះជាយ៉ាងណាក្ដី នៅក្នុង -- ផ្អែកលើមូលដ្ឋាននៅលើឯកសារនេះទេ គឺយើងទំនងថា មានការបកប្រែខុសមួយគឺថា កាលបរិច្ឆេទថ្ងៃទី០២ កុម្ភៈ ឆ្នាំ១៩៧៧ មិនមាននៅលើភាសាខ្មែរនោះទេ។ អ៊ីចឹងប្រហែលជាអត្ថបទភាសាបកទៅជាបារាំងមិនត្រឹមត្រូវ ដែលនិយាយទៅឆ្នាំ១៩៧៧ ប៉ុន្តែផ្អែកលើចម្លើយសារភាពខ្លួនឯងនេះ គឺយើងច្បាស់ហើយ តាមពិតគឺថា សហព្រះរាជអាជ្ញាពិតជាត្រូវដែលនិយាយអំពី ម៉ែន ឈឿន នោះគឺគេត្រូវចាប់ -- គាត់ត្រូវបានចាប់ខ្លួននៅខែមិថុនា ឆ្នាំ១៩៧៧។ ហើយនៅក្នុងឯកសារ E3/1993 ដែលជាឯកសារដែលបានដាក់ជូននៅក្នុងសាលាក្ដីបដិវត្តន៍កម្ពុជាឆ្នាំ១៩៧៩ គឺឯកសារ E3/1993 ហើយអង់គ្លេសគឺ 000664831 គឺថា ហើយខ្ញុំក៏ឯកភាពដែលថា ហើយគាត់នៅជាមួយ តាវ៉ាល់ ត្រូវបានគេចាប់ខ្លួននៅក្នុងខែមិថុនា ឆ្នាំ១៩៧៧។ ប៉ុន្តែក៏មិនមានអ្វី ការប្រែប្រួលទៅនឹងការជំទាស់របស់ខ្ញុំដែរ គឺថាការចាប់ខ្លួននៅភូមិភាគពាយ័ព្យនោះគឺថា បានចាប់ផ្ដើមនៅខែមិថុនា ឆ្នាំ១៩៧៧ រហូតដល់ខែឧសភាឆ្នាំ១៩៧៨ នៅពេលដែល រស់ ញឹម ត្រូវបានចាប់ខ្លួន ហើយ ជាល ជាអនុលេខានៅតំបន់៥ ត្រូវបានចាប់ខ្លួនដែរ។ ហើយសហព្រះរាជអាជ្ញាក៏ស្របគ្នាជាមួយខ្ញុំដែលនិយាយថា ការចាប់ខ្លួនហ្នឹងគឺចាប់ផ្ដើមពីខែមិថុនា ឆ្នាំ១៩៧៧ រហូតទៅដល់ខែឧសភា ១៩៧៨ នោះ។

[០៩:១០:០៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកមេធាវី កូប៉េ ប្រហែលជាមានបញ្ហាបកប្រែបន្តិច ម្សិលមិញក៏មានបញ្ហាអ៊ីចឹងដែរ។ លោកនិយាយអំពីការចាប់ខ្លួន ហ៊ូ នឹម ឬក៏ រស់ ញឹម? ព្រោះថា ហ៊ូ នឹម អត់មានទំនាក់ទំនងអ្វីជាមួយនឹងភូមិភាគពាយ័ព្យទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាការពិតអាចជាបញ្ហាបកប្រែ។ ខ្ញុំនិយាយថាការចាប់ខ្លួន រស់ ញឹម ទេ ប៉ុន្តែអាចនឹងការបកប្រែច្រឡំ។ ប៉ុន្តែគឺភាសាខ្មែរគឺ រស់ ញឹម គឺខ្ញុំយោងទៅ តាញឹម ដែលជាលេខាភូមិភាគ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណចំពោះការបញ្ជាក់នេះ។ អ៊ីចឹងប្រហែលជាពិនិត្យមើលប្រតិចារឹកកាលពីម្សិលមិញ

ព្រោះថាពីម្សិលមិញ ក៏យើងឮនិយាយអំពីការចាប់ខ្លួន ហ៊ូ នឹម ដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមប្រគល់វេទិកាដល់តំណាងសហព្រះរាជអាជ្ញា ក្នុងការតាំងសំណួរទៅសាក្សីរូបនេះបន្តទៀត។ សូមអញ្ជើញ!

[០៩:១១:២៨]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកសាក្សី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំនឹងព្យាយាមបញ្ចប់ការសួរសំណួរទៅលោកព្រឹកនេះ ឲ្យបានឆាប់រហ័សមុននឹងជូនវេទិកាទៅដើមបណ្ដឹងរដ្ឋប្បវេណី។ លោកបាននិយាយអំពីការមកដល់នៃកម្មាភិបាលនិរតីមកដល់តំបន់របស់លោក ហើយសុំឲ្យលោករៀបរាប់ជាទូទៅជូនតុលាការ ថាតើនៅក្នុងតំបន់ដែលលោករស់នៅកាលនោះ តើវាមានការផ្លាស់ប្ដូរអ្វីខ្លះ? ជីវភាពរស់នៅ លក្ខខណ្ឌរស់នៅ ហើយនិងការផ្លាស់ប្ដូរអ្វីផ្សេងៗទៀត របបអាហារជាដើម តើវាមានការកែប្រែអ្វីខ្លះ បន្ទាប់ពីការមកដល់នៃកម្មាភិបាលខាងនិរតី?

**លោក ឡុត ស្វយ៖**

**ឆ៖** អត់ឮៗគាត់សួរ។

**ស៖** ខ្ញុំនឹងសួរលោកឡើងវិញ។ សំណួរខ្ញុំៗសួរថា សុំឲ្យលោកជម្រាបមកខ្ញុំ និងតុលាការអំពីសេចក្ដីរៀបរាប់អំពីថា តើមានការកែប្រែអ្វីខ្លះនៅក្នុងតំបន់ ឬក៏ក្នុងកន្លែងដែលលោកធ្វើការបន្ទាប់ពីកម្មាភិបាលនិរតីមកដល់? តើមានការកែប្រែអ្វីទេ ជីវិតរស់នៅ ការចាប់ខ្លួន ...។ល។

**ឆ៖** ខ្ញុំស្ដាប់អត់បានផង។ សូមលោកសាលាក្ដី សូមនិយាយសាមើល។

**ស៖** បាទ សូមអរគុណ។ សំណួរ សុំលោកជម្រាបតុលាការនូវសេចក្ដីអត្ថាធិប្បាយរៀបរាប់អំពីការកែប្រែនៅក្នុងតំបន់របស់លោក នៅក្នុងតំបន់៥ បន្ទាប់ពីកម្មាភិបាលនិរតីមកដល់។ យើងនិយាយអំពីជីវភាពរស់នៅ ចំនួននៃការចាប់ខ្លួន មនុស្សបាត់ខ្លួន។ គ្រាន់តែឲ្យលោកពណ៌នាដោយសង្ខេបអំពីបញ្ហាដែលខ្ញុំលើកឡើងខាងដើមនេះជូនតុលាការ។

[០៩:១៤:០១]

**ឆ៖** បាទ ខ្ញុំសូមគោរពលោកតុលាការ។ ពេលរយៈកាលដែលពួកនិរតីចូលមកដល់នេះ គេក៏បានចាប់ខ្លួនពួកពាយ័ព្យ គេចោទថាពួកភូមិភាគពាយ័ព្យនេះក្បត់ ហើយបានគេឲ្យហូបក្នុងមួយ កំប៉ុងនេះគ្នា១០០នាក់។ ម្ល៉ោះហើយប្រជាជនមានរស់នៅក្នុងតំបន់៥នេះ ក៏រើបម្រាស។ អ្នកខ្លះក៏គ្នាស្គមស្គាំងក្បាលជង្គង់ដើរមិនរួច ហើម ដោយសារគេៗបង្អត់បាយ។ ហើយធ្វើការចាប់ពីម៉ោងប្រាំល្ងាច ទល់ម៉ោងដប់មួយយប់ ចាប់ពីម៉ោងប្រាំមួយព្រឹក ទល់ដប់មួយថ្ងៃ។

**ស៖** សូមអរគុណលោកសាក្សី។ ហើយខ្ញុំនឹងសួរសំណួរដែលលោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា E3/9060 ERN ខ្មែរ 00733035 ហើយនិង 036, អង់គ្លេស 0078734 *(ស៊ីក)*, បារាំង ERN 01123688 ដែលលោកនិយាយអំពីវត្តមានរបស់កម្មាភិបាលថ្មីៗដែលមកដល់។ មានពីរក្រុម មួយក្រុមមកពីនិរតី មួយក្រុមមកទៀតមកពីកំពង់ឆ្នាំង ហើយនិងខេត្តពោធិ៍សាត់។ ពួកដែលមកពីនិរតីកាចៗណាស់ អ្នកដែលមកពីកំពង់ឆ្នាំងមិនកាចទេ អ្នកទាំងអស់នោះជាស្ត្រី ប៉ុន្តែហើយអ្នកដែលក្រុមមួយផ្សេងទៀតគឺថាមានភាពកាចណាស់។ ហេតុអ្វីបានជាលោកនិយាយថា កម្មាភិបាលនិរតីសុទ្ធតែពួកកាចបែបនោះ? មូលហេតុអីដែលលោកអាចបញ្ជាក់បានបែបនោះ?

**ឆ៖** បានខ្ញុំថា ពួកនិរតីដែលថាកាចនេះ ព្រោះវានារី ហើយវាឡើងគណៈឃុំ ហើយនិរតីសុទ្ធតែទ័ព។ បានពាយ័ព្យយើងខុស គេចាប់វៃចោល ខុសចាប់វៃចោល។ បើពួកកំពង់ឆ្នាំងនេះ គេជាប្រធានសហករណ៍ ចេះស្រណោះប្រជាជនខ្លះ។ ប្រជាជនដែលអត់បាយអត់ទឹកទៅលួចដំឡូងលួចត្រាវគេហូបទៅ ជួនកាលគេឃើញគេអត់សួរធ្វើបាប។ បានខ្ញុំមើលទៅថាកំពង់ឆ្នាំងនេះចិត្តល្អ ពីព្រោះជីវភាពរបស់ខ្ញុំនេះ បានគេដកចេញមកនៅក្នុងភូមិកររបស់ខ្ញុំវិញ។

[០៩:១៧:១០]

**ស៖** និយាយអំពីប្រធានបទអំពីការបោសសម្អាត ខ្ញុំចង់សួរលោកអំពីអ្វីដែលលោកបាននិយាយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ អូ.ស៊ី.អាយ.ជេ. គឺ E319/19.3.20 នៅចម្លើយ៩០។ សំណួរគេសួរថា៖ "តើលោកដឹងពីមូលហេតុដែលថា កម្មាភិបាលនិរតីចាប់កម្មាភិបាលពាយ័ព្យ ហើយនិងជំនួសពួកកម្មាភិបាលនោះទេ? ចម្លើយឆ្លើយ៖ ខ្ញុំមិនដឹងមូលហេតុទេ។ ខ្ញុំដឹងថាកម្មាភិបាលពាយ័ព្យត្រូវបានពួកនិរតីមកជំនួស។ តាញឹម ប្រាប់យើងអំពីបញ្ហានេះ។" ចប់សេចក្តីដកស្រង់។ ខ្ញុំចង់សួរលោកអំពីចំណុចនេះ ថាតើនៅកន្លែងណា ហើយនៅពេលណាដែលលោកបានឮ តាញឹម និយាយពីការចាប់ខ្លួនពួកពាយ័ព្យ ហើយពួកនិរតីមកជំនួសអ្នកទាំងនោះនោះ?

**ឆ៖** ពេលរយៈកាលដែលពួកនិរតីគេចូលមកដល់ តាញ៉ឹម គាត់ជាប្រធានភូមិភាគនេះ គាត់បាន ហៅតាមមេៗទៅប្រជុំ។ បានគាត់ប្រាប់ថា គេចោទថាភូមិភាគយើងនេះក្បត់។ បានឲ្យពួកអ្នកក្រោម នេះគេប្រុងប្រយ័ត្ន ខ្លាចនិរតីចាប់។ រយៈកាលមិនបានប៉ុន្មានថ្ងៃផង គេចាប់ តាញ៉ឹម នោះបាត់ទៅ។ បាន ពួកខ្ញុំអ្នកនៅក្រោមនេះគឺថា មានតែពួកនិរតីដែលចាប់។

**ស៖** តើលោកខ្លួនឯងបានវត្តមាននៅក្នុងការប្រជុំដែល តាញ៉ឹម ប្រកាសប្រាប់ប្រជាជនអំពី បញ្ហាដែលលោកនិយាយអំមិញហ្នឹងទេ?

**ឆ៖** ខ្ញុំអត់បានប្រជុំទេ គ្រាន់តែមេខ្ញុំ គេមក គេប្រាប់កូនចៅឲ្យដឹងថា ភូមិភាគនិរតីនេះ គេបាន មកក្តោបក្តាប់នៅតំបន់៥យើងហើយ ហើយគេចាប់ តាញ៉ឹម ទៅបាត់ហើយ។

[០៩:១៩:៥៤]

**ស៖** ខ្ញុំនឹងសួរលោកសំណួរមួយចំនួន អំពីអ្វីដែលនៅក្នុងបទសម្ភាសន៍របស់លោកដែលមេធាវី ការពារក្តីនឹងសួរសំណួរជាច្រើនអំពីបញ្ហានេះ។ ខ្ញុំមិនមានឱកាសនឹងសួរលោកនៅពេលនោះទេ ហើយខ្ញុំ សួរបញ្ហាមួយចំនួនទាក់ទងនឹងបញ្ហានេះ។ លោកបាននិយាយអំពីបញ្ហានេះនៅពេលមួយដែលលោកបាន រត់ទៅចូលព្រៃ ហើយលោកបាននិយាយអំពីៗថាអាចនឹងដឹកជញ្ជូនអាវុធចូលទៅក្នុងព្រៃ។ សំណួរខ្ញុំ ដែលខ្ញុំចង់សួរ ហើយឯកសារយោងហ្នឹង ខ្ញុំនឹងប្រាប់គឺបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាគឺ ឯកសារ E3/9060, ខ្មែរ ERN 00733053 ដល់ 054, អង់គ្លេស ERN 00728747 ដល់ 48, បារាំង ERN 01123699។ ដកស្រង់៖ “តាណាក បានរៀបចំកិច្ចប្រជុំជាមួយគណៈស្រុក ហើយនិង មេបញ្ជាការ ហើយគាត់បានប្រាប់កងទ័ព ហើយនិងប្រាប់ពួកគេថា ភូមិភាគពាយ័ព្យ ដើម្បីរៀបចំត្រៀម ខ្លួនដើម្បីដឹកអាវុធចូលទៅក្នុងព្រៃ ហើយនៅពេលដែលមានការហៅ យើងត្រូវត្រឡប់មក ហើយពួកគេ ត្រូវបានគេចាប់ខ្លួនយ៉ាងងាយនៅក្នុងផ្ទះ។” តើពួកគេបានពាក់ព័ន្ធនៅក្នុងដឹកអាវុធចូលទៅក្នុងព្រៃដែរ ឬទេ ពួកអ្នកទាំងនោះ?

**ឆ៖** បាទ ពួកកងទ័ពតំបន់ដែលជាគេដឹង ហើយគេក៏បានដឹកជញ្ជូនគ្រឿងអាវុធចូលទៅក្នុង ព្រៃកូនខ្លែង។ ពួកខ្ញុំក៏នៅនឹងអាង នៅលើខ្នងអាង ក៏បានពួកគេនៅៗនឹងព្រៃឈូកអាងហ្នឹងឯង។ ក៏បាន នៅពេលរយៈកាលបានប្រហែល១០ថ្ងៃ ក៏គេក៏ចូលទៅកន្លែងស្វាយវិញ។ ពេលនោះក៏និរតីក៏គេចាប់ពួក នោះដោយស្រួល។ គេហៅទៅប្រជុំ ហៅម្តងមួយៗ គេចាប់ម្តងមួយៗ។

**ស៖** អ្វីដែលខ្ញុំចង់សួរលោក លោកសាក្សីគឺលោកដឹងថាតើសកម្មភាពហ្នឹងជាផ្នែកនៃផែនការ

សម្ងាត់របស់ រស់ ញឹម នៅក្នុងការបះបោរប្រឆាំង ប៉ុល ពត ឬក៏គ្រាន់តែជាកិច្ចប្រឹងប្រែងរបស់កងទ័ពតំបន់ដើម្បីការងារខ្លួនទល់នឹងអ្នកដែលមកចាប់ ហើយនិងសម្លាប់ពួកគេ?

[០៩:២៣:០១]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនមានអត្ថបទទេ ហើយខ្ញុំមិនដឹងថាជាសំណួរនាំមុខឬទេ ប៉ុន្តែហេតុអីក៏សហព្រះរាជអាជ្ញាគឺសួរសំណួរបើក ថាហេតុអីបានជាគេយកអាវុធទៅតម្កល់អ៊ីចឹង? គឺថាបើសហព្រះរាជអាជ្ញាសួរបែបនេះ ហាក់ដូចជាផ្តល់ព័ត៌មានទៅសាក្សីដើម្បីឲ្យឆ្លើយ គឺថាខ្ញុំសូមជំទាស់សំណួរបែបនេះ។

**លោក ឌេល លីសាក់៖**

គឺថាមិនមែនជាសំណួរនាំមុខទេ គឺខ្ញុំផ្តល់ជម្រើសទៅដល់សាក្សី ដូចដែលលោក កូប៉េ ធ្វើដែរ គឺថាលោកសួរថា តើមានការបះបោរដែរឬក៏អត់ទេនោះ? ដូច្នេះហើយលោក កូប៉េ មិនដែលសួរសាក្សីបែបនោះទេ គឺគាត់តែងតែសួរដែលផ្អែកទៅលើព័ត៌មានដំបូង។ ហើយអ៊ីចឹងក៏ខ្ញុំសួរថាតើមានជាផែនការដើម្បីការពារខ្លួនគេ ឬក៏យ៉ាងដូចម្តេចនៅកាលនោះ?

[០៩:២៤:១៣]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៤:៣៥]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាអាចបន្តសំណួរបន្តទៀត ដោយសារសំណួរនេះជាសំណួរចំហទេ។

សូមអញ្ជើញ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើលោកចាំសំណួរខ្ញុំទេ លោកសាក្សី? ខ្ញុំសួរលោកថា តើលោកដឹងអំពីការប្រឹងប្រែងដើម្បីដឹកជញ្ជូនអាវុធទៅក្នុងព្រៃ? តើជាផែនការដើម្បីប្រឆាំង ប៉ុល ពត ឬក៏ជាផែនការ ឬក៏កិច្ចប្រឹងប្រែងដើម្បីការពារខ្លួនពួកគេ ទល់នឹងអ្នកដែលមកចាប់គេ ហើយនិងសម្លាប់ពួកគេនោះ?

**លោក ឡុត សួយ៖**

**ឆ៖** ពេលនោះខ្ញុំឮពួកកងទ័ពតំបន់ គេនិយាយថា ផែនការដែលគេដឹកចូលក្នុងព្រៃនេះ គឺគេ គឺផែនការរបស់គេដើម្បីទប់ទល់ជាមួយភូមិភាគនិរតី ដើម្បីកុំឱ្យមកនៅនឹងទឹកដីតំបន់៥។

**ស៖** បញ្ហាបន្ទាប់ដែលខ្ញុំចង់សួរលោក គឺថានៅក្នុងបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា លោកបាននិយាយអំពី បានឃើញក្រដាសប្រាក់ដែលគេបោះពុម្ព។ ខ្ញុំចង់សួរលោកថាតើលោកបានស្គាល់អំពីក្រដាសប្រាក់ដែលមេដឹកនាំបក្សបានបោះពុម្ពនៅភ្នំពេញដែរឬទេ មុនពេលដែលគេសម្រេចថាតើចាយ ឬមិនចាយនោះ? តើលោកអាចជម្រាបតុលាការបានដែរឬទេ ថាតើក្រដាសប្រាក់នោះគឺជាក្រដាសប្រាក់ដែលបានបោះពុម្ពនៅក្នុងទីក្រុងភ្នំពេញ ឬក៏បានបោះពុម្ពនៅក្នុងភូមិភាគពាយ័ព្យ?

**ឆ៖** បាទ ក្រដាសប្រាក់នោះ គឺបោះនៅក្នុងទីក្រុងភ្នំពេញ គឺក្រដាសប្រាក់នោះខ្ញុំ ឃើញក្រដាសប្រាក់នោះសម្បុររាងក្រហម ហើយប្រជាជនយើងច្រូតស្រូវ ហើយនិងលីចប។

[០៩:២៧:០៥]

**ស៖** សូមអរគុណលោកសាក្សី ខ្ញុំមានសំណួរពីរបីទៀត។ នៅក្នុងបទសម្ភាសន៍ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបាននិយាយអំពីអង្គភាពរបស់លោករាយការណ៍ទៅ តាណាក ជាពិសេសនៅការដ្ឋានត្រពាំងថ្ម អំពីថា តាណាក គាត់រាយការណ៍ជារបាយការណ៍លាយលក្ខណ៍អក្សរទៅ តាវ៉ាល់។ ហើយខ្ញុំសួរៗថា ថាតើលោកដឹងដោយរបៀបណាថា តាណាក គាត់ធ្វើរាយការណ៍ជាលាយលក្ខណ៍អក្សរទៅ តាវ៉ាល់ នោះ?

**ឆ៖** ពេលនោះគឺ តាណាក គាត់ទៅប្រជុំជាមួយនឹងលោក តាវ៉ាល់។ គាត់ធ្វើការនៅក្នុងកងចល័តយើងអាងត្រពាំងថ្មនេះ។

**ស៖** ហើយលោកបានបញ្ជាក់ផងដែរនៅក្នុងឯកសារE3/9060 ហើយឯកសារខ្មែរ 0073382 អង់គ្លេស 0072707 ហើយបារាំង 001123682។ "សំណួរ៖ ថាតើរបាយការណ៍នោះបញ្ជូនទៅណាអំពីការបាត់ខ្លួន? ចម្លើយ៖ តាណាក។ សំណួរ៖ តាណាក? ចម្លើយ៖ បាទ តាណាក សរសេរសំបុត្រទៅ តាវ៉ាល់។" ហើយខ្ញុំសួរឲ្យលោកបំភ្លឺនៅពេលនេះ គឺថាតើ តាណាក បញ្ជូនរបាយការណ៍លាយលក្ខណ៍អក្សរទៅ តាវ៉ាល់ ដែរឬទេ? ប្រសិនបើរបាយការណ៍ហ្នឹងបែបហ្នឹង តើលោកដឹងដោយរបៀបណា?

**ឆ៖** ពេលដែលគាត់សរសេរលាយលក្ខណ៍អក្សរបាន ក្រដាសនោះគាត់ឲ្យនីរសារគាត់រត់យក

ទៅឲ្យ តាវ៉ាល់ គឺផែនការគាត់និយាយអំពីតែរឿងការពារអាងត្រពាំងថ្មកុំឲ្យបាក់។

[០៩:២៩:៤១]

**ស៖** សូមអរគុណ។ ឥឡូវនេះសំណួរចុងក្រោយរបស់ខ្ញុំលោកសាក្សី។ នៅចុងបញ្ចប់នៃបទសម្ភាសន៍ឯកសារកម្ពុជានោះ លោកនិយាយថា បន្ទាប់ពីរបបខ្មែរក្រហមបានចប់ទៅ លោកបានត្រឡប់តែម្ដងទៅត្រពាំងថ្ម ដែលប្រហែលជា២០ឆ្នាំហើយ។ នៅពេលដែលលោកទៅដល់ទីនោះ លោកនិយាយថា សូមដកស្រង់ លោកនិយាយថា “លោកសោកស្ដាយ ឬក៏មានទុក្ខព្រួយ”។ ហេតុអ្វីក៏នៅពេលដែលត្រឡប់ទៅទំនប់ត្រពាំងថ្ម លោកមានទុក្ខព្រួយកាលនោះ ហេតុអ្វី?

**ឆ៖** ពេលដែលខ្ញុំត្រឡប់ទៅអាងត្រពាំងថ្មវិញ គឺខ្ញុំមានទុក្ខព្រួយ ដោយសារដែលគេប្រើទាំងយប់ទាំងថ្ងៃ ហើយឲ្យហូបក្នុងកន្លះកំប៉ុងក្នុងមួយថ្ងៃនេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកសាក្សី ដែលលោកបានឆ្លើយសំណួរខ្ញុំ ហើយលោកប្រធាន ខ្ញុំបានបញ្ចប់ផ្នែករបស់ខ្ញុំហើយបាទ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណតំណាងសហព្រះរាជអាជ្ញា។ ជាបន្តសូមប្រគល់វេទិកាដល់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការតាំងសំណួរទៅសាក្សី។ សូមអញ្ជើញ!

[០៩:៣១:១៦]

**លោក ពេជ អង្គ៖**

បាទសូមគោរពលោកប្រធាន មេធាវីនាំមុខសូមផ្ទេរសិទ្ធិនៅក្នុងការសួរសាក្សីរូបនេះជូនលោកស្រីមេធាវី ជេត វណ្ណលី ហើយជាបន្តពីនោះគឺលោកស្រីមេធាវីអន្តរជាតិ ម៉ារី ហ្គីរ៉ូដ៍ នឹងបន្តសំណួរបន្ទាប់ពីលោកស្រី ជេត វណ្ណលី។ សូមអរគុណលោកប្រធាន សូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីមេធាវីមានសំណួរដល់សាក្សី!

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន។ សូមគោរពលោកចៅក្រមនិងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ជម្រាបសួរលោកសាក្សី! ខ្ញុំឈ្មោះ ជេត វណ្ណលី មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ ម្សិលមិញលោកបានឆ្លើយ និងបញ្ជាក់នូវចំណុចមួយចំនួនជូនតុលាការ តាមសំណួររបស់លោកសហព្រះរាជអាជ្ញា។ នៅថ្ងៃនេះ ខ្ញុំក៏ចង់ឲ្យលោកបញ្ជាក់នូវចំណុចមួយចំនួនបន្ថែមទៀត ដើម្បីជាពន្លឺដល់អង្គជំនុំជម្រះ។ ម្សិលមិញលោកបានបញ្ជាក់ថា លោកត្រូវគេចាត់តាំងឲ្យទៅនៅទំនប់ត្រពាំងថ្ម។ ខ្ញុំចង់ឲ្យលោកបញ្ជាក់បន្ថែមទៀត និងឲ្យបានជាក់លាក់ថា តើលោកទៅទំនប់ត្រពាំងថ្មហ្នឹងប៉ុន្មានដង?

[០៩:៣២:៤៥]

**លោក ឡុត សួយ៖**

**ឆ៖** ខ្ញុំទៅទំនប់ត្រពាំងថ្មនេះពីរដង។ រយៈកាលមុនដែលខ្ញុំនៅទ័ពគេដកឲ្យយាម ដល់ដែលពេលដែលរើស -- រយៈកាលដែលខ្ញុំនៅជាប្រជាជននេះ ខ្ញុំនៅតែអាងត្រពាំងថ្ម គេប្រើឲ្យពួកខ្ញុំនេះសែងអាចម៍ធ្វើដី។ បានគេដកពិសោធមើលដែលពួកខ្ញុំ ដែលនៅចេញពីទ័ពនេះទៅធ្វើបាន ឬមិនបាន។

**ស៖** អរគុណលោកសាក្សី។ នៅក្នុង -- លោកបានបញ្ជាក់ដែរថា លោកទៅទំនប់ត្រពាំងថ្មហ្នឹងពីរដង។ ប៉ុន្តែលោក -- ខ្ញុំសូមឲ្យលោកបញ្ជាក់លម្អិត តើលើកទី១ និងលើកទី២ ហ្នឹងលោកទៅនៅពេលណា? នៅកន្លែងណា? ហើយគេឲ្យធ្វើអី សូមលោកបញ្ជាក់ឲ្យបានច្បាស់លាស់ជាងនេះបន្តិចបានទេ?

**ឆ៖** នៅឆ្នាំ៧៦នេះដែលខ្ញុំនៅទ័ពនេះ គេក៏បានដកខ្ញុំទៅនៅនឹងការពារអាងត្រពាំងថ្ម។ ការពារទឹកកុំឲ្យបាក់ ការពារទំនប់កុំឲ្យបាក់។ ដល់រយៈកាលកន្លងមកដែលភូមិភាគនិរតីចូលដល់នេះ ពួកកងទ័ពនិរតីនេះ គេក៏បានរំសាយពួកខ្ញុំជាពាយ័ព្យនេះថា ពួកភូមិភាគពាយ័ព្យក្បត់ គេក៏ដកពួកខ្ញុំនេះឲ្យទៅនៅក្នុងកងចល័ត។ គេក៏ចែកមុខការងារឲ្យពួកខ្ញុំនេះ ដើរសែងអាចម៍តាមកងចល័តដែលយើងដុះតាមបង្គន់នោះ។

**ស៖** អរគុណលោកសាក្សី។ ម្សិលមិញលោកបានបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះ ក៏ដូចជានៅចំពោះមុខសហព្រះរាជអាជ្ញាថា លោកមានការដូរផ្លាស់កន្លែងធ្វើការញឹកញាប់។ គេចាត់តាំងលោកបន្តិចទៅនេះបន្តិចទៅនោះ។ ហេតុអីក៏មានការផ្លាស់ប្ដូរញឹកញាប់បែបនេះចំពោះរូបលោក?

[០៩:៣៤:៥៥]

**ឆ៖** គឺអត់មានការផ្លាស់ប្ដូរតែរូបខ្ញុំម្នាក់ទេ គឺចង្កោមផងខ្ញុំទាំង៩០នាក់នេះ គឺគេដកបំបែកគ្នា

ផ្លាស់គ្រប់គ្នា។ ខ្លះទៅខាងភ្ជួរស្រែ ខ្លះទៅខាងសែងដី សែងអាចម៍ដែលកងចល័តយើងជុះតាមកងៗនោះ។ ខ្លះទៅដើររើសអាចម៍គោ។

**ស៖** អរគុណលោកសាក្សី។ ខ្ញុំនៅតែមានសំណួរមួយចំនួនទៀត នៅជុំវិញបញ្ហាទំនប់ត្រពាំងថ្មនេះដដែល។ ខ្ញុំចង់ដឹងថា តើលោកអាចបញ្ជាក់ប្រាប់តុលាការបានទេថា តើទំនប់ហ្នឹងចាប់ផ្ដើមតាំងពីពេលណាមក? នៅឆ្នាំណា សាងសង់ហ្នឹង?

**ឆ៖** ទំនប់នោះកសាងនៅដើមឆ្នាំ៧៦។ បានគេវាស់ពីភូមិពន្លៃនេះ មកទល់នឹងភូមិត្រពាំងថ្ម។

**ស៖** តើលោកមានដឹងទេ គេកសាងទំនប់ហ្នឹងដើម្បីអីទៅ មានប្រយោជន៍អីដែរចំពោះប្រជាជន?

**ឆ៖** គេកសាងទំនប់នោះ ដើម្បីទុកធ្វើជាអាងទឹកមួយសម្រាប់ឲ្យប្រជាពលរដ្ឋយើងធ្វើស្រែប្រាំង។ គេទុកជាមេៗទឹកធំ។

**ស៖** អរគុណលោក។ តើទំនប់នេះ បានចប់សព្វគ្រប់នៅឆ្នាំណា លោកដឹងទេ?

**ឆ៖** ពេលនោះ ខ្ញុំដឹងអត់ដល់ដែរ ព្រោះខ្ញុំគេដកមកនៅតាមភូមិវិញ។ ខ្ញុំក៏វិលត្រឡប់ពីទំនប់រន្ទះបាញ់នេះមកនៅ -- អ៎! ទំនប់អាងត្រពាំងថ្មនេះ ក៏ខ្ញុំវិលត្រឡប់មកនៅស្រុកកំណើតរបស់ខ្ញុំវិញ។

**ស៖** ក្រោយពីការដ្ឋានទំនប់ត្រពាំងថ្មបានបញ្ចប់ទៅ តើលោកមានដឹងទេថា មានការសម្ពោធអីទេ ពេលដែលបញ្ចប់ហ្នឹង មានសម្ពោធទំនប់ហ្នឹងទេ?

**ឆ៖** ពេលដែលចប់ទំនប់អាងត្រពាំងថ្មនេះ គឺគេអត់បានសម្ពោធទេ គឺគេដកកងចល័តទៅលើកនៅទំនប់ស្ពានស្រែង។ សូម្បីតែស្ពានទី១ ទី២ ទី៣នោះ ក៏ធ្វើអត់ទាន់រួចដែរ។

[០៩:៣៧:៥៥]

**ស៖** អរគុណលោកសាក្សី។ ម្សិលមិញ លោកបានបញ្ជាក់ថា នៅចំពោះមុខព្រះរាជអាជ្ញាថា មានការចាប់ខ្លួនកម្មាភិបាលពាយ័ព្យ ដូចជា តាវ៉ាល់, តាហ៊ីង្ស, តាម៉ោង, តាហាត់។ នៅពេលដែលគេចាប់កម្មាភិបាលពាយ័ព្យទាំងនេះ តើទំនប់ត្រពាំងថ្មហ្នឹង គេធ្វើហើយឬនៅ លោក?

**ឆ៖** ពេលដែលគេចាប់ពួក តាហាត់, តាម៉ោង នោះ ទំនប់ត្រពាំងថ្មរួចអស់ហើយ នៅសល់តែស្ពាន។

**ស៖** តើអ្នកណាដែលជាគ្រប់គ្រងបន្ត ពេលដែលគេចាប់ តាវ៉ាល់ ទៅ?

**ឆ៖** ពេលដែលចាប់ពួក តាវ៉ាល់ ទៅគឺអ្នកគ្រប់គ្រងបន្ត អានោះ ខ្ញុំដឹងអត់ដែលដែរ គឺឃើញតែតាមវរៈរបស់គេលើក។ គេលើកទំនប់តែជារៀងរាល់ថ្ងៃ។

**ស៖** តើអ្នកណាដែលបន្តការគ្រប់គ្រងជំនួស តាវ៉ាល់ លោកមានដឹងទេ?

**ឆ៖** ការគ្រប់គ្រងជំនួស តាវ៉ាល់ នេះ គឺខ្ញុំអត់បានដឹងទេ។

**ស៖** អរគុណលោក។ ម្សិលមិញ លោកបានបញ្ជាក់ថា តាវ៉ាល់ និងកម្មាភិបាលមួយចំនួនត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់។ ខ្ញុំចង់ដឹងថា តើលោកមានបានដឹងទេ តើគ្រួសាររបស់ តាវ៉ាល់ និងក្រុមគ្រួសាររបស់កម្មាភិបាលទាំងនោះ ត្រូវចាប់ខ្លួនដែរទេ?

**ឆ៖** ការចាប់ខ្លួនរបស់ តាវ៉ាល់ រយៈកាលកន្លងមក ប្រហែលជាបួនដប់ថ្ងៃនេះ គេក៏ចាប់ប្រពន្ធកូនមក១ដែរ។

**ស៖** អរគុណលោក។ ចុះដែលកម្មាភិបាលផ្សេងទៀតដូច តាម៉ោង, តាហាត់, តាហ៊ីង្ស អីហ្នឹង តើប្រពន្ធកូនត្រូវគេចាប់បន្តទៀតទេ?

**ឆ៖** ប្រពន្ធ តាម៉ោង ក៏គេចាប់។ ខ្ញុំឃើញតែពីរនាក់ ប៉ុន្តែប្រពន្ធ តាហាត់ ខ្ញុំអត់បានដឹងដល់ទេ។

[០៩:៥០:២៧]

**ស៖** លោកអាចបញ្ជាក់បានទេថា ហេតុអីបានគេចាប់ប្រពន្ធកូនគាត់?

**ឆ៖** ព្រោះខ្ញុំដឹងថា ប្រពន្ធកូនរបស់ តាវ៉ាល់ និង តាហាត់ នេះគឺគេអ្នកធ្វើការ។ មិនដឹងថាគេភារកិច្ចគេខាងអីទេ ប៉ុន្តែដឹងថាគេធ្វើការធំ។

**ស៖** អរគុណលោកសាក្សី។ លោកបានបញ្ជាក់ថា លោកនៅទំនប់ត្រពាំងថ្មហ្នឹងពីរដង។ នៅពេលដែលលោកយាមនៅទំនប់ត្រពាំងថ្មហ្នឹង តើលោកដែលឃើញអ្នកដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ដូចលោក ខៀវ សំផន, នួន ជា, ប៉ុល ពត ទៅធ្វើទស្សនកិច្ចនៅទំនប់ត្រពាំងថ្មទេ?

**ឆ៖** រយៈកាលកន្លងដែលលើកទំនប់ត្រពាំងថ្មនេះ គឺគេប្រាប់ថា អង្គការមកមើលទំនប់ ប៉ុន្តែគេឲ្យពួកអ្នកយាមនោះ អត់ឲ្យមើលមុខអង្គការទេ គឺឲ្យបែរខ្នងដាក់អង្គការ យាម។ រយៈកាលកន្លងមកខ្ញុំក៏មិនដឹងថា អង្គការនោះអ្នកណាទេ។ ខ្ញុំឃើញតែពាក់ – ខ្ញុំលួចមើលកន្ទុយភ្នែកឃើញតែពាក់តែអាវសដៃខ្លី។ ប៉ុន្តែគេថា “អង្គការ១” មិនដឹងថា អង្គការណាទេ ព្រោះគេមិនបានឲ្យឈរបែរមុខចំ គេឲ្យបែរខ្នងដាក់។

**ស៖** តើពាក្យដែលលោកថា “អង្គការ” ហ្នឹងសំដៅអ្នកដឹកនាំជាន់ខ្ពស់ ឬក៏សំដៅអ្នកណាលោក? លោកអាចបញ្ជាក់បានទេ?

[០៩:៤២:១៨]

**ឆ៖** ព្រោះអង្គការៗនេះ គឺជាអង្គការជាន់ខ្ពស់ គឺអង្គការដែលគេចេញច្បាប់មកឱ្យប្រជាពលរដ្ឋរស់នៅតាមជនបទ។

**ស៖** ពេលដែលលោកឃើញក្បួនទៅធ្វើទស្សនកិច្ចនៅទំនប់ត្រពាំងថ្មហ្នឹង តើលោកឃើញជាក្បួនឡាន ឬក៏របៀបយ៉ាងម៉េចលោក?

**ឆ៖** ខ្ញុំឃើញក្បួនឡានគេច្រើន ហើយឡានតូចៗ។ មិនដឹងថាឡានស្អីទេ អាឡានកាត់ៗ ដូចឡានទាហានយើងអ៊ីចឹង។ អានោះឯងដឹកអង្គការ គឺឡានយើង ឃើញឡាន អាឡានស្អី ឃ្មុបៗដែលដឹកឈ្នួល ទេសចរណ៍គេ ឡានទេសចរណ៍ អានោះផង។ ប៉ុន្តែឃើញគ្នាច្រើន ឃើញតែពាក់អាវសដៃខ្លីៗ។ ពេលនោះគឺគេអត់ឱ្យពួកទ័ព ហើយនិងប្រជាជនយើងមើលមុខគេទេ គឺឱ្យតែបែរខ្នងដាក់។ ជួរកម្មាភិបាលថ្នាក់ក្រោមគេដើរប្រាប់ អត់ឱ្យមើល ពីព្រោះអង្គការមកហើយ។

**ស៖** អរគុណលោកសាក្សី។ លោកតែឃើញក្បួនហ្នឹងទៅញឹកញាប់ទេលោក?

**ឆ៖** ពេលដែលគាត់ -- ពេលអង្គការគេទៅទស្សនកិច្ចនោះ គឺគេទៅទស្សនកិច្ចចំនួន៣ខែម្ដង ជួនកាលបីបួនខែគេទៅអើតម្ដង។ ពេលដែលទៅនោះ គឺគ្មានអ្នកណាចូលជិតបានទេ គឺគេយាមបីបួនជាន់។ កងទ័ពគេដឹកពីស្វាយទៅ។

[០៩:៤៤:២៤]

**ស៖** អរគុណលោក។ ខ្ញុំចង់ឱ្យលោកបញ្ជាក់ដែរថា តើលោកដែលឃើញថ្នាក់អ្នកគ្រប់គ្រងនៅទំនប់ត្រពាំងថ្មហ្នឹង អ្នកណាដែលចុះទៅញឹកញាប់ជាងគេ ចុះទៅមើលការដ្ឋានហ្នឹងដែលញឹកញាប់ជាងគេ ហើយដែលលោកស្គាល់ ហើយដែលលោកបានដឹង?

**ឆ៖** អ្នកដែលចុះញឹកញាប់ ដែលនៅត្រួតពិនិត្យរាល់តែថ្ងៃគឺមានតែ តាវ៉ាល់ ម្នាក់ឯង ដែលគាត់ចុះទៅត្រួតពិនិត្យមើល រួចមិនរួច ស្អាតមិនស្អាត ជាប់មិនជាប់នៅលើគាត់។

**ស៖** អរគុណលោក។ ក្រៅពី តាវ៉ាល់ ដែលជាប្រធានក្ដាប់រួមនៃការដ្ឋានទំនប់ត្រពាំងថ្ម លោកមានឃើញអ្នកដឹងនាំណាផ្សេងទៀតទេ ដែលចូលចុះទៅជួយ តាវ៉ាល់ ហ្នឹង?

**ឆ៖** គឺក្រៅពី តាវ៉ាល់--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំឃើញថា សំណួរនេះវាដូចជាច្រើនពេកទៅហើយ សំណួរហ្នឹងសួរដដែលៗ ហើយមានឆ្លើយហ្នឹងច្រើនដងមកហើយ។ អ៊ីចឹងមិនគួរណាសួរដដែលៗដូច្នេះទេ ព្រោះថាសាក្សីគាត់ឆ្លើយទៅហើយ ហើយគាត់បាននិយាយទៀតផងថា អ្នកដែលមកចុះធ្វើទស្សនកិច្ចនេះពាក់អាវឃីតពណ៌ស អាវដៃខ្លី ហើយអ្នកផ្សេងទៀតគេឲ្យបែរខ្នងដាក់។ អ៊ីចឹងសួរបន្តទៀតមានន័យអី បើបែរខ្នងដាក់ទៅហើយនោះ។

[០៩:៤៦:២៥]

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន។ គឺចំណុចដែលខ្ញុំសួរចង់បញ្ជាក់ហ្នឹង គឺខ្ញុំមិនមែនសួរ ថ្នាក់លើខ្ញុំបានសួររួចហើយ ប៉ុន្តែការដែលខ្ញុំសួរជាបន្ទាប់ៗនេះ គឺជាថ្នាក់បន្ទាប់ៗរបស់ តាវ៉ាល់ អ្នកដែលចូល -- អ្នកដែលត្រូវចូលជួយរបស់ តាវ៉ាល់ មិនមែនជាថ្នាក់លើទេ។ ខ្ញុំអាចបន្តសំណួរបានទៀតទេលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីបន្តសំណួរ!

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ឥឡូវខ្ញុំឆ្លងទៅដល់លក្ខខណ្ឌការងារនៅក្នុងទំនប់ត្រពាំងថ្ម។ ម្សិលមិញលោកបានបញ្ជាក់ដែរថា លោកនៅក្នុងទំនប់ត្រពាំងថ្មហ្នឹង ហើយលោកក៏បានបញ្ជាក់ដែរថា មានពលករជាច្រើនដែលមកធ្វើការនៅក្នុងទំនប់ត្រពាំងថ្ម។ លោកមានដឹងថា អ្នកពលករដែលមកធ្វើការហ្នឹងមានចំនួនប្រហែលប៉ុន្មាន? ហើយពលករទាំងនោះមកពីតំបន់ និងស្រុកណាខ្លះ? លោកអាចបញ្ជាក់បានទេ?

**លោក ឡុត សួយ៖**

**ឆ៖** ដែលធ្វើការនៅក្នុងការងារនៅក្នុងអាងត្រពាំងថ្មនេះ គឺនិយាយរួមទៅគឺមួយតំបន់៥។ បើសព្វថ្ងៃនិយាយថាមួយខេត្តបន្ទាយមានជ័យ គឺគ្រប់ភូមិ ឲ្យតែនារី យុវជន គឺគេប្រមូលទៅឲ្យទៅលើកទំនប់ ជីកប្រឡាយនៅអាងត្រពាំងថ្មនេះឯង។

[០៩:៤៧:៥២]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីបើកមីក្រូហ្វូនសិន។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ម្សិលមិញលោកឆ្លើយបញ្ជាក់នៅចំពោះមុខសហព្រះរាជអាជ្ញាថា លោកធ្វើការនៅក្នុងទំនប់ត្រពាំងថ្ម ហើយលោកបានបញ្ជាក់ពីការរស់នៅ ពីរបបហូបចុក។ ប៉ុន្តែឥឡូវនេះខ្ញុំចង់ឲ្យលោកបញ្ជាក់បន្ថែមនូវចំណុចមួយចំនួន ដែលទាក់ទងនឹងលក្ខខណ្ឌនៃការរស់នៅរបស់ពលករនៅទីនោះ។ ខ្ញុំចង់ដឹងថា តើពលករដែលរស់នៅទីនោះ គេរស់នៅរបៀបយ៉ាងម៉េច? គឺថាក្រោយពីការបញ្ចប់ការងារហើយគេសំណាក់នៅកន្លែងណា? ការស្នាក់នៅតាមផ្ទះ ឬក៏ជារោង? សូមលោកបញ្ជាក់លម្អិតពីបញ្ហានេះបន្តិចចាស។

**លោក ឡុត សួយ៖**

**ឆ៖** ដែលធ្វើការនៅក្នុងអាងត្រពាំងថ្មនោះ គឺប្រជាជនតាមភូមិ គឺធ្វើជម្រកនៅតាមវាលស្រែបាំងកៅស៊ូ បាំងកន្ទេល ដើម្បីធ្វើជាជម្រកដេក។

**ស៖** តើជម្រកហ្នឹងពលករធ្វើខ្លួនឯង ឬក៏អង្គការធ្វើឲ្យលោក ជម្រករោងដែលស្នាក់នៅហ្នឹង? ហើយកន្ទេល មុង ភួយ ខ្នើយជារបស់ពលករ ឬក៏ជាអង្គការផ្គត់ផ្គង់?

**ឆ៖** ជម្រកដែលរស់នៅនោះ គឺៗកងចល័តធ្វើខ្លួនឯង ហើយកន្ទេល ភួយ មុង គឺយកទៅពីផ្ទះ អត់មានអង្គការបើកឲ្យទេ។ អ្នកដែលអត់កន្ទេល គឺដេកនឹងដី។

[០៩:៥០:១០]

**ស៖** ផ្អែកលើបញ្ហាស្នាក់នៅរបៀបនេះ តើបងប្អូនពលករទាំងនោះ តែងមានជំងឺតម្កាត់អ្វីខ្លះទៅ? ព្រោះដេកនៅនឹងដី គ្មានមុងគ្មានខ្នើយ ការរស់នៅគឺថាមិនបានសមស្រប។ អ៊ីចឹងតើមានជំងឺតម្កាត់អ្វីខ្លះ ដែលអាចបង្កឡើយដល់ពលករទាំងអស់នោះ?

**ឆ៖** បងប្អូនដែលរស់នៅសភាពនោះ គឺបានកើតជាជំងឺគ្រុនចាញ់ជាច្រើន។

**ស៖** លោកដែលឃើញមានមនុស្សស្លាប់ដោយសារជំងឺហ្នឹងទេ?

**ឆ៖** ខ្ញុំបានឃើញស្លាប់នៅក្នុងជំងឺនោះជាច្រើននាក់ណាស់។ មួយ ស្លាប់នឹងជំងឺគ្រុនចាញ់។ ពីរ ស្លាប់នឹងដោយសាររែកដីដាច់ចំឡក ងាប់។

**ស៖** ក្រៅពីជំងឺគ្រុនចាញ់ តើមានជំងឺអីផ្សេងទៀតទេលោកនៅកន្លែងនោះ ដែលពលករទាំង

នោះត្រូវស្លាប់?

**ឆ៖** ក្រៅពីជំងឺគ្រុនចាញ់ គឺបងប្អូនមានជាជំងឺហើម ដើរអត់រួច។

**ស៖** អរគុណលោកសាក្សី។ ខ្ញុំចង់ឲ្យលោកបញ្ជាក់មួយចំណុចទៀត។ នៅក្នុងការដ្ឋានហ្នឹង តើនៅក្នុងការដ្ឋានហ្នឹងជាកងចល័ត ដូច្នេះ អ្នកដែលជាពលករហ្នឹងមានប្រុស មានស្រី ហើយមានកុមារទេលោក? ហើយកុមារហ្នឹងពីអាយុប៉ុន្មានទៅអាយុប៉ុន្មាន លោកអាចបញ្ជាក់បានទេ?

**ឆ៖** នៅក្នុងវេនកងចល័តនោះ គឺអត់មានកុមារទេ។ កុមារគឺគេដាក់តាមភូមិ។ ម៉ែឪដែលមានកូនមានចៅ គេយកទៅដាក់នៅក្នុងរោងកុមាររបស់គេ។ មានម៉ែៗគាត់អ្នកអាចថែរក្សាកុមារនោះ។

[០៩:៥២:៥២]

**ស៖** តើកងចល័តដែលលោកនិយាយហ្នឹង តើយើងៗ -- លោកអាចដឹងទេថា តើអ្នកដែលធ្វើការនៅកន្លែងហ្នឹងអាយុទាបបំផុតប្រហែលអាយុប៉ុន្មាន?

**ឆ៖** អាយុគឺអស់ខ្ពស់ គឺមានត្រឹម៤០ចុះ។

**ស៖** ប៉ុន្តែអាយុតិចបំផុត?

**ឆ៖** បាទ ៤០មកទល់នឹងអាយុ១៧, ១៨។

**ស៖** អរគុណលោក។ ចំពោះការងារ តើគេបែងចែកតាមប្រភេទប្រុសស្រី ឬក៏រួមគ្នា?

**ឆ៖** ការងារនោះគឺគេបែងចែកដាច់ពីគ្នា។ ប្រុសគឺគេរៀបតាមប្រុស ស្រីគេរៀបតាមស្រី ដើម្បីយកការប្រឡងប្រជែងឈ្នះចាញ់គ្នា តើអ្នកណាធ្វើការជាង តើនារីធ្វើការជឿនលឿនជាងបុរស អង្គការគេចង់ដឹង។

**ស៖** អរគុណលោកសាក្សី។ ចុះផែនការដែលដាក់ឲ្យ តើក្នុងមួយថ្ងៃហ្នឹង គេគិតជាម៉ែត្រគូបហ្នឹងក្នុងម្នាក់ៗ ឬក៏នៅតាមក្រុម ឬតាមកង? លោកអាចបញ្ជាក់បានទេ?

**ឆ៖** ក្នុងតាមកងៗគឺគេវាស់ម៉ែត្រឲ្យ គេវាស់ម៉ែត្រទំនប់។ ឧបមាថា គេវាស់ម្នាក់ មួយកងអ៊ីចេះគេឲ្យ២០ម៉ែត្រ បណ្ដោយ២០ម៉ែត្រ កំពស់១៥ម៉ែត្រ ទទឹង១០ម៉ែត្រ គេឲ្យយើងរែក។ គេចែកយើងតាមកងៗ។

[០៩:៥៥:០៨]

**ស៖** ចុះបើកងនីមួយៗធ្វើមិនបាន តើនឹងមានហេតុការណ៍អីកើតឡើងដែរ?

**ឆ៖** បើកងណាមួយដែលយើងបំពេញភារកិច្ចជូនអង្គការគេមិនបាន គឺអង្គការគេយកទៅ

ភាសារបស់គេ គេយកទៅទុកដាក់ ព្រោះគេថាយើងៗក្បត់។

**ស៖** លោកសាក្សី ខ្ញុំចង់ឲ្យលោកបញ្ជាក់ លោកថា “យកទុកដាក់” ហ្នឹងមានន័យថាម៉េចដែរ “យកទុកដាក់” ហ្នឹង?

**ឆ៖** គឺគេយកទៅវៃចោល។

**ស៖** អរគុណលោកសាក្សី។ នៅក្នុងការដ្ឋានហ្នឹង ក្រៅពីការកម្លាំង ធ្វើដោយកម្លាំងបាយកម្លាំងពលកម្ម តើមានគ្រឿងចក្រទេលោក?

**ឆ៖** ពេលនោះអត់មានគ្រឿងចក្រទេ។ មានតែឡានដែលគេដឹកម្ហូបមកឲ្យ អង្ករ។

**ស៖** អរគុណលោកសាក្សី។ តើពលករទាំងអស់នោះ នៅក្នុងការបំពេញការងារ តើមានសិទ្ធិសេរីភាពក្នុងការដើរចេញពីកន្លែងធ្វើការ ឬនិយាយគ្នាសើចលេងអីទេ មានសិទ្ធិទេ? ហើយដែលមានគ្រោះថ្នាក់ការងារទេលោក?

**ឆ៖** ពេលចប់ការងារ គឺអត់មានឱកាសយើងការនិយាយគ្នាលេងទេ គឺយើងនិយាយទៅ គេតាមដានយើង។ មានតែការសម្រាក។

[០៩:៥៧:២២]

**ស៖** អរគុណលោកសាក្សី។ នៅក្នុងការបំពេញការងារហ្នឹង តើមានការតាមដាន ត្រួតពិនិត្យ ឬក៏ឃ្លាំមើលទេ? តាមរយៈអ្នកយាម ឬក៏មានឈ្លបអី ឬក៏អីគិញសម្ងាត់អីគេតាមដានយើងទេ ដែលពេលយើងកំពុងធ្វើការងារ ឬក៏ក្រៅម៉ោងធ្វើការងារ?

**ឆ៖** ក្រៅពីម៉ោងធ្វើការងារ គឺគេមានគិញសម្ងាត់របស់គេ គឺឈ្លបគេដើរធ្វើការស្ដាប់ប្រជាជននៅតាមរោងមួយៗ ខ្លាចយើងនិយាយស្ដីចង់រត់ ចង់អីទៅណា ឬយើងពោលថាលំបាក ថានឿយ គឺគេអត់ឲ្យពោលទេ។ គេថាតែស្រួលៗ។

**ស៖** អរគុណលោកសាក្សី។ តើពលករដែលធ្វើការនៅការដ្ឋានហ្នឹង ដែលត្អូញត្អែរពីការហូបមិនឆ្អែត ឬក៏ការលំបាកក្នុងការងារអីទេ? ប៊ានមាន ប៊ានត្អូញត្អែរទេ?

**ឆ៖** បងប្អូនដែលធ្វើការនៅកន្លែងនោះ គឺអត់មានអ្នកណាមួយប៊ានពោលថាហូបមិនឆ្អែតទេ។ សូម្បីតែហូបបបរក្នុងមួយចាន ក៏គេសួរថា “ឆ្អែតហើយ?” ទាល់តែឆ្លើយថាឆ្អែត បើថាមិនឆ្អែតទេ គឺគេយកទៅវៃចោល។

**ស៖** អរគុណលោកសាក្សី។ តើនៅក្នុងចំណោមពលករទាំងអស់ហ្នឹង មានស្ត្រីមានផ្ទៃពោះទេលោក?

**ឆ៖** គឺចង្កោមការដ្ឋានទាំងអស់នោះ គឺអត់មានអ្នកណាមានផ្ទៃពោះទេ គឺគេបិទសិទ្ធិអត់ឲ្យស្រឡាញ់គ្នា។ អ្នកណាដែលស្រឡាញ់គ្នា គេថាខុសសីលធម៌ គឺគេចាប់យកទៅវៃចោល។

**ស៖** អរគុណលោកសាក្សី។ ក្នុងការបំពេញការងារ ក៏ដូចជាការស្នាក់នៅ និងការហូបចុក តើមានការបែងចែកប្រជាជនថ្មី ប្រជាជនចាស់ អ្នកមូលដ្ឋាន ឬក៏ខាងយោធាអីទេលោក?

**ឆ៖** ក្នុងពេលនោះ គឺគេបែងចែកពីការបែងចែកវណ្ណៈគ្នា។ មួយគេថាប្រជាជនចាស់ មួយប្រជាជនថ្មី។ ប្រជាជនថ្មីនេះ គឺជាប្រជាជនដែលយើងនៅដីអត់បានរំដោះ គេថាយើងប្រជាជនថ្មី។ ប្រជាជនចាស់របស់គេ គឺប្រជាជនដែលគេដីដែលគេរំដោះបាន យូរឆ្នាំខែ។

**ស៖** អរគុណលោកសាក្សី។ ខ្ញុំមានសំណួរមួយទៀតជាចុងក្រោយ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថា ពេលដែលលោកនៅទំនប់ត្រពាំងថ្ម តើលោកដែលឃើញគេចាប់មនុស្សទេនៅក្នុងការដ្ឋានហ្នឹង? ឬក៏មាន លោកបានដឹងពីការបាត់មនុស្សទេនៅក្នុងការដ្ឋាន? ហើយភាគច្រើនការបាត់ និងការចាប់មនុស្សហ្នឹងធ្វើនៅពេលណា?

**ឆ៖** ពេលដែលខ្ញុំនៅយាមនៅអាងត្រពាំងថ្មនោះ គឺភារកិច្ចដោយឡែកដោយពីគ្នា គឺអត់មានទៅលូកដៃ ទៅចាប់ចងកងចល័តរបស់គេបានទេ ព្រោះគេជាកងចល័តតំបន់។ ការខុសត្រូវ និងការចាប់ចងនៅលើខាងកងវរៈរបស់គេ។

[១០:០១:១៦]

**ស៖** លោកមានបានដឹងថា នៅកន្លែងហ្នឹងមានកន្លែងឃុំឃាំងមនុស្សទេ ឬក៏ពេលគេចាប់មនុស្សហើយ គេបញ្ជូនទៅកន្លែងណាផ្សេងភ្លាម?

**ឆ៖** គឺកន្លែងនោះ គឺអត់មានកន្លែងឃុំឃាំងទេ គឺចាប់ហើយគឺបាត់ខ្លួន។

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកសាក្សី ដែលលោកបានឆ្លើយបំភ្លឺនូវចំណុចមួយចំនួនយ៉ាងច្បាស់លាស់ជូនអង្គជំនុំជម្រះ។ លោកប្រធាន ខ្ញុំអស់សំណួរ ខ្ញុំសូមប្រគល់វេទិកានេះជូនសហភាតាអន្តរជាតិ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី នាំមុខដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន ជម្រាបសួរភាគីទាំងអស់។ ខ្ញុំមានពេលវេលាខ្លី ខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោក។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសួរលោកខ្លីៗទេនៅព្រឹកនេះ។ សំណួរទី១ របស់ខ្ញុំពាក់ព័ន្ធទៅនឹងរយៈពេលដំបូង នៅពេលដែលលោកធ្វើការនៅទំនប់ គឺនៅពេលដែលលោកយាម។ ខ្ញុំចង់ដឹងថា នៅពេលដែលយាមហ្នឹង លោកមានកាន់កាំភ្លើងទេ?

[១០:០២:៤៨]

**លោក ឡុត សួយ៖**

**ឆ៖** ពេលដែលយាមនោះ គឺគេបើកកាំភ្លើងឲ្យ។ ឲ្យដើរយាមមើលទឹកអាង ខ្លាចអាងបាក់ ឬណាមួយប្រជាជន កងចល័តនោះរត់ឆ្លងដែន ឆ្លងទំនប់។ គេឲ្យចាប់បញ្ជូនទៅឲ្យតាមវរៈ តាមកងរបស់គេវិញ។

**ស៖** កាំភ្លើងដែលលោកកាន់នោះជាកាំភ្លើងប្រភេទអីដែរ?

**ឆ៖** កាំភ្លើង សេ.កា.សេ។

**ស៖** តើអ្នកយាមទាំង១០នៅក្នុងកងរបស់លោកហ្នឹង កាន់កាំភ្លើង សេ.កា.សេ ហ្នឹងដូចគ្នាមែនទេ?

**ឆ៖** បាទ គេបើកកាំភ្លើងឲ្យ សេ.កា.សេ ១០គ្រាប់ គ្រប់គ្នា។

**ស៖** តើលោកធ្លាប់បាញ់កាំភ្លើងហ្នឹងទេ នៅពេលដែលលោកព្យាយាមរាំងកុំឲ្យមានអ្នកណាម្នាក់រត់គេចចេញនោះ?

**ឆ៖** ពេលនោះខ្ញុំអត់ទាន់ចេះបាញ់ទេ។ គេបើកកាំភ្លើងឲ្យ ក៏ដើរតែស្ពាយ។

**ស៖** សូមអរគុណ។ លោកបានឆ្លើយថា លោកមានតួនាទីនៅទំនប់ហ្នឹង គឺដើម្បីពិនិត្យមើលថាកុំឲ្យមានការបាក់អាងជាដើម។ អ៊ីចឹងខ្ញុំចង់ដឹងទៀតថា មានការខូចខាតទំនប់ហ្នឹងញឹកញាប់ទេ?

[១០:០៤:៥៨]

**ឆ៖** ពេលភ្លៀងធ្លាក់ ហើយនិងទឹកជន់ ទឹកក៏ពៀបទំនប់ រលកវាវ៉ៃបក់ឆ្លងទំនប់នោះផុត ទំនប់ក៏ប្រេះ បានពួកខ្ញុំនេះរាយការណ៍ឱ្យទៅថ្នាក់លើទៅ តាណាក។ តាណាក គាត់រាយការណ៍ឱ្យទៅតាម៉ោង បានគាត់បញ្ជូនកងចល័តមកបំពេញទំនប់នោះ។

**ស៖** នៅពេលដែលលោកឃើញមានបាក់អាងទំនប់ ឬទំនប់អ៊ីចឹង មានការដាក់ទណ្ឌកម្មទៅលើអ្នកធ្វើការទេ?

**ឆ៖** ខ្ញុំស្ដាប់អត់បានផង សុំឱ្យ--

**ស៖** ខ្ញុំនឹងសួរម្ដងទៀត។ លោកនិយាយថាមានការប្រេះទំនប់ ហើយលោករាយការណ៍ទៅតាវ៉ាល់។ ក្រោយពីលោកធ្វើរបាយការណ៍ទៅលើហើយនោះ តើគេមានដាក់ទណ្ឌកម្មទៅលើអ្នកណាម្នាក់ទេ ដោយសារតែមានការប្រេះទំនប់ហ្នឹង?

**ឆ៖** គឺគាត់អត់បានដាក់កម្មនោះទៅលើអ្នកណាទេ គឺពួកខ្ញុំរាយការណ៍ទៅថា ទឹកជំនន់វាបុកមកខ្លាំង ព្រោះយើងបិទកំណល់មេទឹករបស់វា។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំនិយាយអំពីត្រពាំងថ្មនៅពេលដែលលោកជាជនស៊ីវិល។ តើលោកមានពេលសម្រាកគ្រប់គ្រាន់ទេ ពេលលោកធ្វើការនៅត្រពាំងថ្ម?

[១០:០៦:៥៩]

**ឆ៖** ពេលដែលខ្ញុំធ្វើការនៅត្រពាំងថ្មនោះ គឺបានមានពេលសម្រាកតែក្នុងមួយម៉ោងទេ។ គឺដូរគ្នាដើរទៅដើរមក មើលទឹក ហើយនិងអង្គុយយាម។

**ស៖** យើងបានស្ដាប់ចម្លើយសាក្សីមួយផ្សេងទៀតមុនលោក--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីការពារក្ដីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែសុំការបញ្ជាក់តែប៉ុណ្ណោះ មិនមែនជាការជំទាស់ទេ។ មេធាវីបានបញ្ជាក់ថា នៅពេលដែលលោកធ្វើការលើកទី១ លើកទី២ ហើយនៅពេលដែលឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា សាក្សីបានបញ្ជាក់ហើយថា គាត់ធ្វើការតែម្ដងទេនៅទំនប់នោះ។ អ៊ីចឹងដើម្បីឱ្យយើងអាចយល់សំណួររបស់មេធាវីឱ្យបានច្បាស់ សូមគាត់បញ្ជាក់ឱ្យបានច្បាស់នូវចំណុចនេះ

សិន មុននឹងគាត់បន្តទៅទៀត។ លើកទី១ លើកទី២ ហ្នឹងយ៉ាងម៉េច?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

មិនអីទេលោកប្រធាន ខ្ញុំព្យាយាមសួរឲ្យបានលឿន។ ខ្ញុំផ្អែកទៅលើចម្លើយរបស់សាក្សីទៅនឹងសហភាតារបស់ខ្ញុំកាលពីព្រឹកមិញនេះ។ គាត់បានបញ្ជាក់យ៉ាងច្បាស់ថា គាត់ធ្វើការពីរពេលនៅត្រពាំងថ្មហ្នឹង គឺដំបូងគាត់ធ្វើជាអ្នកយាមដែលជាយោធា ហើយទី២ គាត់ជាជនស៊ីវិល។ អ៊ីចឹងហើយបានជាខ្ញុំបានសូមឲ្យគាត់បញ្ជាក់ពីបទពិសោធន៍របស់គាត់ នៅពេលដែលគាត់នៅធ្វើការក្នុងរយៈកាលទី២ នៅទំនប់នោះ។ ដូច្នេះខ្ញុំគិតថា ខ្ញុំឆ្លើយតបទៅនឹងមេធាវីការពារក្ដីរួចហើយ។ ខ្ញុំគិតថា ប្រហែលជាពិបាកបន្តិច ពីព្រោះថាពីម្សិលមិញគាត់ឆ្លើយមិនសូវច្បាស់។ អ៊ីចឹងហើយបានជាសហភាតារបស់ខ្ញុំអម្បាញ់មិញនេះបានសួរបញ្ជាក់ឡើងវិញហើយ។ ហើយគាត់មាន -- មេធាវីការពារក្ដីគាត់មានសិទ្ធិសួរបញ្ជាក់បន្ថែមទៅពេលគាត់សួរនុ៎ង ព្រោះខ្ញុំអត់មានពេលច្រើនទេ។ សូមលោកមេត្តាអនុញ្ញាតឲ្យខ្ញុំបន្ត។

[១០:០៩:១៦]

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៖**

**ស៖** លោកសាក្សី ខ្ញុំសូមសួរឡើងវិញ។ យើងបានស្ដាប់ឮសាក្សីមុនលោកដែលបានបញ្ជាក់ថា អ្នកធ្វើការមួយចំនួននោះ គឺសម្រាកនៅនឹងការដ្ឋានហ្នឹងតែម្ដង។ អ៊ីចឹងលោកផ្ទាល់លោកសង្កេតឃើញអ៊ីចឹងទេ អ្នកធ្វើការនៅការដ្ឋានគឺគាត់សម្រាកនៅផ្ទាល់នឹងការដ្ឋានហ្នឹងតែម្ដង?

**លោក ឡុត ស្វយ៖**

**ឆ៖** អ្នកដែលធ្វើការនៅការដ្ឋាននោះ គឺគេត្រូវសម្រាកនៅការដ្ឋាននោះឯង ដើម្បីគេមើលការខុសត្រូវ។

**ស៖** តើមានធ្លាប់មានអ្នកធ្វើការណាដែលកំពុងតែធ្វើការៗ គាត់លង់លក់នៅពេលធ្វើការហ្នឹងតែម្ដង មានអ៊ីចឹងទេ?

**ឆ៖** ការងារដែលការលង់លក់នោះ គឺម្នាក់ៗគឺអត់ប៉ានទេ គឺប្រឹងប្រែងធ្វើយ៉ាងម៉េច ខ្លាចគេវ៉ៃចោល។ ម្ល៉ោះហើយខំប្រឹងទាល់តែឈឺ ដែលកើតជាជំងឺគ្រុនចាញ់។

**ស៖** សូមអរគុណ ខ្ញុំមានសំណួរចុងក្រោយប្រហែលជាពីរទៀត។ កាលពីម្សិលមិញ ពេលព្រឹកនោះលោកនិយាយថា លោកយំយ៉ាងខ្លាំង លោកនឹកឪពុកម្ដាយនៅពេលដែលលោកចូលធ្វើទាហាននៅឆ្នាំ៧៥។ អ៊ីចឹងខ្ញុំចង់ដឹងថា នៅពេលដែលលោកស្នាក់នៅលើទំនប់ការដ្ឋានត្រពាំងថ្មនោះ តើលោកអាច

ទៅសួរសុខទុក្ខឪពុកម្តាយរបស់លោកបានទេ?

**ឆ៖** ពេលដែលខ្ញុំដាច់ខាតនោះ ដែលខ្ញុំ គេដឹកខ្ញុំយកទៅក្នុងព្រៃនោះ ខ្ញុំក៏នឹកឪពុកម្តាយរបស់ខ្ញុំ ខ្ញុំក៏យំទៅ អត់ឲ្យគេដឹងទេ ព្រោះខ្លាចគេវៃចោល ថាខ្ញុំមិនដាច់ខាត។

**ស៖** ចុះក្រោយមកទៀត ពេលដែលលោកឃាមនៅទំនប់នោះ លោកមានបានទៅលេងឪពុកម្តាយ ឬក៏ក្រុមគ្រួសារលោកទេ?

**ឆ៖** ពេលនោះ គេអត់ឲ្យដើរចេញទៅណាទេ គឺអត់មានច្បាប់ឲ្យទៅលេងឪពុកម្តាយរបស់យើងទេ ថាយើងមិនដាច់ខាត នៅតែកម្មសិទ្ធិក្រាស់។

[១០:១២:១៦]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន ខ្ញុំគិតថា ខ្ញុំអស់ពេលហើយ។ សូមអរគុណលោកសាក្សីដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកស្រីមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី។ អរគុណ ឥឡូវនេះដល់ពេលហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ និងមេធាវីប្រឹក្សានៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅម៉ោងដប់កន្លះ។

សូមអញ្ជើញសម្រាក!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:២៨ នាទី)*

[១០:២៨:៤៦]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តទៀត លោកចៅក្រមមានសំណួរចំពោះសាក្សីរូបនេះទេ?

សូមអញ្ជើញលោក ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកសាក្សី! ខ្ញុំនឹងសួរសំណួរចំនួនដើម្បីសុំការបញ្ជាក់ពីលោក។ កាលពីព្រឹកមិញ គេសួរលោកថា តើលោកកាន់អាវុធប្រភេទណា នៅពេលដែលលោកយាមនៅទំនប់ត្រពាំងថ្ម? ខ្ញុំស្តាប់មិនយល់ចម្លើយរបស់លោក។ តើលោកអាចបញ្ជាក់ម្តងទៀតបានទេ ថានៅពេលដែលលោកយាមហ្នឹង លោកកាន់កាំភ្លើងអ្វី? ខ្ញុំឮ ហ្វេស.កា.សេ.កា យ៉ាងម៉េច ខ្ញុំស្តាប់អត់ទាន់។ លោកអាចប្រាប់បានទេថា អាវុធហ្នឹងយកមកពីណា? ហើយគេបាញ់ម្តងចេញមួយគ្រាប់ ម្តងប៉ុន្មានគ្រាប់អី លោកបញ្ជាក់ឲ្យច្បាស់បន្តិចបានទេ?

[១០:៣០:៣៦]

**លោក ឡុត សួយ៖**

**ឆ៖** បាទដែលខ្ញុំយាមនៅអាងត្រពាំងថ្មនេះ គឺគេបើកកាំភ្លើងឲ្យ គេហៅថាកាំភ្លើង សេ.កា.សេ គេនោះ គឺមានគ្រាប់តែ១០គ្រាប់។ បាញ់ម្តងចេញមួយគ្រាប់ ម្តងមួយគ្រាប់។ គឺគេបើកឲ្យដើរយាមតាមៗខ្នងទំនប់នោះ។

**ស៖** អ៊ីចឹងយើងអាចបាញ់ម្តងបានមួយគ្រាប់ហ្នឹង នៅក្នុងបង់ហ្នឹងមានគ្រាប់ច្រើនទេ ដាក់គ្រាប់ម្តងបានច្រើនទេ ក្នុងមួយបង់?

**ឆ៖** ក្នុងមួយបង់វានោះ មានតែ១០គ្រាប់។ វាអត់មានបង់ទេ វាមានតែរាងកំពកៗ ១០គ្រាប់ប៉ុណ្ណោះ។

**ស៖** លោកដឹងថា កាំភ្លើងហ្នឹង គេផលិតនៅប្រទេសណាទេ?

**ឆ៖** ខ្ញុំឮគេថា កាំភ្លើងហ្នឹង ថាចេញមកពីកាំភ្លើងចិនៗ សេ.កា ហ្នឹង សេ.កា.សេ ហ្នឹង។

**ស៖** សូមអរគុណ។ លោកបានពន្យល់ប្រាប់តុលាការថា លោកបានចូលធ្វើជាទាហាន ហើយជាទាហានដាច់ខាត។ លោកបានពន្យល់ថាលោកមិនយល់ទាំងពាក្យហ្នឹងថា "ទាហានដាច់ខាត" ហ្នឹងយ៉ាងម៉េចផង នៅពេលដែលគេប្រាប់ឲ្យលោកចូលធ្វើទាហាននោះ។ លោកអាចជម្រាបបានទេថា នៅពេលដែលលោកចូលធ្វើទាហានហ្នឹង លោកមានស្បថទេ ឬមួយក៏គេមានឲ្យលោកប្ដេជ្ញាអីទេ នៅពេលដែលលោកចូលធ្វើទាហានដាច់ខាតហ្នឹង?

[១០:៣២:៥០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយ!

សូមអញ្ជើញលោកមេធាវី ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំចង់បញ្ជាក់ទៅលើសក្ខីកម្មរបស់សាក្សីដែលបានឆ្លើយកន្លងមក ដែលគាត់និយាយអំពីពាក្យថា "ដាច់ខាត"។ "ដាច់ខាត" នេះមិនមែនមានន័យថា ជាទាហានដាច់ខាតទេ គឺរើសពីក្នុងចំណោមកងចល័តអ្នកណាដែលដាច់ខាត ដើម្បីឲ្យទៅធ្វើជាទាហាន។ នេះបើតាមខ្ញុំចាំពីសក្ខីកម្មរបស់សាក្សីកន្លងមក។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមលោកសាក្សីឆ្លើយតាមសំណួររបស់លោកចៅក្រម។

**លោក ឡុត សួយ៖**

**ឆ៖** ដែលគេថា "ដាច់ខាត" នេះ គឺគេរើសកងដាច់ខាត។ ពួកខ្ញុំនៅតាមភូមិ ក៏លើកដៃ ហើយពួកខ្ញុំក៏ល្ងង់ មិនដឹងថា "ដាច់ខាត" ហ្នឹងគឺយ៉ាងណាទេ គឺគេថា "ដាច់ខាត"។ គេសួរថា "ពួកមិត្តទាំងអស់គ្នានេះ អ្នកណាដាច់ខាតខ្លះ?" ពួកខ្ញុំក៏មិនដឹងថា គេស្មានតែដាច់ខាតលើកទំនប់ ខ្ញុំក៏លើកដៃ។ ពួកភូមិខ្ញុំ មិនថាប្រុស មិនថាស្រី គេលើក។

[១០:៣៤:៤៥]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ខ្ញុំយល់នៅពេលដែលគេជ្រើសរើសលោកហើយ ក៏ប៉ុន្តែពេលនុ៎ង គឺថាលោកអត់យល់ពាក្យថា "ដាច់ខាត" ហ្នឹងទេ។ ចុះក្រោយមកទៀត លោកមានយល់ពាក្យថា "ដាច់ខាត" ហ្នឹងមានន័យ

យ៉ាងម៉េចទេ? មានន័យថា លោកត្រូវតែខ្លាំងក្លាជាងទាហានផ្សេងទៀត ឬក៏ជាងសមាជិកផ្សេងទៀត នៅក្នុងកងចល័តមែនទេ? ហេតុអីបានជាគេនិយាយថាដាច់ខាតហ្នឹង លោកមានយល់ទេនៅក្រោយមក ទៀតហ្នឹង? ខ្ញុំដឹងថាដំបូងលោកមិនយល់ទេ ក្រោយមកទៀត លោកយល់ទេ ឬក៏លោកអត់យល់រហូត តែម្តង ពាក្យថា "ដាច់ខាត" ហ្នឹង?

**ឆ៖** ខ្ញុំក៏មិនយល់ដែរ ឮគេថា "ដាច់ខាតៗ" ខ្ញុំក៏លើកទៅដៃ ដាច់ខាត។ ដល់ដាច់ខាតនេះ គេក៏បានដឹកពួកខ្ញុំនេះទៅធ្វើកងទ័ព។ បានខ្ញុំថា ដាច់ខាតនេះ ប្រហែលដាច់ខាតធ្វើទ័ព ពួកខ្ញុំក៏ដឹក -- ដឹកពួកខ្ញុំទៅទុកក្នុងព្រៃ ស្នាច់យើង ស្នាច់រំដួលយើងនេះ។

**ស៖** លោកសាក្សី តើលោកអាចជម្រាបបានទេ ថាក្រោយពីខ្មែរក្រហមកាន់កាប់តំបន់របស់លោកបានហើយ ប៉ុន្មានខែក្រោយមកបានលោកចូលធ្វើកងទ័ព? លោកអាចបញ្ជាក់ឲ្យបានច្បាស់បានទេ?

**ឆ៖** ពួកខ្មែរក្រហមចូលបាននៅក្នុងភូមិឃុំរបស់ខ្ញុំចំនួនមួយខែ បានគេជម្លៀស បានគេរើស បានគេដេញតាមភូមិ រើសតាមភូមិនេះឲ្យមកលើកទំនប់ដឹកប្រឡាយនៅព្រៃមាន់។ គេរើសនារីយុវជនឲ្យមកលើកទំនប់ដឹកប្រឡាយ ចាប់ពីរហាលមកទល់ព្រៃមាន់នេះ គឺទំនប់អមថ្នល់ ព្រៃមាន់នេះ។

[១០:៣៧:១៦]

**ស៖** ពេលណាដែលលោកចូលធ្វើជាទាហាននោះ ជាកងទ័ពនោះ?

**ឆ៖** ខ្ញុំក៏លើកទំនប់ជាមួយបងស្រីរបស់ខ្ញុំ ចំនួនបានប្រហែលជាកន្លះខែ ក៏គេរើសកងដាច់ខាត គេប្រជុំតាមភូមិៗ ដាច់ខាត ខ្ញុំក៏លើកដៃដាច់ខាត។ មិនដឹងថាដាច់ខាតហ្នឹងគេធ្វើស្អី ខ្ញុំក៏មិនដឹងដែរ ក៏លើកដៃ។ ដល់តែលើកដៃទៅជាប់ គេរើសអ្នកណាលើកដៃ អ្នកនោះអ្នកដាច់ខាត។

**ស៖** ពេលដែលលោកធ្វើជាកងទ័ពហើយ គេចាត់តាំងលោកឲ្យចូលទៅក្នុងវរសេនាធំផ្ទាល់តែម្តង? ហើយវរសេនាធំហ្នឹងជាវរសេនាធំរបស់ស្រុក របស់តំបន់ ឬក៏យ៉ាងម៉េច? ហើយបន្ទាប់មកគេបានបែងចែក ទៅជាវរសេនាធំតាមស្រុកមកទៀត ឬក៏យ៉ាងម៉េច?

**ឆ៖** ពេលដែលគេរើសពួកខ្ញុំទៅ គឺគេបញ្ចូលនៅក្នុងវរសេនាធំតំបន់។ គេក៏បញ្ជូនពួកខ្ញុំទៅនៅនឹង ឈរជើងនៅនឹងភ្នំលៀប។ បានរយៈកាលក្រោយមកបានគេបែងចែក -- បានគេទៅប្រជុំចម្រាញ់នៅស្វាយ បានគេដកពួកខ្ញុំ គេថា១៧មេសានេះ គេដកចេញ។ បានគេបែងចែកយកមកឲ្យស្រុក។ ខ្ញុំក៏បានជាប់នៅក្នុងទឹកដីស្រុកភ្នំស្រុក ធ្វើកងស្រុកភ្នំស្រុក។

**ស៖** លោកនិយាយថា អ្នក១៧មេសា គេឲ្យទៅភ្នំស្រុកហ្នឹងយ៉ាងម៉េច? ខ្ញុំអត់យល់ មានន័យថា គេចែកកាំភ្លើងឲ្យទៅអ្នក១៧មេសាហ្នឹងនៅភ្នំស្រុកហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** គេដកអ្នកដែលគេហៅ ១៧មេសា គឺអ្នកថ្មី បានគេដកចេញពីកងទ័ពតំបន់នេះ គេទុកតែអ្នកចាស់ដែលគេ ជាគេអ្នកគេអ្នករំដោះ។ បានគេមកឲ្យយើងនៅធ្វើទ័ពនៅតាមស្រុកនេះ គេហៅសមរភូមិក្រោយ។ បានគេបញ្ជូនពួកខ្ញុំនេះ ឲ្យមកនៅស្រុកភ្នំស្រុកដើម្បីសមរភូមិក្រោយ។

**ស៖** ប្រសិនបើខ្ញុំស្ដាប់មិនច្រឡំទេគឺថា អ្នក១៧មេសាហ្នឹងក្លាយជាកងទ័ព ឬមួយក៏គេយកគេទៅសម្លាប់? ខ្ញុំដូចស្ដាប់មិនយល់ ស្ដាប់អត់ទាន់។

[១០:៤០:៤៨]

**ឆ៖** អ្នក១៧មេសាហ្នឹងដែលគេដាច់ខាតច្រើន គឺសម្បូរដោយយើងអ្នកចេះអក្សរផង អ្នកល្ងង់ផង។ ពេលនោះគឺជួរកម្មាភិបាលរបស់គេ អង្គការរបស់គេនោះ គេត្រូវចម្រាញ់។ ចម្រាញ់រកតែអ្នកល្ងង់ អ្នកណាដែលមិនចេះអក្សរបានគេឲ្យជាប់ធ្វើជាទ័ព អ្នកណាដែលចេះគឺគេដកចេញមកនៅតាមភូមិឃុំវិញ។ ពេលនោះ ខ្ញុំក៏បានគេដកចេញមកពីកងទ័ពតំបន់នោះ មកនៅនឹងទឹកដីភ្នំស្រុកនេះ។

**ស៖** កាលពីម្សិលមិញ ខ្ញុំបានស្ដាប់ឮថា នៅសម័យនោះ អ្នកណាដែលរៀនសូត្រហ្នឹងគឺអ្នកចេះដឹងហ្នឹង គេត្រូវ -- ត្រូវគេសម្លាប់ចោល។ តើលោកបានឆ្លើយអ៊ីចឹងមែនទេ ឬក៏ខ្ញុំស្ដាប់មិនច្បាស់?

**ឆ៖** អ្នកណាដែលគេចេះដឹង ដូចជាគេថា គ្រូបង្រៀនគ្រូអី ឲ្យតែគេដឹងថាយើងអ្នកចេះអីចុះ គេសម្លាប់ចោលអស់។ ម្ល៉ោះហើយ ប្រជាជនអ្នកណាដែលចេះគឺគ្នាខំលាក់ខ្លួនធ្វើជាល្ងង់។ ពេលនោះ ខ្ញុំដែលខ្ញុំរស់នៅជាមួយគេកងទ័ព ក៏ខ្ញុំអត់ធ្វើអ្នកចេះ គឺខ្ញុំធ្វើជាអ្នកមិនចេះអក្សរ។ គេក៏បង្ហាត់ស្រៈអ, ស្រៈអា, ស្រៈអិ, ស្រៈអី ខ្ញុំក៏មិនដឹងថាសរសេរយ៉ាងណាទេ ខ្ញុំចេះតែគូរដូចក្ដាម ធ្វើៗឲ្យតែគេជឿខ្ញុំ។

**ស៖** បាទ សូមអរគុណ។ ដូច្នេះខ្ញុំយល់ថា គឺលោកចូលទៅក្នុងកងដាច់ខាត លោកស្ថិតនៅក្នុងកងរបស់ស្រុក ក៏ប៉ុន្តែអ្វីដែលខ្ញុំស្ដាប់មិនសូវយល់នោះ ខ្ញុំចង់ដឹងថា តើមេរបស់លោកនុំងរាយការណ៍ទៅអ្នកណា? ប្រហែលជាមានចម្លើយខ្វែងគ្នាដែលត្រូវបំភ្លឺ។ ខ្ញុំយល់ថា មេរបស់លោករាយការណ៍ទៅមេស្រុក ដែលជា តាហាក់ ក៏ប៉ុន្តែខ្ញុំក៏យល់ផងដែរថា មេរបស់លោកនុំងក៏អាចរាយការណ៍ផ្ទាល់ទៅតាហ៊ីង្ស ឬក៏ តាពាក នេះតែម្ដង -- តាភី។ ហើយ តាហាក់ និង តាភី ហ្នឹងមិនមែនជាប្រធានស្រុកទេ គឺជាប្រធានតំបន់៥។ អម្បាញ់មិញនេះ ខ្ញុំក៏ស្ដាប់ឮថា ពេលដែលលោកនៅត្រពាំងថ្ម មេរបស់លោករាយការណ៍ទៅ តាវ៉ាល់។ អ៊ីចឹងគេរាយការណ៍ទៅថ្នាក់លើយ៉ាងម៉េច? រាយការណ៍ម្ដងទៅទាំងអស់គ្នា

ឬយ៉ាងម៉េច ឬក៏មានការប្រែប្រួលយ៉ាងម៉េច? ខ្ញុំអត់យល់។ សូមលោកបញ្ជាក់ឱ្យបានច្បាស់ម្ដងទៀត ទៅមើល៍ មេរបស់លោកហ្នឹងរាយការណ៍ទៅអ្នកណា?

[១០:៤៤:២៧]

**ឆ៖** ពេលដែលខ្ញុំធ្វើការចុះជាប់នៅអាងត្រពាំងថ្មនោះ ដែលខ្ញុំការពារអាងត្រពាំងថ្មនោះ បើសិនណាដែលទំនប់វាបាក់ មេរបស់ខ្ញុំក៏បានធ្វើរបាយការណ៍បញ្ជូនទៅឱ្យ តាវ៉ាល់។ ឱ្យ តាវ៉ាល់ គាត់បញ្ជាកូនចៅរបស់គាត់ជាកងចល័តនោះ ដើម្បីមកលើកបំពេញទំនប់នោះដែលវាប្រុងបាក់នោះ។ អានោះផ្នែកជាខាងកងចល័តជនស៊ីវិល។ បើផ្នែកខាងកងទ័ព តាណាក គាត់ក៏បានធ្វើរបាយការណ៍បញ្ជូនទៅតាហាត់ ជាគណៈស្រុក ដើម្បីដោះស្រាយកងទ័ព។

**ស៖** អ៊ីចឹង តាវ៉ាល់ ហ្នឹងគាត់ៗយ៉ាងម៉េច? គាត់ត្រូវរាយការណ៍ទៅគណៈស្រុក ឬក៏ តាណាក?

**ឆ៖** គឺ តាវ៉ាល់ នោះគឺបញ្ឈប់នៅធំនៅលើគាត់។ អ្នកណាក៏ដោយ កងចល័តតំបន់៥យើងនេះ គឺចំណុះក្នុង តាវ៉ាល់ ទាំងអស់។ ត្រូវតែរាយការណ៍ទៅឱ្យគាត់ ត្រូវលើកបានប៉ុន្មានម៉ែត្រគូបៗ ត្រូវធ្វើរបាយការណ៍បញ្ជូនទៅគាត់ អ្នករួចមិនរួច។

**ស៖** តើទំនប់ត្រពាំងថ្មស្ថិតនៅក្នុងស្រុកភ្នំស្រុកមែនទេ?

**ឆ៖** ទំនប់ត្រពាំងថ្មស្ថិតនៅក្នុងទឹកដីស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។

[១០:៤៦:៣៨]

**ស៖** លោកបានឆ្លើយថា គេបញ្ជូនលោកទៅឱ្យយាមនៅកន្លែងមួយ គឺនៅក្នុងព្រៃ ដែលមានឈ្មោះថាចម្ការខ្នុរ។ តើនៅពេលនុ៎ង លោកនៅជាទាហានស្រុកភ្នំស្រុកដដែល ឬក៏យ៉ាងម៉េច? ហើយចម្ការខ្នុរហ្នឹងស្ថិតនៅក្នុងភ្នំស្រុកដែរ ឬក៏យ៉ាងណា?

**ឆ៖** ពេលដែលគេបញ្ជូនខ្ញុំទៅឱ្យយាមនៅផ្លូវចម្ការគនោះ គឺខ្ញុំស្ថិតនៅក្នុងកងទ័ពតំបន់ពីឆ្នាំ៧៥ពាក់បណ្ដាលឆ្នាំ៧៥។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងពេលខ្លះលោកស្ថិតនៅក្រោមបង្គាប់របស់ទាហានតំបន់ និងពេលខ្លះលោកស្ថិតនៅក្នុងនៅក្រោមបង្គាប់ទាហានស្រុក អ៊ីចឹងមែនទេ? គឺមានការប្រែប្រួលអ៊ីចឹង ពេលខ្លះទៅ លោកធ្វើការក្រោមតំបន់ ពេលខ្លះក្រោមស្រុក អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពេលមុន គឺគេកងតំបន់គេរើស អ្នកដាច់ខាត។ ដល់រយៈកាលក្រោយមក បានគេចម្រាញ់ បានគេបំបែកពួកខ្ញុំនេះ ១៧មេសានេះឱ្យមកនៅតាមកងស្រុក។ បាននៅចំណុះកង តាណាក

ជាកងស្រុក ស្រុកភ្នំស្រុក។

**ស៖** បាទ សូមអរគុណ។ ពេលលោកយាមនៅចម្ការខ្នុរ តើលោកមានឃើញឡានទាហានបើកកាត់ហ្នឹងទេ? គឺឡានទាហានដែលដឹកអ្នកទោស។

**ឆ៖** ខ្ញុំអត់ដែលបានឃើញនូវ អត់ដែលបានឃើញឡានទេ ព្រោះខ្ញុំយាមតាមផ្លូវយើង ផ្លូវចម្ការគយើងនេះ សព្វថ្ងៃគេហៅ "ផ្សារថ្មីៗ" នេះ គឺខ្ញុំយាមតាមចិញ្ចើមថ្នល់នោះឯង។

[១០:៤៩:៣៦]

**ស៖** ខ្ញុំចង់ឲ្យលោកបំភ្លឺអំពីទំនាក់ទំនងរវាងកងទ័ពនិងកងឈ្លប។ លោកបានឆ្លើយថា ឈ្លបមានភារៈចាប់ខ្លួនមនុស្ស។ ក៏ប៉ុន្តែលោកក៏បានបញ្ជាក់ថា លោកខ្លួនឯងផ្ទាល់ហ្នឹងក៏ចាប់អ្នកដែលព្យាយាមរត់គេចដែរ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើកងទ័ព ហើយនិងកងឈ្លបហ្នឹងគេបែងចែកភារកិច្ចគ្នាយ៉ាងម៉េចដែរ?

**ឆ៖** កងទ័ព និងកងឈ្លបនេះគឺបែងចែកដាច់ពីគ្នា។ កងឈ្លបគេមើលការខុសត្រូវក្នុងភូមិករដើរតាមដានប្រជាជនតាមភូមិ តាមឃុំរបស់គេនីមួយៗ។ កងទ័ពសម្រាប់ការពារអ្នកដែលរត់ចេញពីអង្គភាពចូលព្រៃ។

**ស៖** ពេលដែលឈ្លបចាប់អ្នកណាម្នាក់ តើឈ្លបហ្នឹងប្រគល់អ្នកដែលគេចាប់ហ្នឹងទៅឲ្យអ្នកណា? ហើយមានប្រគល់ទៅឲ្យទាហានទេ?

**ឆ៖** ឈ្លបពេលគេចាប់បាន ជួនកាលគេបញ្ជូនទៅឲ្យ តាហាត់ គណៈស្រុក។ ជួនកាលគេក៏សម្លាប់ខ្លួនគេ។

**ស៖** ដូច្នេះមានន័យថា ឈ្លបហ្នឹងពេលខ្លះទៅគាត់សម្លាប់អ្នកដែលគេចាប់ខ្លួនបានហ្នឹងដោយខ្លួនឯងផ្ទាល់។ ចុះពេលចាប់ខ្លួនបានហ្នឹង ឈ្លបមានធ្លាប់ប្រគល់ទៅឲ្យខាងកងទ័ពទេ?

**ឆ៖** គេអត់ដែលបានប្រគល់មកឲ្យខាងកងទ័ព ដែលយើងការពារទេ គេប្រគល់ទៅឲ្យថ្នាក់លើបញ្ជូនទៅតែម្តង ព្រោះមេរបស់គេមាន។

[១០:៥២:២៨]

**ស៖** គេចាត់វិធានការយ៉ាងណាខ្លះ ដើម្បីយាមព្រំដែនជាមួយថៃ? គេមានខ្លាចអ្នកគេរត់គេចទៅថៃទេ? ហើយខាងកងទ័ពហ្នឹងមានចាត់ចែងវិធានការយ៉ាងម៉េច ដើម្បីការពារកុំឲ្យមានអ្នករត់ចូលទៅខាងថៃទេ?

**ឆ៖** អានោះខ្ញុំដឹងអត់ដល់ដែរ ដែលគេនៅតាមព្រំដែនថៃនិងខ្មែរនោះ ព្រោះខ្ញុំនៅខាងព្រៃកូនខ្លែង។ ព្រៃកូនខ្លែងនេះ វាជាប់នឹងមាត់អាងត្រពាំងថ្មនេះឯង។ គឺខ្ញុំនៅនិងរស់នៅនឹងកូនខ្លែងនោះមិនដែលបាន ជួបបងប្អូនរត់ បានខ្ញុំមិនដែលដឹង។

**ស៖** តើលោកស្ដាប់ឮ មានមាក៏បីសម្រាប់ការពារបន្ទាត់ព្រំដែនទេ? លោកមានឮគេនិយាយ អំពីអន្ទាក់ឬស្សីដែលគេដាក់សម្រាប់ការពារនៅព្រំដែនទេ?

**ឆ៖** ខ្ញុំឮៗ តែគេនិយាយ ហើយខ្ញុំឃើញ តាៗតាមភូមិនោះគាត់ធ្វើជាចម្រូង។ ខ្ញុំសួរគាត់ថា "ឪឯងធ្វើចម្រូងធ្វើអី?" ថាគាត់ "អ្ហូលោកកូន ខ្ញុំធ្វើដើម្បីបញ្ជូនទៅឲ្យកងទ័ពគេនៅព្រំដែន"។ ក៏ខ្ញុំក៏មិន ដឹងថាគេយកចម្រូងនោះទៅធ្វើព្រំដែន មិនដឹងគេដាក់យ៉ាងណា ឮតែតាៗតាមភូមិគាត់និយាយ។

**ស៖** កាលពីម្សិលមិញ គឺយើងបាននិយាយអំពីការធ្វើតេស្តសាកល្បងទៅលើអ្នកដែលធ្វើពុតជា ខ្វាក់មាន់ ដែលមិនអាចមើលឃើញច្បាស់នៅពេលយប់។ ចុះលោកផ្ទាល់ លោកធ្លាប់ស្ដាប់ឮថាគេមាន ធ្វើតេស្តទៅលើអ្នកដែលខ្លួនឯងថា ខ្វាក់មាន់ហ្នឹង មានឃើញគេធ្វើតេស្តអីទេ? ដែលគេដាក់ឲ្យៗដើរទៅ ៗមុខអន្លង់ ឬក៏ជួនកាលគេដាក់រងើកភ្លើង ហើយឲ្យដើរកាត់អីអ៊ីចឹង លោកធ្លាប់ឃើញទេ?

[១០:៥៥:២៤]

**ឆ៖** ខ្ញុំអត់ដែលបានឃើញទេ។ ឮតែពួកកងចល័តដែលភូមិខ្ញុំនៅជិតខ្ញុំ វានិយាយថា អ្នកងងឹត មាន់ អ្នកណាដែលពុតថាងងឹតមាន់ គេដឹកទម្លាក់អន្លង់ បើអ្នកណាងងឹតមាន់មែន ដើរចូលក្នុងអន្លង់គេ ទាញមកៗវិញ។ បើអ្នកណាដែលមិនងងឹតមាន់ កុហកថាងងឹតមាន់តែឃើញអន្លង់ដើរគេចៗ ម៉្លោះ ហើយប្រធានកងគេនោះ គេក៏ច្រាលទម្លាក់ក្នុងអន្លង់នោះ។ ពេលនោះបានគេស្រង់មកកសាង គេថា ទិតៀនយើង ថ្ងៃមុខថ្ងៃក្រោយកុំឲ្យកុហកគេ កុំឲ្យ គេថាៗ សតិអារម្មណ៍។ គេថា ជំងឺសតិអារម្មណ៍ កុហកគេ។ បើគេអប់រំម្ដងហើយមិនបាន លើកក្រោយគេក៏វ៉ៃយើងចោល។

**ស៖** តើតេស្តដែលគេប្រើអន្លង់ហ្នឹង លោកឃើញផ្ទាល់ភ្នែកទេ ឃើញគេឲ្យដើរកាត់អន្លង់ហ្នឹង ផ្ទាល់ភ្នែកទេ?

**ឆ៖** ខ្ញុំអត់បានឃើញនឹងភ្នែកទេ ឮតែស្រុកភូមិខ្ញុំដែលវាលើកទំនប់នៅកន្លែងនោះប្រាប់ ថា យប់មិញគេ អាមួយនោះវាធ្វើជាងងឹតមាន់ ដែលវាយ៉ាប់ណាស់ពេកនឿយណាស់ពេក សោ វាធ្វើងងឹត មាន់ ក៏សុំគេសម្រាក។ គេថាបើងងឹតមាន់មក គេក៏ដឹកដៃមក។ ដឹកដៃមកទៅតម្រង់អន្លង់។ ដល់ពេល មួយទៀតដែលវាងងឹតមែន ដឹកមកដល់អន្លង់ វាចេះតែដើរទៅ គេក៏ ប្រធានកងគេក៏ទាញមកវិញ គេ

ក៏ឲ្យសម្រាក។ ដល់អាមួយនោះមិនងងឹត ធ្វើជាងងឹត ដល់ពេលដល់មាត់អន្លង់ ដើរគេចចេញ បានប្រធានកងគេច្រាលទម្លាក់ក្នុងអន្លង់នោះ។ បានគេទាញដៃឡើងមក បានគេកសាងយើងទាំងយប់ គេទិតៀន បានខ្ញុំដឹង។ ដល់ព្រឹកឡើងបានភូមិខ្ញុំគេប្រាប់ថា យប់មិញអាមួយនោះធ្វើធ្លាក់អន្លង់ ធ្វើជាងងឹតមាន់។ នេះឯងបានខ្ញុំដឹង។

**ស៖** ចុះគេធ្វើតេស្តដែលឲ្យដើរកាត់រងើកភ្លើងនេះ លោកបានឃើញផ្ទាល់ភ្នែក ឬក៏លោកស្តាប់ឮពីគេ?

[១០:៥៨:២៤]

**ឆ៖** អានោះខ្ញុំអត់ដែលបានឃើញផ្ទាល់ភ្នែកទេ ខ្ញុំឮតែកងចល័តគេនិយាយ។ គេនិយាយគ្រប់តែគ្នា ព្រោះម្នាក់ៗវានឿយៗណាស់ ពុំដែលបានសម្រាក ហើយហូបមិនដែលបានឆ្អែត។ ម្ល៉ោះហើយប្រជាជនត្រូវរើបម្រាស ប្រើគ្រប់កលល្បិចដើម្បីឲ្យបានឈប់ក្នុងខណៈមួយពេល។

**ស៖** បាទ សូមអរគុណ។ មុននេះបន្តិចលោកបាននិយាយអំពីក្រដាសលុយ លោកបានឃើញ។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេថា ពេលណាដែលលោកឃើញលុយទាំងអស់ហ្នឹងគឺក្នុងសម័យកាល នៅក្នុងរយៈកាលណាដែរ? ក្រោយពី១៧ មេសា ភ្លាមៗតែម្តង ឬក៏មុនពេលវៀតណាមចូលមកបន្តិច?

**ឆ៖** លុយនោះ ក្រដាសលុយនោះ មុនវៀតណាមចូលចំនួនបានប្រហែលជា១២ខែ គឺគ្នាខ្ញុំបានលុយមកពីណាទេ វាប្រាប់ថានេះលុយយើងបើកប្រាក់ខែ តាមសហករណ៍។ គេថា បើយុទ្ធជនបានម្នាក់ ១០រៀល បើគេមានអ្នកភារកិច្ច ប្រធានក្រុមបាន២០ៗរៀល។ ខ្ញុំក៏សួរថា "មិត្តឯងបានក្រដាសពីណាមក?" ថា "អញបានមកពីបង" អ៊ីចេះ! បងគាត់ឲ្យមើល។ ខ្ញុំក៏ចាប់ក្រដាសប្រាក់មើលក៏ឃើញប្រជាជនច្រូតស្រូវ រូបប្រជាជនច្រូតស្រូវ និងប្រជាជនលីចប។ ក្រដាសលុយនោះពណ៌ក្រហមរាងឈាមជ្រូក។ បានបាំងប្រហែលជា២ខែ ក៏បានវៀតណាម បានកងទ័ពវៀតណាមរំដោះបាន។

[១១:០០:៥២]

**ស៖** អ៊ីចឹងនៅពេលដែលលោកឃើញលុយហ្នឹង ពេលនោះយើងអាចនិយាយបានថាកម្មាភិបាលភូមិភាគពាយ័ព្យហ្នឹងត្រូវបានកងកម្លាំងនីរតីហ្នឹង ចាប់ខ្លួនរួចទៅហើយ មែនទេ?

**ឆ៖** បាទ ពេលនោះគឺ មុននោះគឺភូមិភាគពាយ័ព្យបានពួកនីរតីចាប់បានអស់។ ពេលដែលលុយធ្លាក់មកដល់នេះ គឺភូមិភាគនីរតីដែលគេបាន មកនេះ។

**ស៖** ខ្ញុំមិនសូវយល់។ លោកចង់និយាយថាកម្មាភិបាលភូមិភាគនីរតីហ្នឹងជាអ្នករៀបចំចែកចាយចរាចរលុយនៅភូមិភាគពាយ័ព្យហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** អាហ្នឹងខ្ញុំដឹងអត់ដល់ដែរ ប៉ុន្តែខ្ញុំឮតែគ្នាខ្ញុំនិយាយ គេថាលុយនេះបានមកពីបង ពេលនោះគឺភូមិភាគពាយ័ព្យអត់មានអ្នកណានៅទេ គេចាប់អស់ហើយ។ មានតែភូមិភាគនិរតីដែលនៅឈរជើងនៅនឹងទឹកដីភ្នំស្រុកនោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថា មេធាវីការពារក្ដីនឹងសួរសំណួរច្រើនពាក់ព័ន្ធនឹងបញ្ហានេះ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកសាក្សី សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកចៅក្រម។ ជាបន្តទៀត អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីដើម្បីតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ជាដំបូងអង្គជំនុំជម្រះប្រគល់វេទិកាទៅក្រុមមេធាវីការពារក្ដីលោក នួន ជា។ សូមអញ្ជើញលោកមេធាវី!

[១១:០៣:០៥]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ តាមពិតខ្ញុំមានសំណួរមួយចំនួនត្រូវសួរទៅលោក។ ខ្ញុំនឹងចាប់ផ្ដើមជាមួយនឹងសំណួរទាក់ទងទៅនឹង តើពេលណាឲ្យប្រាកដ ដែលលោកទៅយាមនៅក្នុងឋានៈជាឈ្លបនៅទំនប់ត្រពាំងថ្ម ព្រោះខ្ញុំមិនទាន់យល់ច្បាស់សោះ ហើយខ្ញុំឲ្យលោកគិតទាក់ទងទៅនឹងខែហើយនិងថ្ងៃជាកាលបរិច្ឆេទ។ បើសិនជាខ្ញុំអាចផ្ដល់កាលបរិច្ឆេទនេះ រំឭកដល់លោក ប្រហែលជាអាចលោកអាចនឹកឃើញបានខ្លះ។ កាលពីម្សិលមិញ នៅក្នុងសាលសវនាការនេះ យើងបានឮសាក្សីម្នាក់និយាយថា ការងារនៅការដ្ឋានត្រពាំងថ្ម គឺចាប់ផ្ដើមនៅថ្ងៃទី១៤ កុម្ភៈ ១៩៧៧ ហើយប្រហែលជានៅមុនចូលឆ្នាំខ្មែរ ប្រហែលជានៅខែមេសា ឆ្នាំ១៩៧៧ ការងារនោះក៏ត្រូវបានបញ្ចប់ ហើយក៏យើងបានអត្ថបទចម្លងនៃសុន្ទរកថា ដែលមេដឹកនាំភូមិភាគពាយ័ព្យ រស់ ញឹម បានផ្ដល់ បានអាននៅខែធ្នូ ឆ្នាំ

១៩៧៧ ជាមួយនឹងវត្តមានរបស់គណៈប្រតិភូចិន។ ហើយគាត់និយាយថា ទំនប់ ការដ្ឋានហ្នឹងត្រូវតែបញ្ចប់ក្នុងរយៈពេល២ខែ។ ហើយទង់បដិវត្តឆ្នាំ១៩៧៧ ខែមិថុនា ក៏បាននិយាយប្រហាក់ប្រហែលគ្នានេះដែរ ថាត្រូវតែបញ្ចប់ក្នុងរយៈពេល២ខែ។ តើអាចដែរឬទេ នៅពេលដែលលោកបំពេញភារកិច្ចជាឈ្លបនៅការដ្ឋានត្រពាំងថ្មនោះ តើពីចន្លោះពាក់កណ្ដាលខែកុម្ភៈ រហូតទៅដល់ខែឧសភា ឆ្នាំ១៩៧៧ ហ្នឹងដែរឬទេ?

[១១:០៥:៤៤]

**លោក ឡុត ស្លួយ៖**

**ឆ៖** ខ្ញុំអត់យល់។

**ស៖** ខ្ញុំយល់ថាជាសំណួរវែង ប៉ុន្តែខ្ញុំផ្ដល់ជូនលោកនូវភស្តុតាងទាក់ទងនឹងកាលបរិច្ឆេទមួយចំនួន ដែលទំនប់ហ្នឹងត្រូវបានសាងសង់។ ហើយភស្តុតាងទាំងអស់នេះបញ្ជាក់ថា ៗទំនប់ហ្នឹងបានចាប់ផ្ដើមកសាងពីពាក់កណ្ដាលខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយបញ្ចប់ក្រោយហ្នឹងក្នុងរយៈពេល២ខែ អាចនៅខែដើមខែមេសា។ ហើយខ្ញុំសួរលោកថា នៅពេលដែលលោកធ្វើការនៅជាអ្នកយាមនៅទីនោះ គឺថាពាក់កណ្ដាលខែមេសា ឆ្នាំ១៩៧៧ ហើយតើទៅដល់ខែឧសភា ឆ្នាំដដែលហ្នឹង ១៩៧៧ហ្នឹង តើការដ្ឋានទំនប់ហ្នឹង វាចប់ពេលហ្នឹងដែរ ឬយ៉ាងម៉េច?

**ឆ៖** ពេលដែលខ្ញុំរស់នៅក្នុងយាមពេលនោះ ក៏ពួកកងទ័ពនិរតី ដែលខ្ញុំកាល តាណាក គាត់នៅគាត់ឱ្យពួកខ្ញុំយាម យាមការពារទឹកអាងនោះ។ ពេលនោះទំនប់ក៏អត់ទាំងរួច រួចស្រួលបួលទេ។ ពេលនោះក៏ភូមិភាគនិរតីចូលដល់ចាប់ពួក តាណាក ទៅផុតនេះ ក៏គេបានដកពួកខ្ញុំចេញពីទំនប់នោះ ទៅនៅជាកងចល័ត។ កងចល័តនោះ គឺមិនមែនកងចល័តតំបន់ទេ គឺកងចល័តតាមភូមិ។ គេក៏បានឱ្យខ្ញុំដើររើសអាចម៍គោ ដើរស្វែងអាចម៍តាមចល័តគេ ដើម្បីយកលេសរើចោលពួកខ្ញុំនេះ។ ពួកខ្ញុំក៏បំពេញភារកិច្ចនោះ អត់មានឱ្យឆកល្វែង។

[១១:០៧:៥៩]

**ស៖** លោកសាក្សី ខ្ញុំសូមកាត់លោកបន្តិច ហើយខ្ញុំសួរលោកខុសពីនេះវិញ។ តើលោកដឹងឬទេថាតើការដ្ឋានការងារត្រពាំងថ្មហ្នឹងបញ្ចប់នៅពេលមួយ ដែលថានៅពេលចូលឆ្នាំខ្មែរក្នុងឆ្នាំ១៩៧៧ដែរឬទេ?

**ឆ៖** ពេលនោះខ្ញុំអត់ដឹងថា ខែណាឆ្នាំណាទេ។ ប៉ុន្តែពេលដែលខ្ញុំៗរើស -- ពេលដែលខ្ញុំដកពួក

ខ្ញុំចេញនេះ ខ្ញុំមកវិញក៏ឃើញថា ពួកចល័តគេនៅតិច។ ឃើញកងចល័តនៅចំនួនប្រហែល១០០នាក់ ដើរបំពេញទំនប់នោះ ប៉ុន្តែមិនដឹងថា ឆ្នាំណានោះឯង។

**ស៖** បាទ ខ្ញុំយល់ហើយ ខ្ញុំសួរមួយទៀត។ តើលោកបានចាកចេញពីការដ្ឋានទំនប់ត្រពាំងថ្មនៅពេលដែល តាវ៉ាល់ ត្រូវបានគេចាប់ខ្លួនឬទេ?

**ឆ៖** ពួកខ្ញុំដែលចេញពីអាងត្រពាំងថ្មនេះ ដែលគេចាប់ពួក តាវ៉ាល់, តាណាក, តាហាត់ អស់បាននៅសល់តែពួកកងទ័ពចំនួនគ្នា៩០នាក់នេះ បាននិរតីគេហៅទៅដកអាវុធ។ បានគេឲ្យពួកខ្ញុំនេះ នៅជាកងចល័ត កងចល័តរបស់ តាម៉ោង។ តាម៉ោង នោះគឺតាម៉ោងនិរតី គាត់នៅនិរតី គាត់ឈ្មោះតាម៉ោងៗនិរតី។

**ស៖** បាទ ហើយលោកសាក្សី តើលោកចាំទេ តើប៉ុន្មានថ្ងៃ ឬក៏ប៉ុន្មានអាទិត្យបន្ទាប់ពីគេចាប់ខ្លួន តាវ៉ាល់ ទៅនោះ ហើយគេចាត់តាំងលោកឲ្យទទួលការងារថ្មី ដូចលោកថាអំមិញឲ្យចូលកងចល័តជាដើមហ្នឹង?

[១១:១០:៤៣]

**ឆ៖** គេចាប់ពួក តាវ៉ាល់ រយៈកាលចំនួនបានប្រហែលកន្លះខែ បានគេមកស្រាវជ្រាវកងទ័ពពាយ័ព្យ ឲ្យពួកខ្ញុំនៅតាមអាងត្រពាំងថ្ម នៅតាមកូនខ្លែងនេះ។ គេក៏ហៅប្រមូលមកកន្លែងស្រុកភ្នំស្រុកដើម្បីដកអាវុធ បានគេឲ្យចូលទៅក្នុងចល័ត។

**ស៖** បាទឥឡូវនេះខ្ញុំៗយល់ហើយលោកសាក្សី។ នៅពេលដែលលោកចាកចេញពីទំនប់នោះ ឥឡូវនេះខ្ញុំនឹងពិនិត្យមើលរកឲ្យឃើញ ថាតើនៅពេលណាដែលលោកទៅដល់ទំនប់នោះ។ តើលោកនៅចាំដែរឬទេ នៅពេលដែលលោកទៅដល់ដំបូងទៅកន្លែងទំនប់នោះ តើមានមនុស្ស១០.០០០ ឬក៏ប៉ុន្មាននាក់ធ្វើការនៅកន្លែងហ្នឹង ឬក៏នៅតែមានមនុស្សថ្មី ឬក៏កងចល័តថ្មីបន្តមកការដ្ឋានហ្នឹងទៀត?

**ឆ៖** ពេលដែលខ្ញុំនៅកងចល័ត ដកខ្ញុំមកនៅកងចល័តនោះ ខ្ញុំក៏មករើសអាចម៍គោនៅកៀនទំនប់នោះ ក៏ឃើញកងចល័តចំនួន១០០នាក់ ដើម្បីដែលគេឲ្យនៅការពារៗទំនប់ត្រពាំងថ្មនេះ ដើម្បីឲ្យខ្លាចវាបាក់ ឲ្យរែកដីបំពេញ។ ខ្ញុំក៏ភ្លេចគិត មិនដឹងថាឆ្នាំ៧៧ មិនដឹងថាឆ្នាំ៧៦។

**ស៖** ខ្ញុំមិនប្រាកដថា ខ្ញុំស្តាប់ចម្លើយរបស់លោកច្បាស់ គ្រប់ទាំងអស់ទេ។ តើលោកប្រចាំការនៅទំនប់ហ្នឹងពីមុន ហើយដូចថាកងចល័ត១០.០០០នៅទីនោះរួចហើយ ឬក៏មកពេលណា ឬក៏គេមកក្រោយ មុន ឬក៏ក្រោយលោកនៅទីនោះ?

**ឆ៖** កងចល័តដែលនៅគ្នាច្រើននោះ គឺគេដកទៅនៅៗធ្វើការនៅខាងទំនប់ស្ពានស្រែង គេក៏បានបន្សល់ទុកមួយកងធំនោះ ដើម្បីឲ្យនៅការពារទំនប់ត្រពាំងថ្មនោះ។

[១១:១៣:៣៩]

**ស៖** ខ្ញុំគិតថាសំណួររបស់ខ្ញុំបានសួរម្ដងទៀត។ នៅពេលដែលលោកក្រឡេកមើលទៅទំនប់ហ្នឹងជាលើកដំបូង ថាតើមនុស្សភាគ -- មានមនុស្សច្រើនធ្វើការនោះហើយឬនៅ? ឬក៏ពេលដែលលោកទៅដល់ដំបូង មើលឃើញដំបូងហ្នឹង ទើបតែគេចាប់ផ្ដើមការងារសាងសង់ទេ?

**ឆ៖** ពេលដែលខ្ញុំឃើញដំបូងនោះ ពេលដែលខ្ញុំ កាលដើមឡើយខ្ញុំក៏នៅកូនខ្លែង ក៏ខ្ញុំក៏ចាប់ផ្ដើមឃើញគេវាស់ៗទំនប់នោះ។ គេក៏បោះបង្គោលៗឲ្យត្រង់ ចាប់ពីពន្លៃមកទល់ត្រពាំងថ្មនោះ។ បានរយៈកាលកន្លងក្រោយមក បានឃើញកងចល័តតំបន់នេះ គេចុះមកនៅតាមភូមិ ប្រមូលតាមភូមិតាមឃុំ មកលើកនៅទំនប់ត្រពាំងថ្មនេះ គឺមនុស្សរាប់ម៉ឺន មនុស្សចាប់ពីពន្លៃមកទល់នឹងអាងត្រពាំងថ្មនេះ។

**ស៖** បាទ សូមអរគុណលោកសាក្សី។ ឥឡូវនេះ គឺចំណុចមួយទៀតដែលខ្ញុំមិនច្បាស់ ថាខ្ញុំយល់បានត្រឹមត្រូវ។ នៅក្នុងចម្លើយរបស់លោកឆ្លើយទៅការិយាល័យសហចៅក្រមស៊ើបអង្កេត នៅក្នុងសំណួរមួយ សំណួរលេខ៣០ លោកបានឆ្លើយទៅសំណួរដូចតទៅនេះ៖ “មុនពេលដែលគេជ្រើសរើសតាំងលោកឲ្យជាយោធាស្រុក តើលោកបានទៅធ្វើការនៅត្រពាំងថ្មទេ?” លោកឆ្លើយថា៖ ខ្ញុំមិនបានធ្វើការយូរទេ។ ខ្ញុំនៅទីនោះបានតែ១០ថ្ងៃ។ បន្ទាប់មកគេជ្រើសខ្ញុំឲ្យជាយោធាស្រុកភ្នំស្រុក។” អ៊ីចឹងសួរថា តើៗរយៈពេល១០ថ្ងៃហ្នឹង គឺលោកនៅកន្លែងណាដែលលោកនិយាយបែបនេះនោះ?

**ឆ៖** ពេលដែលខ្ញុំធ្វើយោធា ១០ -- ពេលរយៈកាល១០ថ្ងៃនោះ ដែលខ្ញុំចូលធ្វើយោធាស្រុកនោះ ខ្ញុំក៏រស់នៅនឹងទឹកដីអាងត្រពាំងថ្មនោះដែរ។

[១១:១៦:១៧]

**ស៖** បាទ ដូច្នេះ ខ្ញុំនឹងបន្តទៅមុខទៀតលោកសាក្សី។ ទាក់ទងទៅនឹងការងារយាមរបស់លោកនៅក្នុងឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាដែលលោកបានឆ្លើយនោះ ERN 00728728, ខ្មែរ 0073 307 *(ស៊ីក)*។ លោកបាននិយាយថា៖ “នៅត្រពាំងថ្ម មិនមានកងទ័ពច្រើនទេ មានតែយោធា មានតែកងអនុសេនាតូចយោធា ប៉ុន្តែមានកងទ័ពនៅកូនខ្លែង។ មានតែកងរបស់ តាអាត ទេនៅទំពាំងថ្មនោះ។” តើមានការណែនាំពី តាអាត ឬទេទៅសមាជិកកងដែលធ្វើការនៅត្រពាំងថ្ម ដើម្បីឲ្យពួកគេនោះយាមកម្មករដែលមានចំនួន១០.០០០ ឬក៏១៥.០០០នាក់នៅការដ្ឋាននោះ? តើមានការណែនាំបែបនោះទៅ

កងយោធានោះទេ?

**ឆ៖** គឺកង តាអាត នោះគាត់មាន -- គាត់ក្តាប់កងតូច។ គាត់បានដាក់កូនចៅគាត់យាមតាមអាងត្រពាំងថ្ម តាមមាត់ គឺថាតាមទំនប់ត្រពាំងថ្មនេះ គឺទៅដល់ដាក់នៅព្រលិនទន្រ្ទាន(?) មួយកន្លែង ដាក់ធ្មេញត្រីមួយកន្លែង។

**ស៖** តើនៅក្នុងកងអនុសេនាតូចនោះមានសមាជិកប៉ុន្មាននាក់?

**ឆ៖** ក្នុងសមាជិក ក្នុងកងតូចនោះ មានចំនួនគ្នា៣០នាក់។ ដាក់មួយកន្លែងមួយក្រុមៗ។

**ស៖** តើការងារដូចថាការណែនាំជាក់លាក់ទៅក្រុមនីមួយៗដែល តាអាត ហ្នឹងគាត់បញ្ជានោះ ថាតើគាត់បានណែនាំឲ្យក្រុមនីមួយៗនោះធ្វើអ្វីឲ្យពិតប្រាកដ?

**ឆ៖** តាអាត គាត់បានណែនាំកូនចៅថ្នាក់ក្រោមនោះឲ្យដើរយាម ការពារប្រជាជនខ្លាចរត់។

**ស៖** នៅក្នុងចម្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជារបស់លោកនៅក្នុងភាសាអង់គ្លេស 0072827, ខ្មែរ 00733025 លោកបាននិយាយថា នៅពេលដែលលោកយាមនៅទីនោះ គឺមិនមានអ្នករត់គេចខ្លួនទេ។ ប៉ុន្តែខ្ញុំចង់ដឹងថាតើ តាអាត ហ្នឹងចាត់យោធាឲ្យយាមកងពល១០.០០០ ឬ១៥.០០០នាក់នៅការដ្ឋាននោះ តែកងអនុសេនាតូចមួយប៉ុណ្ណឹង ថាតើអាចទៅរួចទេ?

**ឆ៖** បានដែលគាត់ឲ្យយាមនោះ គឺដើម្បីឲ្យធ្វើការ ដើរធ្វើការរាល់ថ្ងៃ យប់ថ្ងៃ។ ដើរធ្វើការងារទាក់ទងគ្នាកុំឲ្យដាច់។ ម្ល៉ោះហើយប្រជាជនទាំងអស់នោះ ក៏គ្នាអត់ហ៊ានរត់ដែរ ប៉ុន្តែវាអត់ស្គាល់ទឹកដីព្រៃ ព្រោះតំបន់នោះជាតំបន់ព្រៃដុង គឺព្រៃដំរី ព្រៃខ្លានោះឯង។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំនឹងបន្តទៅសួរលោកសំណួរមួយចំនួនទាក់ទងនឹង តាវ៉ាល់។ តើត្រូវទេ នៅពេលដែលខ្ញុំនិយាយថា ពេលដែលលោកធ្វើការនៅទំនប់នោះ គឺពេលវេលាភាគច្រើននៅពេលនោះ គឺតាវ៉ាល់ គឺជាអ្នកដឹកនាំការដ្ឋាននោះ?

[១១:២១:៤៥]

**ឆ៖** ខ្ញុំស្តាប់អត់យល់ផងលោកមេធាវី។

**ស៖** បាទ នៅក្នុងរយៈពេលដែលលោកធ្វើការជាអ្នកយាមនៅទំនប់ត្រពាំងថ្មនោះ តើ តាវ៉ាល់ គឺជាមនុស្សម្នាក់ ជាអ្នកទទួលខុសត្រូវរហូត ឬក៏ភាគច្រើនណាមួយនៅក្នុងការដ្ឋាននោះ ការដ្ឋានទំនប់នោះ?

**ឆ៖** ព្រោះក្នុងការដ្ឋានទំនប់នោះ គឺជា តាវ៉ាល់ គាត់ក្តាប់រួមទាំងអស់ក្នុងមួយតំបន់៥នេះ គឺ

កន្លែងទំនប់ត្រង់ណាក៏គាត់ក្តាប់រួមដែរ។ ព្រោះចល័តច្រើន បែងចែកគ្នាលើកតាមទំនប់ ដូចជាទំនប់រន្ទះបាញ់ក្តី ទំនប់ស្ពានស្រែង ទំនប់អាងត្រពាំងថ្ម គឺជាចល័ត១តំបន់ ហើយនិងចល័តតាមភូមិលើក នៅក្នុងការគ្រប់គ្រងរបស់ តាវ៉ាល់ ទាំងអស់។

**ស៖** ហើយគឺ តាវ៉ាល់ នេះឯងជាអ្នកទទួលខុសត្រូវលើលក្ខខណ្ឌនៃការរស់នៅ ហើយពេលម៉ោងធ្វើការ ហើយនិងការព្យាបាលអ្នកដែលមានជំងឺអីជាដើម។ តើអ៊ីចឹងឬទេ?

**ឆ៖** បាទ ពេលដែលអ្នកឈឺគឺគាត់បញ្ជូនពេទ្យ គឺពេទ្យមានតាមកសិដ្ឋាន។ គឺពេទ្យនោះអត់មានថ្នាំអីទេ គឺមានតែថ្នាំឫសឈើយើង ឲ្យបុកឲ្យកើតជាឫស បុកឲ្យកើតជាម្សៅ ដើម្បីលញ់១ធ្វើជាថ្នាំបំបាត់គ្រុនញាក់ បំបាត់គ្រុនក្តៅ បំបាត់ហើម។ ថ្នាំនោះប្រហែលប៉ុនមេដៃលេប បើសព្វថ្ងៃលេបអត់រួចទេ ធំណាស់។

[១១:២៤:១៣]

**ស៖** លោកសាក្សី សក្ខីកម្មដែលលោកបានឆ្លើយព្រឹកនេះ និងម្សិលមិញនោះ គឺថាអ្វី១ដែលលោកបានឃើញនៅពេលដែលលោកនៅទំនប់នោះ គឺអ្វី១ដែលប្រជាជនរងការឈឺចាប់នោះ គឺចាប់ពីដំបូងដល់ចុងបញ្ចប់ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ការទទួលខុសត្រូវរបស់ តាវ៉ាល់ ទាំងអស់។ តើអ៊ីចឹងឬទេ?

**ឆ៖** បាទ តាំងពីឆ្នាំ៧៥មកទល់ថ្ងៃយើងបញ្ចប់នេះគឺ តាវ៉ាល់ គាត់អ្នកគ្រប់គ្រងទាំងអស់។ មិនថាចល័តកន្លែងណាទេ គឺក្នុងការដឹកនាំរបស់គាត់។

**ស៖** តាមពិតនៅពេលដែលអ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោកហៅត្រពាំងថ្ម*ដាម* ថាជាទំនប់របស់ តាវ៉ាល់។ តើហ្នឹងជាពាក្យដែលលោកបាននិយាយបែបហ្នឹងប្រាប់គេទេ?

**ឆ៖** បាទ គឺទំនប់នោះគឺបងប្អូនតំបន់៥ យើងទាំងអស់ គេហៅតំបន់៥ គឺខេត្តបន្ទាយមានជ័យ អ្នកណាមួយក៏គេដឹងថា ទំនប់នោះជាទំនប់របស់ តាវ៉ាល់ គឺ តាវ៉ាល់ គាត់អ្នកការគ្រប់គ្រងទាំងអស់។ គាត់អ្នកដឹកនាំចល័តឲ្យលើក មិនថាទំនប់តាមប្រឡាយយើងព្រៃមាន់នេះទេ គឺជាទំនប់ តាវ៉ាល់។ កន្លែងទីណាគឺរបស់ តាវ៉ាល់ ទាំងអស់។

**ស៖** លោកសាក្សី ឥឡូវនេះយើងនិយាយបន្តិចអំពី តាវ៉ាល់។ លោកខ្លួនឯងក៏បានរៀបរាប់ពីគាត់ថា ជាមនុស្សដាច់ខាត។ តាមអ្វីដែលលោកចាំ តើ តាវ៉ាល់ ជាមនុស្សកាចឃោរឃៅ ឬក៏ជាមនុស្សស្លូតបូត ឬសុភាពរាបសា?

**ឆ៖** មនុស្ស តាវ៉ាល់ នេះគឺក៏មនុស្សគាត់កាចណាស់ គឺសម្ដីគាត់គឺកាច អ្នកណាក៏មិនហ៊ានមើលមុខគាត់ទេ គាត់កាច។ ឲ្យតែខុសគឺ ឲ្យតែគាត់ខុសហើយ ឲ្យគាត់ដឹងហើយ គឺអត់មានពិបាកនេះទេ គឺឲ្យយកទៅវ៉ៃចោលភ្លាម បានប្រជាជនខ្លាចគាត់។

[១១:២៧:៣២]

**ស៖** លោកសាក្សីយោងទៅរកបញ្ហាមួយចំនួនដែលថា មនុស្សមួយចំនួនដែលគាត់ស្គាល់ តាវ៉ាល់ នោះគាត់បាននិយាយពី តាវ៉ាល់ នេះ។ គឺបុគ្គលម្នាក់ដែលហៅ តាវ៉ាល់ នោះថាជាមនុស្សឃោរឃៅចិត្តអាក្រក់ គាត់ពូកែដាក់ទោសអ្នកដទៃ គាត់ជាឃាតករ ជាមនុស្សដែលកាចសាហាវណាស់។ តើលោកយល់ស្របជាមួយសម្ដីនេះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

គឺថាសាក្សីគាត់បានផ្ដល់សក្ខីកម្មផ្ទាល់របស់ខ្លួនគាត់ហើយ អំពីបញ្ហានេះ។ បើសិនជាមេធាវីចង់យោងទៅឯកសារផ្សេង គប្បីតែកំណត់អត្តសញ្ញាណឯកសារនោះ ជាជាងគាត់ផ្ដល់ការរៀបរាប់របស់បុគ្គលផ្សេងឲ្យសាក្សីនេះស្ដាប់។ អ៊ីចឹងគឺថា ជាពិសេសជាចាំបាច់ គឺថាត្រូវបង្ហាញនូវអត្តសញ្ញាណឯកសារនោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** មិនបញ្ហាទេលោកចៅក្រម។ នៅពេលដែលខ្ញុំនិយាយថា គាត់ពូកែដាក់ទោសនោះគឺថាឯកសារ E3/8991 ដែលថាគាត់ជាមនុស្សឃោរឃៅ គ្មានមេត្តានេះជាដើមនោះ។ ខ្ញុំមិនបញ្ជាក់ឈ្មោះបុគ្គលដែលនិយាយបញ្ហានេះនៅឡើយទេ។ អង់គ្លេស 00969903, ខ្មែរ 00736232។ នៅពេលដែលខ្ញុំនិយាយថា តាវ៉ាល់ ជាឃាតករនោះគឺយោងទៅរកE3/805 អង់គ្លេស 00277815, ខ្មែរ 00267743។ ហើយសាក្សីមួយទៀតហៅថា តាវ៉ាល់ នេះជាជនឃោរឃៅ ហើយ E3/902 អង់គ្លេស 0-- ហើយខ្ញុំនឹងជូនខ្មែរពេលក្រោយជា ERN។ នេះគឺជាការរៀបរាប់ពីអត្តចរិតរបស់ តាវ៉ាល់ តើលោកយល់ស្របជាមួយសម្ដីរបស់សាក្សីទាំងអស់នេះ ដែលគេរៀបរាប់ពី តាវ៉ាល់ ដែរឬទេ?

[១១:៣០:៣១]

**លោក ឡូត ស្លួយ៖**

**ឆ៖** បាទ តាមដែលខ្ញុំឃើញគាត់និយាយស្ដី ហើយនិងគាត់ធ្វើការនេះ គឺគាត់កាចណាស់ គឺខុសអត់បានទេ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះឈប់ក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សារបស់គាត់ មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:២៨ នាទី)*

[១៣:២៨:៤៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការជាបន្តទៀត។ អង្គជំនុំជម្រះផ្ដល់វេទិកាដល់

មេធាវីការពារក្តីលោក នួន ជា តាំងសំណួរទៅសាក្សីជាបន្តទៀត។

សូមអញ្ជើញ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោកចៅក្រម លោក លោកស្រីសហការីទាំងអស់គ្នា។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី! មុនពេលសម្រាកពិសាបាយថ្ងៃត្រង់ ខ្ញុំបានសួរលោកអំពី តាវ៉ាល់។ មុននឹងសួរគាត់អំពីការចាប់ខ្លួនគាត់នេះ ខ្ញុំសូមសួរលោកពាក់ព័ន្ធទៅនឹង តាវ៉ាល់។ តាមការចងចាំរបស់លោក តើ តាវ៉ាល់ ជាបញ្ញវន្ត ឬមិនមែនទេ?

[១៣:៣០:២៣]

**លោក ឡុត សួយ៖**

**ឆ៖** តាវ៉ាល់ ដែលខ្ញុំដឹង ដូចគេថា ឲ្យតែពេលពាយ័ព្យគឺលំបាក។ អ្នកបញ្ញវន្ត ឬអ្នកល្ងង់អីទេ ឲ្យតែអ្នកធំ គឺគេចាប់ៗយកទៅទាំងអស់។

**ស៖** ខ្ញុំខ្លាចក្រែងខ្ញុំស្តាប់តាមរយៈការបកប្រែវាមិនច្បាស់ ខ្ញុំរៀបសំណួរឡើងវិញ។ តាមការចងចាំរបស់លោក តើ តាវ៉ាល់ ផ្ទាល់នេះជាបញ្ញាជន ឬក៏មិនមែនទេ?

**ឆ៖** បញ្ញាជនម៉េច? និយាយអីចេះ ខ្ញុំអត់ស្គាល់ផង។

**ស៖** លោកចង់ថាយ៉ាងម៉េចដែលថា លោកអត់ស្គាល់ផងហ្នឹង? លោកបានធ្លាប់បាននិយាយជាមួយ តាវ៉ាល់ ធ្លាប់បានឃើញគាត់។ តើជំនាញរបស់គាត់ពីមុននោះ អាជីពរបស់គាត់ពីមុននោះជាអ្វីដែរ? តើគាត់ជាអ្នករៀនសូត្រចេះដឹង ជាបញ្ញាជន ឬក៏មិនមែនទេ?

**ឆ៖** រយៈកាលកន្លងមក ដែលៗខ្ញុំស្គាល់គាត់នេះ គឺមិនមែនគាត់នៅស្រុកកំណើតនោះទេ ហើយខ្ញុំក៏មិនដឹងថាគាត់ចេះ ឬគាត់មិនចេះទេ។

**ស៖** តើលោកដឹងថា ពីមុនមក គាត់ធ្លាប់ធ្វើជាគ្រូបង្រៀនដែរឬក៏អត់ទេ?

[១៣:៣២:៤១]

**ឆ៖** ព្រោះរយៈកាលកន្លងមក ព្រោះខ្ញុំស្គាល់គាត់នេះ គឺស្គាល់គាត់ដោយសារដែលគាត់ក្តាប់ទ័ពបានឮ។ បានខ្ញុំចូលទៅនៅជាមួយកងពួកគាត់ គេហៅ “តាវ៉ាល់ៗ” បានខ្ញុំឃើញគាត់ បានខ្ញុំស្គាល់គាត់ថា “អំនេះតើ តាវ៉ាល់!”។ ហើយរឿងការ ដែលការដែលគាត់ចេះដឹងនោះ គឺខ្ញុំអត់បានដឹងដល់ទេ ហើយ

មិនដែលឃើញគាត់សរសេរផង។

**ស៖** តើលោកដឹងថា គាត់ចេះនិយាយបារាំងទេ?

**ឆ៖** បាទ ពីសម័យនុ៎ង គឺយើងនិយាយភាសាបរទេស គឺយើងនិយាយអត់បានទេ។ សូម្បីតែធំប៉ុនណា ក៏អ្នកធំត្រូវសម្លាប់អ្នកធំតែគ្នាឯង មានតែលាក់បំពួន។ ចេះធ្វើជាមិនចេះ បានយើងអាចរស់នៅបានយូរ។

**ស៖** ខ្ញុំនឹងត្រឡប់មកចំណុចដែលលោកកំពុងនិយាយនេះ បន្តិចទៀតនេះ។ ចុះ តាហ៊ីង្ស ប្រធានតំបន់៥ គាត់ជាបញ្ញាជនដែរ ឬក៏អត់ទេ?

**ឆ៖** អានោះខ្ញុំ ដូចខ្ញុំជម្រាបអ៊ីចេះ ថាខ្ញុំអត់ស្គាល់ទេ ព្រោះខ្ញុំស្គាល់តែឈ្មោះ ស្គាល់តែរូប ប៉ុន្តែរឿងការចំណេះចេះដឹងរបស់គេ គឺខ្ញុំអត់ដឹងថា គេចេះដល់កម្រិតណា ឬល្ងង់ដល់កម្រិតណាទេ។

**ស៖** ដូច្នេះលោកមិនដឹងថា គាត់ជាសាស្ត្រាចារ្យ អាចនិយាយភាសាបារាំងបានស្ទាត់ជំនាញ ឬក៏អត់នោះ គឺថាលោកមិនដឹងទេ។ តើអ៊ីចឹងមែនឬទេ?

[១៣:៣៤:៥៥]

**ឆ៖** បាទ គឺភាសាទាំងនោះ គឺខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំមិនដែលបានទៅនៅថា រួមរក្សបម្រើគាត់ បានខ្ញុំមិនដែលដឹងថាគាត់ចេះ ឬក៏គាត់ល្ងង់។

**ស៖** លោកសាក្សី ខ្ញុំក៏នឹងមកសួរលោកអំពីចំណុចនេះឡើងវិញដែរ។ ឥឡូវនេះ ខ្ញុំសូមអានសម្រង់មួយចេញអំពីចម្លើយរបស់សាក្សីម្នាក់ ដែលយើងនឹងស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះ ឆាប់ៗនេះ។ ជម្រាបជូនអង្គជំនុំជម្រះ សាក្សីនេះគឺឈ្មោះ TC រហស្សនាម TCW-918 ឯកសារ E3/9094 ERN ជាភាសាអង់គ្លេស 00728657, ខ្មែរ 00734053។ សាក្សីរូបនេះ ត្រូវបានអ្នកស៊ើបសួរសួរអំពីតាហ៊ីង្ស ហើយខ្ញុំសូមអានចម្លើយរបស់គាត់សួរមើល ថាតើលោកយល់យ៉ាងម៉េចដែរ។ “តាហ៊ីង្ស តើតាហ៊ីង្ស ជាអ្នកណា?” សាក្សីឆ្លើយថា៖ “គាត់ជាបញ្ញវន្តជាន់ខ្ពស់ បញ្ញវន្តកំពូល។ គាត់មកពីណា? គាត់មកពីតាកែវដែរ។ តើគាត់រៀនសូត្រនៅឯណា? ខ្ញុំមិនដឹងថាគាត់បានទទួលការរៀនសូត្រនេះពីណាទេ ប៉ុន្តែគឺថាគាត់និយាយថា គាត់គឺជាអ្នកចេះដឹងកំពូល មិនមែនជាមនុស្សអវិជ្ជាទេ មនុស្សល្ងង់ខ្លៅទេ។ និស្សិតនិងបញ្ញវន្តទាំងអស់ដែលផ្ញើចេញពី បញ្ជូនពីភ្នំពេញត្រូវដាក់នៅកងចល័ត ហើយត្រូវបានគេហៅឲ្យចូលរួមប្រជុំ”។ ហើយទំព័របន្ទាប់ជាភាសាអង់គ្លេស “នៅពេលណាបញ្ញវន្តមកដល់គាត់ហៅពួកគេឲ្យចូលរួមប្រជុំ ហើយគាត់និយាយបានល្អណាស់ ដូចជាអ្នកចេះដឹងខ្លាំងណាស់”។

តាមរយៈ មានសម្រង់មួយពីសាក្សីម្នាក់ទៀត ដែលក៏នឹងត្រូវផ្តល់សក្ខីកម្មនៅពេលខាងមុខដែរ TCW-937 ចម្លើយរបស់គាត់ គឺអាចរកឃើញនៅ E305/13/2/6 ERN--

[១៣:៣៧:៥០]

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន មេធាវីអានលេខឯកសារញាប់ពេក តាមអត់ទាន់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ សូមលោកអានលេខយោងអម្បាញ់មិញនេះម្តងទៀត អ្នកបកប្រែមិនអាចបកប្រែទាន់ទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកចៅក្រម ឡាវែន៍ ខ្ញុំនឹងផ្តល់។

**ស៖** គឺ E305/13.23.306 ERN អង់គ្លេស 00731123 ដល់ 24, ខ្មែរ 0072897 *(ស៊ីក)* ដល់ 98។ សាក្សីរូបនេះគឺ មានលេខសម្ងាត់ TCW-937 គេបានសួរសាក្សីរូបនេះ ឲ្យរៀបរាប់អំពីឈ្មោះ តាវ៉ាល់ ហើយគាត់បានឆ្លើយចំណុចមួយថា គាត់ តាវ៉ាល់ គឺថាចិត្តអាក្រក់ណាស់ គឺថាគាត់មកពីកំពង់ចាម រាងស្គម រាងស្តើង ហើយក៏គេបានសួរអំពីសក់របស់គាត់ មិនចំណាប់អារម្មណ៍ទេ។ ប៉ុន្តែចំណុចខាងក្រោមគឺដូចតទៅ សាក្សីឆ្លើយថា៖ "គឺថាគាត់ជាមនុស្សដាច់ខាត យោងទៅតាមអត្តចរិតរបស់គាត់ និងសម្តីរបស់គាត់ គឺថាគាត់អាចធ្លាប់ធ្វើជាគ្រូបង្រៀន។ ធ្លាប់ធ្វើជាគ្រូបង្រៀន? បាទពីព្រោះគាត់ធ្លាប់និយាយភាសាបារាំងជាមួយ តាហ៊ីង្ស។ តាហ៊ីង្ស ជាសាស្ត្រាចារ្យចេញពីភ្នំពេញ។ តើគាត់និយាយភាសាបារាំងដែរអត់ទេ ពេលជួប តាហ៊ីង្ស? គាត់និយាយបារាំងជាមួយ តាហ៊ីង្ស ពេលជួបគ្នា។ តើលោកធ្លាប់ឮសួរគាត់និយាយភាសាបារាំងជាមួយ តាហ៊ីង្ស ទេ? បាទ ពួកគាត់និយាយបារាំង ពេលខ្លះខ្ញុំដើរពីខាងក្រោយគាត់ ពេលគាត់មើលប្រជាជនកសាងទំនប់។ ប្រសិនណាជាគាត់អត់ចង់ឲ្យគេស្តាប់អីបានទេ ពួកគាត់ទាំងពីរហ្នឹងគឺថានិយាយភាសាបារាំងជាមួយគ្នា។" ហើយក្រោមមកទៀត៖ "តាវ៉ាល់នេះគឺថាជាសាស្ត្រាចារ្យដែលចេញពីភ្នំពេញ"។

ក្រោយពីខ្ញុំអានសម្រង់នៃចម្លើយសាក្សីរូបនេះ តើវាអាចជួយរំឭកការចងចាំ ឬធ្វើឲ្យលោកផ្លាស់

ប្តូរចម្លើយរបស់លោកទេ? បាទ ខ្ញុំសូមដកសំណួរនេះឡើងវិញ។ លោកសាក្សី តើលោកយល់ថាម៉េច ដែរ ចំពោះសម្រង់ដែលខ្ញុំទើបអានឲ្យស្តាប់អម្បាញ់មិញនេះ?

[១៣:៤០:៤៤]

**លោក ឡុត សួយ៖**

**ឆ៖** រឿងការងារដែលគិតចេះដឹងនេះ គឺខ្ញុំដាច់ខាតថា ខ្ញុំអត់បានដឹង ហើយមិនដែលឮ។ និយាយរួមទៅគឺខ្ញុំមិនដែលបានថា ជិតគាត់ផង។ មិនដែលដឹងថាគាត់អ្នកចេះផង។

**ស៖** បាទ អ៊ីចឹង ខ្ញុំសួរចង់ដឹងប្រតិកម្មបន្ថែមទៅទៀត គឺមានសម្រង់ចេញពីចម្លើយឯកសារ E3/9004 ERN ជាភាសាអង់គ្លេស 00984978, ខ្មែរ 00730602។ អ្វី យ៉ាងហោចណាស់ក៏ជាការបកប្រែជាភាសាអង់គ្លេសនេះ អ្នកស៊ើបអង្កេតមជ្ឈមណ្ឌលឯកសារកម្ពុជាបានសួរទៅសាក្សីរូបនេះ សួរអំពីឈ្មោះ តាវ៉ាល់។ ហើយសព្វថ្ងៃ គាត់ជាគឺថា -- គឺត្រូវបានជំរុញឲ្យគាត់ឆ្លើយដូចតទៅ៖ "ខ្ញុំមិនប្រាកដទេ ដោយសារថាពួកគាត់ធ្វើជាកងទ័ពទាំងអស់គ្នា ក្រោយគេចាប់ តាម៉ាន់ និង តាវ៉ាល់ គឺថាពួកគេបានរត់គេចខ្លួនចេញពីនេះ ហើយទៅលាក់ខ្លួននៅក្នុងព្រៃ។ គាត់ឈ្មោះអី? គាត់ឈ្មោះ ឡុត សួយ ឈ្មោះ ឡុត សួយ គាត់ធ្វើជាកងទ័ពទាំងអស់គ្នា។ ខ្ញុំមិនបានសួរពីការចាប់ខ្លួនអំពីថ្ងៃខែនៃការចាប់ខ្លួន តាវ៉ាល់ ទេ។ ខ្ញុំមិនចាំខែឆ្នាំចាប់ខ្លួននោះទេ។ តើ ឡុត សួយ នេះនៅជាមួយ តាម៉ោង, តាស៊ន ហើយនិង តាវ៉ាល់ ឬក៏អត់ទេ? គាត់នៅជាមួយអ្នកទាំងនោះ។" សម្រង់មួយនេះហាក់បញ្ជាក់ថា តាម៉ោង, តាវ៉ាល់, តាស៊ន គឺថាស្គាល់គ្នានៅក្នុងពេលធ្វើកងទ័ព ហើយស្នាក់នៅជាមួយគ្នា តើត្រឹមត្រូវអ៊ីចឹងមែនទេ?

[១៣:៤៣:២០]

**ឆ៖** បាទ ពេលនោះខ្ញុំអត់បានរស់នៅជាមួយគាត់ទេ។ គាត់ -- គ្រាន់តែនៅជាកូនចៅរបស់គាត់ ប៉ុន្តែខ្ញុំនៅកន្លែងផ្សេង គាត់នៅនឹងជប់ ពួកខ្ញុំនៅភ្នំលៀប។

**ស៖** តាមរយៈសម្រង់នេះ វាមិនច្បាស់លាស់អីនោះទេ។ ប៉ុន្តែលោកនៅនឹកឃើញឈ្មោះ តាម៉ាន់ ទេ?

**ឆ៖** តាម៉ាន់ ខ្ញុំមិនដែលឮទេ។ បើ តាម៉ោង មែនបានខ្ញុំដែលឮ។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅសួរអំពីការចាប់ខ្លួន តាម៉ោង, តាវ៉ាល់ ហើយនិងអ្នកដទៃទៀត ខ្លះៗ។ លោកបានឆ្លើយចំពោះអ្វីដែលកើតឡើងនៅការដ្ឋានទំនប់ត្រពាំងថ្ម លោកនិយាយអំពីស្ថានភាពការងារ លក្ខខណ្ឌការងារ និយាយអំពីអនាម័យ និងការទទួលខុសត្រូវរបស់ តាវ៉ាល់។ លោកពេលហ្នឹង

លោកសប្បាយចិត្តទេលោក ពេលឮសួរថាគេចាប់ខ្លួន តាវ៉ាល់?

**ឆ៖** ពេលដែលចាប់ខ្លួនពួក តាវ៉ាល់ ពួកខ្ញុំអ្នកក្រោមនេះ ក៏នាំគ្នាភ័យ ហើយនិងពិគ្រោះគ្នានឹងរត់ចូលព្រៃ ព្រោះគេចាប់បាន គេយកទៅៗសម្លាប់ចោល។ បានពួកខ្ញុំប្រុងប្រយ័ត្នខ្លួនមិនឲ្យគេហៅបាន។

**ស៖** លោកសាក្សី ខ្ញុំចង់ស្វែងរកឲ្យឃើញ តើចង់ដឹងថាតើ តាវ៉ាល់ នេះជាមនុស្សកាចកំណាញ់ ជាឃាតករ ដោយសារចុងក្រោយ គាត់ត្រូវបានគេចាប់ខ្លួន ហើយជោគវាសនារបស់លោកក៏អាចប្រឈមនឹងការចាប់ខ្លួនដែរ វាមូលហេតុអីបានជាលោកថាលោកអាចនឹងប្រឈមនឹងការចាប់ខ្លួនដែរនោះ?

[១៣:៤៥:៥៩]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់ឆ្លើយ!

អញ្ជើញលោកសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សំណួរនេះ គឺសួរចង់បានព័ត៌មានស្ដីអំពីអង្គហេតុមួយចំនួនហាក់បីដូចជាចូលរួមនៅក្នុងពាក់ព័ន្ធទៅមូលហេតុនៃការចាប់ខ្លួនសាក្សីរូបនេះ។ ហើយសួរទៅ តាវ៉ាល់ គួរតែសួរថា តាវ៉ាល់ ចាប់ខ្លួនមូលហេតុអីនៅត្រពាំងថ្មហ្នឹង? តើមានអ្វីអះអាង? តាវ៉ាល់ អនុវត្តការ -- ការអនុវត្តគោលនយោបាយលើកទំនប់ត្រពាំងថ្មនេះ គឺថាអនុវត្តតាមគោលនយោបាយទេ ឯរឿងការចាប់ខ្លួន តាវ៉ាល់ ជារឿងមួយផ្សេង។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ស្របជាមួយសហព្រះរាជអាជ្ញា ដែលថាហេតុផលចម្បងនៃការចាប់ខ្លួននេះ គឺអាចដោយសារតែមូលហេតុផ្សេង។ ប៉ុន្តែខ្ញុំយល់ថាខ្ញុំមានសិទ្ធិសួរសំណួរបែបនេះទៅសាក្សី បើគាត់អាចពន្យល់មកយើង ថាហេតុអ្វីពេលហ្នឹង គាត់ក៏ហាក់ដូចជាមិនមានការធូរចិត្ត គឺថាមិនមានការធូរស្រាលក្នុងចិត្ត ដោយសារថាមេឃាតករនោះត្រូវបានគេចាប់ខ្លួន ហើយជាមេរបស់គាត់ហ្នឹង។

**ប្រធានអង្គជំនុំ៖**

សូមមេធាវីសួរឲ្យច្បាស់ ដើម្បីសាក្សីងាយស្រួលឆ្លើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំនឹងបំបែកសំណួរខ្ញុំនេះទៅជាពីរ។ លោកសាក្សី ហេតុអ្វីក៏លោកមិនមានការធូរស្រាល នៅក្នុងចិត្តនៅពេលដែល តាវ៉ាល់ ចុងក្រោយត្រូវបានគេចាប់ខ្លួន? ហេតុម៉េចក៏លោកមិនៗធូរស្រាលក្នុង ចិត្តទៅវិញ?

**លោក ឡុត សួយ៖**

**ឆ៖** ដែលព្រោះខ្ញុំមិនធូរចិត្តនេះ គឺភូមិភាគពាយ័ព្យនេះ ឲ្យតែកងទ័ពគេចាប់យកទៅដាក់គុក គេចាប់យកទៅសម្លាប់ចោលអស់។ បាននៅសល់ពួកខ្ញុំចំនួន៩០នាក់នេះ ដែលនៅក្នុងព្រៃកូនខ្លែងនេះ។ បានពួកខ្ញុំភ័យខ្លួនខ្លាចគេដឹង។ បានចាប់ពួក តាវ៉ាល់ ហើយនេះ បានដល់ចាប់ដល់ពួក តាណាក, តាហាត់ ក្រោយនេះ បានពួកខ្ញុំកាន់តែភ័យ។

**ស៖** ប៉ុន្តែលោកសាក្សី យើងបានស្តាប់ឮពីលោកព្រឹកមិញនេះគឺថា លោកត្រូវគេបានគេបង្ខំឲ្យ ចូលធ្វើជាកងទ័ព លោកត្រូវតែគោរពតាមបញ្ជា បើមិនដូច្នេះទេ គេនឹងសម្លាប់លោកចោល។ លោកគ្មាន អ្វីដែលត្រូវភ័យខ្លាចនោះទេ។ តើពិតទេ?

**ឆ៖** ខ្ញុំឆ្លើយអត់ -- ស្តាប់អត់បានច្បាស់ផង។

[១៣:៤៩:២២]

**ស៖** លោកបានឆ្លើយថា លោកត្រូវបានគេបង្ខំឲ្យចូលធ្វើជាកងទ័ពខ្មែរក្រហម ហើយលោកចេះ តែធ្វើតាមបញ្ជាទៅ បើមិនធ្វើតាមទេ គេនឹងសម្លាប់លោកចោល។ ហើយ តាវ៉ាល់ គឺជាឃាតករដ៏ សាហាវម្នាក់។ គាត់ក៏ត្រូវបានគេចាប់ខ្លួន។ ហេតុអ្វីក៏លោកនេះក៏ភ័យខ្លាចគេចាប់ខ្លួនដែរ? ខ្ញុំអត់យល់ មូលហេតុអីលោកភ័យខ្លាចគេចាប់ខ្លួនដែរ?

**ឆ៖** បាទ ដែលពួកខ្ញុំភ័យគេចាប់ខ្លួននេះ គឺពួកខ្ញុំជាអ្នកភូមិភាគពាយ័ព្យ ជាអ្នកតំបន់៥។ ម្ល៉ោះ ហើយភូមិភាគនិរតីដែលគេមកនៅទឹកដីភូមិភាគតំបន់៥នេះ នៅតំបន់៥នេះសុទ្ធតែនិរតី។ កងទ័ព ពាយ័ព្យក៏បានរំលាយចោលអស់។ បាននៅសល់តែពួកខ្ញុំចំនួន៩០នាក់នេះ ដែលនៅក្នុងព្រៃកូនខ្លែងនេះ។

**ស៖** ឥឡូវ ខ្ញុំសូមសួរសំណួរតាមរបៀបផ្សេងវិញ ហើយខ្ញុំនឹងចូលទៅប្រធានបទថ្មី។ តើខ្លួន លោកផ្ទាល់គឺថា ជាមនុស្សដែលកាចសាហាវព្រៃផ្សៃដូច តាវ៉ាល់ ដែលជាឃាតករសាហាវព្រៃផ្សៃដែរ ទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

មិនមានមូលដ្ឋានអ្វីដែលត្រូវតាំងសំណួរបែបនេះមកកាន់សាក្សីទេ។ នេះជាវា ៗគ្រាន់តែទៅលើតែការសន្និដ្ឋានគួរឲ្យចង់សើចទេ។ ប៉ុល ពត, នួន -- ពួក ប៉ុល ពត, នួន ជា ជាអ្នកចាប់ តាវ៉ាល់ ទោះតាវ៉ាល់ ជាមនុស្សកាចសាហាវព្រៃផ្សៃយ៉ាងម៉េចក៏ដោយ។ បើសិនណាជាចង់សួរអំពីបញ្ហាអង្គហេតុគឺមិនជាថ្វីទេ ត្រឹមត្រូវហើយ ប៉ុន្តែបើការសួរបែបនេះមិនត្រឹមត្រូវទេ។

[១៣:៥១:៣៩]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំថាសំណួរនេះក៏ជាសំណួរពាក់ព័ន្ធអង្គហេតុដែរ បើគ្រាន់តែសួរថា តើលោកក៏ជាមនុស្សកាចសាហាវព្រៃផ្សៃដែរ? បើគាត់ថា អត់ទេៗ នេះក៏ជាអង្គហេតុដែរ។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីបន្តប្រធានបទថ្មីបន្តទៀត សួរសាក្សី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ឥឡូវនេះខ្ញុំចូលទៅសួរមូលហេតុអ្វីបានជាលោកភ័យខ្លាចគេចាប់ខ្លួនលោកដែរនោះ? ឥឡូវនេះនិយាយអំពីការលាក់អាវុធដែលលោកបានលើកឡើងពីមុននេះ។ តើលោកនៅនឹកឃើញទេថា អាវុធប្រភេទណាដែរដែលត្រូវបានគេយកទៅលាក់ទុកនៅក្នុងព្រៃនោះ?

**លោក ឡុត ស្វយ៖**

**ឆ៖** ប្រភេទដែលលាក់អាវុធនេះ គឺមិនមែនលាក់ជីកកប់ទេ គឺកងទ័ពតំបន់ដែលគេយកគ្រឿងអាវុធគេនេះមកទុកក្នុងព្រៃ ក៏ទ័ពកម្លាំងទ័ពគេបោះជំរំនៅក្នុងព្រៃកូនខ្លែង។ គឺអាវុធ គឺដូចជាពួកអាហុកអាប៉ែតរបស់គេ គេតាំងកាំភ្លើងធំរបស់គេ។ អានោះឯងបានដែលខ្ញុំនិយាយថា ការលាក់អាវុធ និងការលាក់ខ្លួនរបស់ពួកគេនោះ។

**ស៖** បាទ ច្បាស់ហើយលោកសាក្សី ប៉ុន្តែសំណួរខ្ញុំគ្រាន់តែសួរថា អាវុធទាំងអស់នោះជាអាវុធប្រភេទណា? សុទ្ធតែជាអាវុធស្វ័យប្រវត្តិ អាវុធធុនធ្ងន់ ឬក៏យ៉ាងណា? សូមលោកពន្យល់បន្តិចមក។

[១៣:៥៣:៤៩]

**ឆ៖** អាវុធដែលគេយកមកនោះ គឺមានអាប៉ែតក៏មាន កាំភ្លើងដៃរបស់គេ គេកាន់គ្រប់ដៃ ហើយនិងអាហុករបស់គេ។ បានគេមកនៅលាក់ខ្លួននៅក្នុងព្រៃនោះ ព្រៃកូនខ្លែងនេះចំនួនរយៈកាលកន្លះខែ បានគេដកទៅនៅស្វាយវិញ បានគេយកកាំភ្លើងរបស់គេចូលទៅស្វាយវិញ។ ពេលនោះក៏ពួកនិរតីក៏ល្បួងលោម អប់រំ ក៏បានចាប់បានទាំងអស់ ដកអាវុធនោះយកបានទៅវិញទាំងអស់។

**ស៖** តើអាវុធទាំងអស់នេះមានប្រភពដើមចេញមកពីណាដែរ?

**ឆ៖** អារឿងដើមចេញ ខ្ញុំអត់ដឹងទេ ដឹងតែគេ ទ័ពគេចេញទៅពីស្វាយហ្នឹងឯង។

**ស៖** តើលោកធ្លាប់ឮអាវុធ គ្រាប់រំសេវ ដែលមានចំនួនរាប់ពាន់ដើម ដែលរឹបអូសបានពីទាហាន លន់ នល់ នៅក្នុងខែមេសា ១៩៧៥ ដែរទេ ហើយដែលក្រោយមកគេយកទៅលាក់ខ្លួននៅក្នុងព្រៃ? លោកដែលដឹងរឿងនេះទេ?

**ឆ៖** បាទ រឿងហ្នឹងខ្ញុំដឹងអត់ដល់ ព្រោះខ្ញុំនៅក្មេងណាស់។ ខ្ញុំដឹងថាពេលដែលខ្ញុំចាប់ផ្តើមដែលធ្វើកងចល័តនឹងគេហើយ ខ្ញុំបាននិងធ្វើទ័ពជាមួយគេ រយៈកាលក្រោយមកទេ។

**ស៖** ចុះអាវុធដែលលោកស្គាល់នេះ តើលោកឮ ឬក៏លោកដឹងជាលើកដំបូងអំពីអាវុធនេះ ត្រូវគេយកទៅលាក់នៅក្នុងព្រៃហ្នឹង ឮលើកដំបូងនៅពេលណាដែរ?

**ឆ៖** នៅពេលដែលមុននិរតីចូលមកទៅជាន់ដីភូមិ -- ទៅជាន់នៅតំបន់៥នោះ មុនពេលនិរតីចូលដល់។

[១៣:៥៦:២៥]

**ស៖** តើលោកៗដឹងថាហ្នឹង អាវុធហ្នឹងត្រូវបានគេលាក់តាំងពីមុនពេលខាងនិរតីទៅដល់ភូមិភាគពាយ័ព្យហ្នឹង អ៊ីចឹងមែនឬក៏អត់ទេ?

**ឆ៖** បាទ មុនពេលនិរតីដែលគេចាប់ តាញឹម បានភ្លាម ក៏ពួកតំបន់គេដឹងខ្លួនគេ គេចេញទៅនៅព្រៃ យកអាវុធទៅទុកក្នុងព្រៃ។

**ស៖** សំណួរខ្ញុំសួរថា តើលោកហើយនិងអ្នកដទៃខ្លះទៀតនោះ ថាមុនពេលកម្មាភិបាលភូមិភាគនិរតីទៅដល់ភូមិភាគពាយ័ព្យហ្នឹង – ខ្ញុំសួរឡើងវិញ លោកដឹងថាអាវុធទាំងអស់នេះ គេៗបានយកទៅលាក់ទុកហ្នឹងតាំងពីមុនខាងភូមិភាគនិរតីទៅដល់ពាយ័ព្យម្ល៉េះ ឬក៏យ៉ាងណា?

**ឆ៖** អាវុធដែលគេយកទៅនេះ គឺមុនពួកនិរតីចូលដល់ពាយ័ព្យ។

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលថាជំហររបស់សហព្រះរាជអាជ្ញាគឺថា អាវុធទាំងអស់នោះមាន

នៅទីនោះហើយ គឺអាវុធនេះគឺដើម្បីការពារខ្លួនពីការចាប់ខ្លួនរបស់ភូមិភាគនិរតី គឺមិនត្រឹមត្រូវទេ។ គ្រាន់ខ្ញុំសួរថា អាវុធហ្នឹងបានយកទៅលោកទុកជាដំបូងហ្នឹងគឺនៅពេលណា?

**ឆ៖** នៅមុនៗពេលដែលនិរតីចូលទៅដល់តំបន់៥ នោះ។

[១៣:៥៩:០២]

**ស៖** ខ្ញុំខ្លាចតែខ្ញុំទទួលចម្លើយមកបានមិនច្បាស់លាស់ទេ ខ្ញុំនឹងបន្តទៅមុខទៀត ពីព្រោះខ្ញុំមានសំណួរច្រើនណាស់។ ខ្ញុំនឹងបន្តទៅមុខលោកសាក្សី។ ខ្ញុំសុំចូលទៅនិយាយសួរអំពីក្រដាសប្រាក់ ហើយនិងលុយកាក់។ មុនពេលឈប់សម្រាកបាយថ្ងៃត្រង់ លោកបានឆ្លើយថា "ពេលណាដែលលោកឃើញក្រដាសប្រាក់ហ្នឹង? ហើយក្រដាស់គេបោះពុម្ពនៅពេលណា?" លោកឆ្លើយថា "២ខែមុនពេលវៀតណាមចូលមកដល់។" យើងដឹងថាកងទ័ពវៀតណាមគឺនៅ ចុះមកចុងឆ្នាំ៧៨ និងដើមឆ្នាំ១៩៧៩។ ប៉ុន្តែចម្លើយរបស់លោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជាថា តាញឹម ខ្លួនឯងផ្ទាល់ គឺជាអ្នកបានចូលរួមចេញក្រដាសប្រាក់នេះ។ ហើយ តាញឹម ត្រូវបានចាប់ខ្លួននៅក្នុងខែឧសភា ១៩៧៨។ ហើយក្នុងចម្លើយរបស់លោក លោកឆ្លើយថា ភ្លាមៗក្រោយពីការចេញប្រកាសក្រដាសប្រាក់នេះ គឺថាកម្មាភិបាលមួយចំនួនក៏ត្រូវបានគេចាប់ខ្លួន។ តើវាអាចនៅក្នុងខែឧសភា ឬក៏ -- ឧសភា ឬមិថុនា ៧៨? តើលោកពិតប្រាកដថា ក្រដាសប្រាក់ហ្នឹង គឺចាប់ផ្តើមផ្សព្វផ្សាយនៅដើមឆ្នាំ១៩៧៨ មែន ឬក៏អត់ទេ?

**ឆ៖** ព្រោះក្រដាសប្រាក់នេះ គឺអត់មានអ្នកណាដឹងទេ ចេញមកទេ គឺសូម្បីតែប្រជាជនក៏អត់ទាន់ដឹងដែរ។ ដឹងតែទ័ពដែលគេបានមក ដែលគេយកមកមួយសន្លឹកនេះ គេប្រាប់ថា យើងត្រូវបើកប្រាក់ខែ។ បានខ្ញុំសុំគេមើលប្រាក់ហ្នឹង ថា "ប្រាក់ហ្នឹងប្រាក់អី?" គេថា "ប្រាក់គេបើក គេបម្រុងបើកឲ្យយើង"។ បានខ្ញុំមើលទៅថា បានឃើញរូបប្រាក់នោះ ជាសញ្ញាអ្នកច្រូតស្រូវ ហើយនិងអ្នកលីចប។

**ស៖** លោកសាក្សី មុននឹងចូលទៅសំណួរផ្សេងទៀត មើលទៅហាក់ដូចជាមិនទំនង ហើយខ្ញុំសួរថា តើអ្នកណាជាអ្នកចេញក្រដាសប្រាក់នេះ។ ពីមុនលោកនិយាយថា កម្មាភិបាលពាយ័ព្យជាអ្នកចេញក្រដាសប្រាក់នេះ។ នៅក្នុងចម្លើយរបស់លោកពីមុន លោកឆ្លើយថា តាញឹម ជាអ្នកចេញក្រដាសប្រាក់ហ្នឹង ជាលេខាភូមិភាគពាយ័ព្យ។ អ៊ីចឹងឥឡូវនេះ ខ្ញុំមិនច្បាស់ ខ្ញុំចង់សួរថាតើអ្នកណាជាអ្នកចេញក្រដាសប្រាក់ហ្នឹង? តើកម្មាភិបាលនិរតី ឬក៏ តាញឹម ជាអ្នកចេញក្រដាសបោះពុម្ពក្រដាសប្រាក់ហ្នឹង?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

[១៤:០២:១១]

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ហើយសូមឲ្យមេធាវីសួរសំណួរជាក់លាក់ ថាតើអ្នកណាជាអ្នកចេញក្រដាសប្រាក់ ពីព្រោះថាមានរឿងពីរដែលថា និយាយពីការបោះពុម្ពក្រដាសប្រាក់នេះ។ ថាតើគេសួរថាតើអ្នកណាជាអ្នកផ្ដល់ក្រដាសលុយនោះទៅពួកទាហាន។ អ៊ីចឹងសូមឲ្យមេធាវីសួរសំណួរឲ្យបានជាក់លាក់ពីបញ្ហានេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ។ ហើយបញ្ហានេះ វាហាក់ដូចជា បាទគឺលំបាក ហើយខ្ញុំនឹងប្រើពាក្យផ្សេង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើ តាញឹម ឲ្យក្រដាសប្រាក់នេះទៅយោធាហ្នឹង នៅពេលណា? តើទាហាន -- តើនៅពេលដែលលោកបានឃើញក្រដាសប្រាក់ហ្នឹង ឃើញនៅពេលណា បាទ ដោយនិយាយពីខែឆ្នាំមកនោះ?

**លោក ឡុត ស្វយ៖**

**ឆ៖** ក្រដាសប្រាក់ដែលឃើញនោះប្រហែលចូលក្នុងឆ្នាំយើងចិតសិប ចុងឆ្នាំ៧៧ហ្នឹងឯង ប៉ុន្តែប្រាក់នោះ អត់មែនថា មកបើកឲ្យទេ គឺបានដោយមួយសន្លឹក មិនដឹងថា គ្នាខ្ញុំនោះគេបានមកពីណាទេ។

[១៤:០៣:៤៥]

**ស៖** ឥឡូវនេះខ្ញុំដឹង ខ្ញុំប្រើថាចេញក្រដាសប្រាក់នេះ ជាជាងឲ្យផ្ដល់ឲ្យនេះ។ ហើយក្នុងជាសេចក្ដីដកស្រង់ លោកប្រធាន មកពីចម្លើយរបស់សាក្សី ហើយខ្ញុំនឹងសួរថា តើត្រឹមឬអត់។ នៅក្នុងឯកសារមណ្ឌលកម្ពុជាគឺ E3/9060 គឺ ERN 00728746, ខ្មែរ ERN 00733051។ គេសួរដំបូងពីគណៈប្រតិភូចិន ហើយលោកបាននិយាយថា៖ "អត់ទេ តាញឹម អត់ដឹងទេ គាត់បានធ្វើផែនការកែសម្រួលសង្គម ហើយគាត់និយាយថា គាត់ធ្វើផែនការឲ្យប្រជាជនមានជំនួញ។ ដូច្នេះហើយបានជាគេបោះពុម្ពលុយកាក់ ហើយគេបានបោះពុម្ពលុយ ហើយនិងប្រជាជនត្រូវផ្ដល់លក់ទំនិញ ឬក៏លក់ផលិតផលក្នុងសហករណ៍។" លោកសាក្សី នៅក្នុងចម្លើយរបស់លោកពីមុននោះ លោកនិយាយថា តាញឹម ជាអ្នកបោះពុម្ពលុយ ដើម្បីធ្វើជំនួញជាថ្មីឡើងវិញ។ តើការនេះធ្វើឲ្យលោកនឹកឃើញឡើងវិញដែរឬទេ?

**ឆ៖** បាទ ពេលនោះគឺតាមកងដែលពួក តាណាក គាត់នៅ គាត់ថាគេបម្រុងរៀបចំលក់តាម

សហករណ៍ ហើយពួកយើងនឹងបានចាយលុយ។ បានគាត់ថា ថ្នាក់លើគេនឹងបើកលុយឱ្យពួកកងទ័ព បានខ្ញុំថាថ្នាក់មានអ្នកណា មានតែពួក តាញ៉ឹម ហើយនិងថ្នាក់លើនៅតាមទីក្រុងភ្នំពេញ។

**សះ** តើលោកចាំថាលោក -- តើលោកឮដោយខ្លួនឯងដែរឬទេថា តាញ៉ឹម គាត់នឹងត្រូវបើកប្រាក់ឱ្យ ឬក៏ផ្តល់លុយហ្នឹងទៅឱ្យខាងយោធា ហើយនិងខាងសហករណ៍នោះ?

**ឆះ** អាហ្នឹងខ្ញុំឮតែគ្នាឯងនិយាយ។ អ្នកតូចតាចដូចគ្នានិយាយ រិភាគគ្នា។ អ្នកធំគេអត់ទាន់ប្រកាសប្រាប់ដល់ពួកថ្នាក់ក្រោមទេ។

[១៤:០៦:៤៦]

**សះ** ខ្ញុំសូមអានសេចក្តីដកស្រង់ពីចម្លើយរបស់លោកម្តងទៀត អង់គ្លេស ERN 0072829 *(ស៊ីក)* ហើយខ្មែរ 00733042 ហើយនិង 043 – 42 ដល់ 43។ “ខ្ញុំបានឃើញក្រដាសប្រាក់ដោយផ្ទាល់ភ្នែក ហើយគឺគេបានជជែកជាមួយយោធា ហើយម្នាក់ៗគឺថាត្រូវទទួលបាន២៥រៀល ហើយអ្នកមានថ្នាក់ខ្ពស់បាន៥០រៀលក្នុងមួយខែ ហើយនិងឃើញចេញនៅក្នុងភូមិភាគហ្នឹង។ ហើយយើងបានដឹងពីរឿងហ្នឹង មានការចាប់ខ្លួននៅខាងបូព៌ា។ នៅដែលការចាប់ខ្លួននៅខាងភូមិភាគបូព៌ាមួយខែហើយ គឺតាញ៉ឹម ក៏បានរៀបចំទ័ព ហើយនិងរៀបចំទ័ពចេញដើម្បីតទល់នឹង តាគាវ និង តាម៉ុក។ តាម៉ុក គឺថាប្រញាប់ហៅ តាញ៉ឹម ទៅប្រជុំ ហើយនៅពេលដែល --។ តើពួកគេមកដល់ភ្នំស្រុកទេ? បាទ។ តើក្រដាសប្រាក់ហ្នឹងមកដល់ភ្នំស្រុកទេ? តើឃើញទេ? ឃើញ គឺមានសញ្ញារូបគោ ហើយនិងនង្គ័លនៅលើហ្នឹង។ សំណួរ៖ ហើយគឺថានោះជាប្រាក់ លន់ នល់ ហើយមានគោហើយនិងនង្គ័ល? ចម្លើយ៖ អត់ទេ មិនមែនជាក្រដាសប្រាក់មកពីមុនទេ ហើយក្រដាសប្រាក់នេះ មានពណ៌ៗឆ្នោត។ តើលោកបានឃើញអក្សរអ្វីខ្លះ? ទេ ខ្ញុំមិនបានឃើញថា មានអក្សរជារបស់ លន់ នល់ ឬក៏អ្វីទេ ខ្ញុំមិនបានឃើញអក្សរនោះទេ។ ខ្ញុំបានឃើញមនុស្សនៅលើក្រដាសប្រាក់នោះដែលពាក់បង់កក្រមាផងដែរ ជួតក្បាលនឹងក្រមា។”

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន ខ្ញុំសូមបង្ហាញសាក្សីជាឯកសារថតចម្លងនូវក្រដាសប្រាក់ដែលយកមកពីរបប លន់ នល់ ហើយនិងក្រដាសប្រាក់ដែលខ្ញុំនឹង ដែលគេមានបំណងចង់ប្រើនៅក្នុងកម្ពុជាប្រជាធិបតេយ្យ នៅក្នុងឯកសារសំណុំរឿង ឯកសារ E190.1.404 នៅត្រង់ទំព័រដែលនិយាយអំពីប្រវត្តិសេដ្ឋកិច្ចរបស់កម្ពុជា។ នេះជាឯកសារចម្លងពណ៌ខ្មៅ ស-ខ្មៅ ដែលនៅក្រដាសប្រាក់នេះ ហើយនេះគឺយើងមានជាការថតចម្លងក្រដាសប្រាក់ ជាពណ៌ធម្មជាតិ។ ហើយខ្ញុំនឹងជូនទៅភាគី ហើយនិងអង្គជំនុំជម្រះ ដើម្បី

ពិនិត្យ ហើយនិងជូនទៅសាក្សីឲ្យពិនិត្យមើលថា តើលោកចាំថាបានឃើញក្រដាសប្រាក់បែបនេះដែរឬទេ ពេលដែលគាត់និយាយអំពីក្រដាសប្រាក់នៅក្នុងសវនាការនេះ?

[១៤:១០:៣៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាបញ្ហានេះគប្បីតែជូនដំណឹងតាមរយៈអ៊ីម៉ែលដើម្បីឲ្យយើងមានឱកាសពិនិត្យមើល ថាតើៗមេធាវីចង់បង្ហាញអ្វី។ តើជាក្រដាសប្រាក់ដែលបោះដោយខ្មែរក្រហម ឬក៏របប លន់ នល់ នោះ។ ប្រសិនបើលោកចង់ផ្តល់ឲ្យយើង ហើយនិងនិយាយបញ្ហានេះបន្ទាប់ពីសម្រាកយើងអាចពិនិត្យមើល បើសិនជាឯកសារត្រឹមត្រូវ ជាការបង្ហាញត្រឹមត្រូវ គឺថាអាចមានសារៈប្រយោជន៍។ ប៉ុន្តែភាគីទាំងអស់ គឺថាមានឱកាសដើម្បីពិនិត្យមុនពេលដែលមេធាវីប្រើដើម្បីសួរដេញដោលនោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនមានបញ្ហាអ្វីទេក្នុងការផ្តល់អង្គជំនុំជម្រះ ហើយនិងភាគីនូវច្បាប់ចម្លងជាខ្មៅស ហើយនិងមានពណ៌ធម្មជាតិនេះ។ ខ្ញុំមិនមានយល់ទាស់អ្វីទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្វង់ម៉ាក!

**ចៅក្រម ហ្វង់ម៉ាក ឡាវែន៖**

លោកមេធាវី ខ្ញុំចង់សួរលោកថា ហេតុអ្វីក៏នាទីចុងក្រោយហើយបានឲ្យ? ម៉េចក៏មិនត្រៀមលក្ខណៈការងារហ្នឹងឲ្យបានមុន ហើយព្រោះថា លោកដឹងរឿងនេះមិនត្រឹមតែឥឡូវទេ អ៊ីចឹងម៉េចក៏មិនដាក់សំណើមក។ អ៊ីចឹងដូចថា រូបក្រដាសសៀវភៅ -- រូបប្រាក់នេះ គឺថាមិនមែនជាឯកសារថ្មីទេ ឯកសារមាននៅក្នុងសំណុំរឿងហើយ ម៉េចក៏មិនប្រាប់មុន? សូមដាក់សំណើសុំជូនអង្គជំនុំជម្រះជាមុន ដើម្បីឲ្យយើងដឹងថា តើឯកសារនេះ ជាឯកសារអ្វី។

**លោក វ៉ិចទ័រ កូប៉េ៖**

យើងបានដាក់ចូលក្នុងអ៊ីនធើហ្វេសហើយឯកសារនេះនោះ។ បាទ ទំព័រដែលចម្លងខ្មៅ និងស។

ហើយយើងខ្ញុំយល់ថា អាចនឹងមានសារៈប្រយោជន៍ ជាឯកសារតែមួយទំព័រទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកមេធាវី លោកដាក់ឯកសារហ្នឹងនៅក្នុងអ៊ីនធើហ្វេស មួយទំព័រ និងក្រដាសប្រាក់ពណ៌ធម្មជាតិហើយ ប៉ុន្តែគឺថាដូចជាមិនមែនទំព័រដូចគ្នាទេ។

[១៤:១៣:១៤]

**លោក វ៉ិចទ័រ កូប៉េ៖**

តាមពិតខ្ញុំមិនដែលដាក់អ្វីៗដោយខ្លួនឯងទេ ប៉ុន្តែខ្ញុំយល់ថា ឯកសារនេះស្ថិតនៅក្នុងអ៊ីនធើហ្វេសហើយ។ ក៏ប៉ុន្តែខ្ញុំធ្វើដូចដែលអង្គជំនុំជម្រះធ្វើដូចគ្នានៅក្នុងរឿងក្តី០០២/០១ដែរ ដូចលោកចៅក្រមឡាវែន៍ បានពិនិត្យមើលក្រដាសប្រាក់ -- ឯកសារកូពីរបស់ អាឡាំង វ៉ូកូហ្វ ហ្នឹង។ ដូច្នេះគឺថា អ្វីដែលស្ថិតនៅក្នុងសំណុំរឿងគឺថា យើងមានតែឯកសារថតចម្លងខ្មៅ និងសនោះ បាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

នៅថ្ងៃមុខគួរតែគោរពនីតិវិធី និងវិធានដែលទាក់ទងទៅនឹងការទាក់ទងភស្តុតាងថ្មី ឯកសារថ្មី។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាតាមបច្ចេកទេស គឺថាយើងមិនអាចដាក់បែបនេះបានទេ ពីព្រោះឯកសារនេះមិនស្ថិតនៅក្នុងសំណុំរឿង។ ហើយលោកប្រធាន ខ្ញុំសូមអនុញ្ញាតដើម្បីផ្តល់ជូនឯកសារបោះពុម្ពពណ៌ធម្មជាតិហើយនិងខ្មៅស ERN ហើយនិងផ្តល់ជាលេខ ERN ដើម្បីនឹងពិនិត្យបញ្ហានៅក្រោយពេលសម្រាក។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

[១៤:១៤:៥៤]

**លោក វ៉ិចទ័រ កូប៉េ៖**

អរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ក្នុងឱកាសមួយចំនួនលោកបានផ្តល់មូលហេតុអំពីការចាប់ខ្លួន ដូចជាតាវ៉ាល់, តាម៉ោង, តាហ៊ីង្ស ហើយលោកនិយាយថា គេចាប់ខ្លួនអ្នកទាំងនោះ ដោយសារគេជាអ្នកក្បត់ក្បត់អង្គការ។ តើៗលោកចង់និយាយដូចម្តេច ដោយប្រាកដពាក្យថា “ក្បត់” នោះ? តើអ្វី ទោសអ្វីដែល

គេថាទោសក្បត់នោះ ក្បត់ជាតិនោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ខ្ញុំគិតថា មេធាវីនិយាយខុសពីពាក្យសាក្សីនិយាយ ហើយគាត់ៗមិននិយាយថា គេ -- គាត់យល់ថាអ្នកទាំងហ្នឹងជាជនក្បត់ជាតិទេ គាត់និយាយថាខាងនិរតីចោទពួកគេជាជនក្បត់។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនបញ្ហាទេ ខ្ញុំកែសម្រួលសំណួរខ្ញុំឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកបានផ្តល់សក្ខីកម្មថា តាវ៉ាល់ ហើយអ្នកផ្សេងទៀត ពីព្រោះថា គេចោទគាត់ថា ពួកគាត់ជាអ្នកក្បត់។ តើនៅពេលនោះលោកដឹងដែរឬទេ ថាតើ ៗពួកគេបានធ្វើអ្វី ដើម្បីឱ្យពួកកម្មាភិបាលមកពីនិរតីហ្នឹងចោទ ឬក៏អះអាងថាពួកគេជាជនក្បត់នោះ?

[១៤:១៦:៣៨]

**លោក ឡុត ស្វយ៖**

**ឆ៖** បាទ ដែលចោទថាពួក តាវ៉ាល់ ក្បត់នេះ គឺគេចោទរួមទាំងអស់មួយតំបន់៥នេះ ភូមិភាគពាយ័ព្យនេះ គឺសុទ្ធតែអ្នកក្បត់។ ពួកខ្ញុំក៏គិតឃើញថា ព្រោះគេចោទថាក្បត់នឹងអី បានគេថាយើងក្បត់? ពួកខ្ញុំក៏ដឹងមិនដល់ដែរ គេចោទថាក្បត់ទេ មិនដឹងថាក្បត់នឹងអី។ មិនដឹងថាផ្នែកនយោបាយពួកគេយ៉ាងណា។

**ស៖** ខ្ញុំនឹងអានសេចក្តីដកស្រង់ពីចម្លើយរបស់លោកពីលើកមុន។ គេបានសួរអំពីកងកម្លាំងភូមិភាគបូព៌ាទៅលោក។ នៅក្នុងចម្លើយមជ្ឈមណ្ឌលឯកសារកម្ពុជា អង់គ្លេស ERN 00728748, ខ្មែរ 00733054។ លោកបាននិយាយដូចខាងក្រោមនេះ៖ “បាទ ពួកបូព៌ាបម្រុងនឹងចូលទៅព្រៃ ដើម្បីចូលរួមជាមួយនឹងខាងពាយ័ព្យ ហើយការចូលរួមរវាងពួកគេទាំងពីរនេះ គឺដើម្បី – ភូមិភាគទាំងពីរ ដើម្បីផ្តួលភូមិភាគនិរតីដោយកម្លាំង។” អ្វីដែលលោកនិយាយទៅអ្នកស៊ើបអង្កេតនោះ គឺរឿងហៅថាវាមានការទាក់ទងគ្នា រវាងការចោទប្រកាន់ពីការក្បត់ ឬក៏លោកមិនដឹងពីរឿងហ្នឹងទេ?

**ឆ៖** អារឿងការក្បត់ភូមិភាគនេះ គឺខ្ញុំដឹងអត់ដល់ដែរ។ ឮ -- ខ្ញុំឃើញថាពួកកងទ័ពតំបន់គេថា

ភូមិភាគបូព៌ាបន្តិចទៀតគេមកនៅជាមួយភូមិភាគពាយ័ព្យ ពីព្រោះនិរតីចោទថាភូមិភាគបូព៌ានេះពួកក្បត់។

[១៤:១៩:២០]

**ស៖** តើលោកធ្លាប់ឮ ថាតើថាទោសក្បត់ជាតិហ្នឹងត្រូវបានប្រព្រឹត្តឡើងដោយភូមិភាគពាយ័ព្យ និងពួកបូព៌ា ជាទាហាន ឬក៏កម្មាភិបាលហ្នឹង គឺៗថាដោយសារពួកគេចាប់ផ្ដើមការបះបោរប្រដាប់អាវុធ ដើម្បីផ្ដួលមជ្ឈិម ដើម្បីដណ្ដើមអំណាចពីមជ្ឈិម ឬក៏យ៉ាងម៉េច? តើក្នុងន័យហ្នឹងឬទេ ដែលគេថាក្បត់បក្សនោះ? ការចោទប្រកាន់អំពីក្បត់នោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ខ្ញុំគិតថា មេធាវីបានបំភ្លឺសំណួរនេះ គឺថាគាត់សួរសំណួរ ថាតើៗកម្មាភិបាលនិរតី ឬក៏អ្នកផ្សេងទាក់ទងទៅនឹងមូលដ្ឋាននៃការចោទពីក្បត់ជាតិនោះទេ។ បាទ អ៊ីចេះគឺថាមេធាវីហាក់ដូចជាព្យាយាមផ្ដល់ព័ត៌មានឲ្យទៅសាក្សី ដើម្បីឲ្យសាក្សីឆ្លើយតាម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ សូមអរគុណ។ ប៉ុន្តែខ្ញុំគិតថា ខ្ញុំបានប្ដូរសំណួរខ្ញុំពីចុងក្រោយ ដំណាក់កាលចុងក្រោយអំមិញនេះ។ នៅពេលដែលមានការចាប់ផ្ដើមការបះបោរប្រដាប់អាវុធ គឺថាមានការប្រមូលអាវុធ ហើយការប្រមូលបង្កើតកងទ័ព ការចេញក្រដាសប្រាក់ ហើយនិងការបង្កើតទីផ្សារ។ តើរឿងទាំងអស់នេះលោកធ្លាប់បានឮ? តើលោកបានឮការចោទប្រកាន់ពីកម្មាភិបាលនិរតីហ្នឹង គឺវាស្របពេលនឹងអ្វីដែលខ្ញុំរៀបរាប់ខាងដើមហ្នឹង ឬក៏យ៉ាងដូចម្ដេច?

[១៤:២១:៣២]

**លោក ឡុត ស្វយ៖**

**ឆ៖** បាទ បានខ្ញុំឮថាគេថាចោទថា ភូមិភាគនិរតីៗនេះចោទថា ភូមិភាគបូព៌ានិងភូមិភាគពាយ័ព្យអ្នកក្បត់។ ខ្ញុំឮតែគ្នាឯងនិយាយ គេនិយាយប្រាប់ថា ម៉េចថាចោទថា ភូមិភាគពាយ័ព្យយើងក្បត់? បានរយៈកាលនេះកន្លងប្រហែលចំនួនប្រហែល យើងថាប្រហែល២ខែនេះគឺ និរតីចូលមកដល់បណ្ដោយ។ បានបាត់ខ្លួនពួក តាញឹម តាអី។

**ស៖** លោកសាក្សីខ្លួនឯង តើលោកបានច្បាំង ឬក៏ទៅសមរភូមិប្រឆាំងនឹងកងទ័ពខាងនិរតីនោះ?

តើលោកចាំ ឬមិនចាំ ជាមូលដ្ឋានដ៏សំខាន់នៃការចោទប្រកាន់នៃការក្បត់ ក្បត់បក្ស ឬក្បត់ជាតិនេះ លោកធ្លាប់ឮ ឬក៏មិនធ្លាប់ឮអ្វីសោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ នេះជាសំណួរច្រំដែល ហើយគាត់បានសួរថា តើសាក្សីបានឮអ្វីខ្លះ? គេប្រាប់គាត់ម៉េច? គឺថា ហើយបើការទទួចសួរបន្ថែមគឺថា អាចជាសំណួរស្នើចម្លើយទៅឱ្យគេ។ ដូច្នេះគឺថា ទោះបីជាពេលនោះគឺមិនមានការប្រកាសក៏ដោយគឺថា អ្វីដែលសាក្សីឆ្លើយគាត់ឆ្លើយតាមអ្វីដែលគាត់ដឹង ហើយគាត់បានឆ្លើយរួចហើយ។

[១៤:២៣:២៩]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងបន្តទៅមុខទៀតលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកក៏បាននិយាយផងដែរអំពីចម្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជាអំពីការសម្លាប់អ្នកការទូតចិន។ តើដែលថាលោកឮតពីគេហ្នឹង តើលោកចាំបានអ្វីខ្លះអំពីរឿងហ្នឹង?

**លោក ឡុត សួយ៖**

**ឆ៖** ខ្ញុំឮថាពួកកងទ័ពតំបន់គេថា ភូមិភាគបូព៌ានេះសម្លាប់ទូតចិន បានគេចោទភូមិភាគបូព៌ានេះថា ភូមិភាគបូព៌ាក្បត់។ ប៉ុន្តែខ្ញុំមិនដែលឃើញចិនមកជាន់ភូមិភាគពាយ័ព្យទេ។

**ស៖** តើលោកបានឮ អាចជាអ្វីជាមូលហេតុនៃការសម្លាប់អ្នកការទូតដែលថា ទាក់ទងទៅនឹងខាងកងទ័ព ខាងពាយ័ព្យហ្នឹងដែរឬទេ?

**ឆ៖** ពេលនោះ ខ្ញុំអត់ដឹងដែរ។

[១៤:២៤:៥៨]

**ស៖** ខ្ញុំនឹងពិនិត្យបញ្ហាឡើងវិញដែលទទួលការជំទាស់ ហើយខ្ញុំនឹងសម្រួលសំណួររបស់ខ្ញុំឡើងវិញ លោកប្រធាន។ ហើយខ្ញុំនឹងអានក្តីដកស្រង់ដែលខ្ញុំបានអានពីខាងមុននេះផងដែរ ពីចម្លើយពីមុនរបស់លោក គឺឯកសារ 00728748, ខ្មែរ 00733055 “មិត្តភាពរវាងភូមិភាគពាយ័ព្យ ហើយនិងបូព៌ា

ដើម្បីវាយប្រហារ ផ្ដួលបំផ្លាញឲ្យអស់នូវពួកនិរតី ហើយនិងបង្កើតគ្រប់គ្រងអំណាចដោយខ្លួនឯង”។ នេះជាពាក្យសម្ដីផ្ទាល់របស់លោក។ តើការៗវាយកម្ទេចខាងនិរតីឲ្យអស់ ដើម្បីបង្កើតគ្រប់គ្រងអំណាចហ្នឹង តើលោកនិយាយពេលហ្នឹង ពេលនោះលោកចង់មានន័យថាដូចម្ដេច?

**ឆ៖** ពេលដែលភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យនេះ គេចំណងសាមគ្គីគ្នាថា ភូមិភាគនិរតីនេះចោទថាភូមិភាគពាយ័ព្យនេះក្បត់ ហើយបានភូមិភាគបូព៌ានេះ គេមកចង់វាយផ្ដួលពួកនិរតីនេះ បានគេមកពឹងពាក់ពួកពាយ័ព្យនេះ។

**សៈ** ប៉ុន្ដែចម្លើយរបស់លោក គឺថាសាមគ្គី ឬមិត្តភាពរវាងបូព៌ា និងពាយ័ព្យហ្នឹង គឺថាបំផ្លាញខាងនិរតីឲ្យបានខ្ទេចខ្ទី ដើម្បីបង្កើតបដិវត្តន៍ៗជាថ្មីឡើងវិញ។ តើលោកចង់មានន័យដូចម្ដេច ពេលដែលលោកប្រើឃ្លានេះ?

**ឆ៖** ខ្ញុំអត់ដែលបាននិយាយថា បង្កើតបដិវត្តន៍ផង គឺដឹងតែត្រឹមតែពាយ័ព្យ និងនិរតី គេបានជាចំណងមិត្តភាពគ្នា ដែលគេបាននិរតីបានចោទថា បូព៌ានេះបាញ់សម្លាប់ទូតចិន។ អានេះ ខ្ញុំដឹងតែត្រឹមណោះឯង។

**សៈ** ប៉ុន្ដែចម្លើយលោកទៅមជ្ឈមណ្ឌលឯកសារកម្ពុជានោះ លោកបានបំភ្លឺបន្ថែមទៀត អំពីការបង្កើតបដិវត្តន៍ថ្មី ដែលក្នុងនោះ ដែលរាប់បញ្ចូលទាំងការធ្វើការងារ ឬក៏ជំនួញនៅក្នុងសហករណ៍ឡើងវិញ។ តើលោកចង់សំដៅលើអ្វីពេលដែលថា ចង់ធ្វើជំនួញក្នុងចំណោមសហករណ៍?

**ឆ៖** ភូមិភាគពាយ័ព្យនេះ គេបម្រុងប្រែសង្គម ឲ្យមានឲ្យប្រជាជនមានហូបចុកស្រួលបួល គេបម្រុងបើកជាសហករណ៍លក់ដូរ មានការទិញដូរគ្នា។ ដល់ពេលនោះឡើងនិរតីដឹង ក៏និរតីវាយចាប់ពួកជួរកម្មាភិបាលពាយ័ព្យនេះអស់។ បាននិរតីគេចូលមកជាន់ទឹកដីភូមិភាគពាយ័ព្យនេះ។ គេចោទថាភូមិភាគពាយ័ព្យនេះក្បត់។

[១៤:២៩:០៩]

**សៈ** តើលោកធ្លាប់ឮ តាវ៉ាល់ និយាយអំពីការបង្កើតបដិវត្តន៍ ហើយកម្ទេចពួកកម្មាភិបាលនិរតីដែរឬទេ?

**ឆ៖** ពេលនោះខ្ញុំឈប់នៅជាមួយ តាវ៉ាល់ ហើយ ខ្ញុំមកនៅនឹងកងស្រុកភ្នំស្រុក។ បានកម្មាភិបាលស្រុកភ្នំស្រុក ដូចជា តាណាក គាត់ទៅប្រជុំ បានគាត់មកធ្វើការប្រាប់កូនចៅក្រោមៗ។ បានខ្ញុំដឹងថា ប្រាប់ពួកខ្ញុំថា គេបម្រុងរៀបជាសហករណ៍លក់ដូរ។ បន្តិចទៀតនេះ គេនឹងបើកប្រាក់ខែឲ្យ

កងកម្លាំង ឲ្យពេទ្យ ឲ្យជួរកម្មាភិបាលគ្រប់មុខ។

**សៈ** ខ្ញុំនឹងត្រឡប់មកបញ្ហានេះឡើងវិញ។ ឥឡូវនេះ យើងចូលទៅប្រធានបទថ្មីមួយ អាចនឹងជាសន្ទនារបស់លោកដែលលោកអាចជជែកជាមួយកម្មាភិបាលខាងនិរតី។ តើលោកធ្លាប់និយាយទៅកម្មាភិបាលស្ត្រីដែលមកពីភូមិភាគនិរតីដែរឬទេ?

**ឆៈ** បាទ ខ្ញុំបានឈ្លោះគ្នាជាមួយនឹងភូមិភាគនិរតីស្រី ឈ្មោះ នារីង៉ែត នេះជាប្រធានសហករណ៍នៅភូមិតាប៉ែន។ ខ្ញុំក៏បានមកលេងផ្ទះ ក៏ខ្ញុំបានឡើងលើផ្ទះគេ ក៏អត់បានដោះស្បែកជើង។ ពេលយប់ឡើងក៏និរតីនោះ គេក៏លួចហ៊ុំចាប់ខ្ញុំយកទៅវាយចោល។ ពេលម៉ោងដប់ពីរយប់ នៅថ្ងៃពេញបូណ៌មីនេះខ្ញុំក៏បានប្រើក្នុងកម្លាំងបាយ នូវក្បាច់គុណបុរាណខ្មែរនេះ ជាមួយពួកគេ១០នាក់នេះ បានខ្ញុំរត់ បានរួចខ្លួនក៏ខ្ញុំរត់ឡើងភ្នំព្រះនេត្រព្រះ។ បានខ្ញុំចេញពីភ្នំព្រះនេត្រព្រះទាំងយប់ប្រហែលម៉ោងពីរនេះ ខ្ញុំក៏ដល់ត្រឡប់ទៅភ្នំស្រុកវិញ។

[១៤:៣១:៥៤]

**សៈ** ខ្ញុំគិតថាលោកបាននិយាយពីរឿងនេះរួចទៅហើយ។ តើលោកថាលោកជាបុរសហ្នឹង ថាតើលោកអាចនឹងទៅឈ្លោះ ឬក៏ -- បាទ តើគាត់ចូល -- លោកចូលចិត្តកម្មាភិបាលនារីមកពីនិរតីដែរឬទេ?

**ឆៈ** ខ្ញុំអត់ដែលចូលចិត្តទេ ហើយនិងមិនដែលស្គាល់គេផង។ ហើយគេចោទពួកខ្ញុំថា ភូមិភាគពាយ័ព្យនេះសុទ្ធតែពួកក្បត់។

**សៈ** ខ្ញុំសូមរំឭក ជួយរំឭកការចង់ចាំរបស់លោកបន្តិច ERN ជាភាសាអង់គ្លេស 00728745, ខ្មែរ 00733049 ដល់ 50។ "សំណួរ៖ សួរតើលោកស្គាល់កម្មាភិបាលភូមិភាគនិរតីប៉ុន្មាននាក់? – ខ្ញុំឆ្លើយ៖ ខ្ញុំស្គាល់ខ្លះ។ ពេលហ្នឹងគឺថា ខ្ញុំហ្នឹងរាងដូចថាច្រឡឹមដែរហ្នឹង រាងចែចង់ជាមួយនឹងកម្មាភិបាលនារីហ្នឹងដែរ។ ពេលហ្នឹងគឺថាខ្ញុំនៅលីវ គឺថាខ្ញុំនិយាយលេងសើចច្រើនដែរ។" តើវាជួយរំឭកដល់ការចងចាំរបស់លោកទេចំណុចនេះ?

**ឆៈ** ខ្ញុំស្គាល់នារីនិរតី គឺស្គាល់នារី ង៉ែត និងនារី ថា, ស្គាល់នារី ជឿន។ ប៉ុន្តែខ្ញុំភ្លេចឈ្មោះគេខ្លះ ចាំបានតែប៉ុណ្ណោះឯង។

**សៈ** ហើយលោកចាំទេ នៅពេលដែលលោកលេងសើចជាមួយនឹងកម្មាភិបាលនារីពីភូមិភាគនិរតីនេះ នៅក្នុងពេលនិយាយគ្នាលេងហ្នឹង លោកមានបានស្តាប់ឮមូលហេតុ ដែលនាំឲ្យមានការចាប់

ខ្លួនកម្មាភិបាលមួយចំនួន ដូចជា តាវ៉ាល់ នេះជាដើមដែរទេ?

[១៤:៣៤:២០]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សំណួរនេះមិនពាក់ព័ន្ធ។ សូមលោកមេធាវីសួរសំណួរទាក់ទងនឹងប្រធានបទ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំទុកចោលចុះ ចំពោះសំណួរពាក់ព័ន្ធទៅនឹងការញ៉ែប៉ប្រែជាមួយកម្មាភិបាលនារីនេះ។ ពេលលោកនិយាយជាមួយកម្មាភិបាលនារីនេះ លោកដែលស្ដាប់ឮពីមូលហេតុដែលនាំឱ្យមានការចាប់ខ្លួនកម្មាភិបាលមួយចំនួន ដូចជា តាវ៉ាល់ នេះជាដើមដែរទេ?

**លោក ឡុត ស្វយ៖**

**ឆ៖** ខ្ញុំអត់ដែលឮទេ។ ឮគេចោទថា ពួកពាយ័ព្យក្បត់ៗ គេហៅរួមបណ្ដោយ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំគិតថា ខ្ញុំសួរជិតចប់ហើយ លើកលែងតែសំណួរពាក់ព័ន្ធទៅនឹងក្រដាសប្រាក់តែប៉ុណ្ណោះ។ ហើយខ្ញុំមើលទៅឃើញដល់ម៉ោងសម្រាកហើយ។ តើគួរឈប់សម្រាកសិន ហើយសឹមចូលមកវិញ ខ្ញុំនឹងសួរបន្តអំពីបញ្ហាលុយកាក់នេះ។ យ៉ាងណាដែរលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះ និងមេធាវីប្រឹក្សានៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញវេលាម៉ោងបី។

សូមអញ្ជើញសម្រាក!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៦ នាទី ដល់ម៉ោង ១៤:៥៩ នាទី)*

[១៤:៥៩:០៧]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធី។ សូមអញ្ជើញលោកមេធាវី កូប៉េ បន្តសំណួរ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមការអនុញ្ញាតពីលោកប្រធាន ដើម្បីផ្តល់ជូនទៅមន្ត្រីរដ្ឋបាលតុលាការនូវច្បាប់ចម្លងពណ៌ធម្មជាតិនូវក្រដាសប្រាក់ ហើយនិងខ្ញុំឆ្លៀតឱកាសនេះ ដើម្បីឯកសារនេះគឺលេខ E3 ដើម្បី E3/4535 ហើយមានលេខ ERN ដូចគ្នាបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន។ ខ្ញុំនឹងមានការប្រុងប្រយ័ត្នក្នុងការផ្តល់សេចក្តីសង្កេត ពីព្រោះខ្ញុំមិននិយាយអ្វីជាមួយសាក្សីនេះទេ។ នេះគឺជាច្បាប់ចម្លងដែលបង្ហាញទំព័រចេញមកពីសៀវភៅ។ ម្យ៉ាងវិញទៀតបើសិនជាតុលាការផ្តល់ការយល់ព្រម គឺថាអាចនឹងផ្តល់ទៅសាក្សីពិនិត្យ។ ប៉ុន្តែមិនបន្ថែមតម្លៃអ្វីច្រើនទេក្នុងការបង្ហាញសាក្សី ដែលដាក់បញ្ចូលក្រដាសប្រាក់ពីរសន្លឹក ដែលយកចេញ -- ដែលជារបស់សម័យកាលខ្មែរក្រហម – កម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែមិនដាក់បញ្ចូលលទ្ធភាពទាំងអស់ដែលថា ក្រដាសប្រាក់ដែលសាក្សីអាចបានឃើញ ប៉ុន្តែទោះជាយ៉ាងណាក្តី ជាជាងការផ្អាកពន្យារពេលយូរនោះ ប្រសិនបើតុលាការផ្តល់ការអនុញ្ញាត ខ្ញុំមិនជំទាស់ទៅនឹងការបង្ហាញឯកសារនេះទៅសាក្សីទេ។ ប៉ុន្តែខ្ញុំកត់សម្គាល់ថា ចំណុចមួយដែលថាអាចនឹងកៀកបំផុតទៅនឹងការរៀបចំនោះគឺថា ឃើញថាច្បាប់ចម្លងមិនមានគុណភាពច្បាស់ទេ។ ប៉ុន្តែគឺថា ដោយបញ្ជាក់បញ្ជានេះ គឺថាអាចនឹងមានសារៈប្រយោជន៍ ហើយសហព្រះរាជអាជ្ញាមិនជំទាស់ទេ។

[១៥:០២:១៧]

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំមិនច្បាស់ថា មតិរបស់ព្រះរាជអាជ្ញាចុងក្រោយមានន័យយ៉ាងដូចម្ដេចទេ។ ប៉ុន្តែតើលោកចង់និយាយថា ច្បាប់ចម្លងនេះគឺវាផ្ទុះបញ្ហាំង ឬក៏វាត្រូវទៅនឹងការរៀបរាប់ច្បាស់យ៉ាងណា ឬមិនយ៉ាងណា ឬដែលទេ។ សូមការអនុញ្ញាតពីតុលាការដើម្បីបង្ហាញឯកសារនេះទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីរដ្ឋបាលតុលាការយកឯកសារយកបង្ហាញសាក្សី!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ខ្ញុំនឹង -- យើងមិននិយាយជាមួយសាក្សីទេពេលនេះ។ ឥឡូវនេះ លោកសាក្សី ខ្ញុំនឹងសួរសំណួរដោយចំហ តើលោកអាចនិយាយអ្វីបានខ្លះ រៀបរាប់អ្វីខ្លះបានក្រោយពីឃើញក្រដាសប្រាក់នៅលើក្រដាសដែលមានការបោះពុម្ពចម្លងនេះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ហើយយើងនឹងពិនិត្យមើលការអនុវត្ត។ សូមឲ្យលោកសួរសំណួរមានលក្ខណៈផ្ដល់នូវការយល់ឃើញ។ អ៊ីចឹងគឺថា បើសួរថាតើអានេះវាតំណាង ឬក៏បង្ហាញពីអ្វីដែលលោកឃើញក្នុងឆ្នាំ១៩៧៧អ៊ីចឹង បើសិនជាខ្ញុំវិញ គឺខ្ញុំនឹងសួរសំណួរជាក់លាក់ដើម្បីសន្សំពេលមានតម្លៃ។

[១៥:០៥:០៥]

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំសួរសំណួរដែលមានគោលបំណង ពីព្រោះខ្ញុំមិនដឹងថា តើគាត់បានឃើញអ្វី? ខ្ញុំក៏សួរសំណួរដែលមានលក្ខណៈចំហតាមដែលអាចធ្វើទៅបាន។ វាមានលទ្ធភាពទី៣ ផងដែរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ខ្ញុំគិតថា វិធីសមស្របដើម្បីសួរសំណួរនេះគឺថា គឺលោកសាក្សី តើលោកអាចប្រាប់តុលាការ តើលោកឃើញអ្វីខ្លះលើឯកសារលើក្រដាសនេះ?

**លោក ឡុត ស្វយ៖**

**ឆ៖** បាទ ក្រដាសប្រាក់ដែលខ្ញុំឃើញនេះ គឺក្រដាស១០រៀល ហើយមានមនុស្សពីរនាក់នៅក្នុងជាប់ក្នុងក្រដាសនោះ។ មានមនុស្សច្រូតស្រូវ ហើយនិងមនុស្សលីចប។

**ស៖** ខ្ញុំនឹងសួរសំណួរជាក់លាក់លោកសាក្សី។ នៅលើទំព័រមួយលោកឃើញ គឺក្រដាសប្រាក់មានពណ៌ក្រហមដែលសរសេរឆ្នាំ១៩៧៥ ដែលក្រដាស១០រៀល។ តើរូបនេះជាក្រដាសប្រាក់ដែលលោកចងចាំបានឃើញពីមុន ឬក៏វាខុសពីអ្វីដែលលោកបានឃើញកាលនោះ?

**ឆ៖** ដែលខ្ញុំបានឃើញនោះ គឺមនុស្សច្រូតស្រូវតែម្នាក់ ហើយនិងអ្នកលីចបម្នាក់។ អានេះមនុស្សច្រើនច្រូតស្រូវ។

[១៥:០៧:២០]

**ស៖** ចុះក្រដាសប្រាក់ផ្សេងទៀតនៅលើឯកសារនេះ លើទំព័រនេះ លោកសាក្សីអាចប្រាប់តុលាការបានទេ តើលោកស្គាល់ទេ តើក្រដាសប្រាក់ទាំងនោះជាអ្វីខ្លះ?

**ឆ៖** ក្រដាសប្រាក់មួយនេះ គឺជាក្រដាសប្រាក់របស់ទាហាន លន់ នល់ ដែលទូលក្អម ហើយនិងប្រាសាទព្រះវិហារ និងគោនេះជាក្រដាសប្រាក់របស់សម័យយើង គេហៅសម័យ លន់ នល់។ អានេះចេញក្រោយទេ អានេះ--

**ស៖** នេះជានៅលើទំព័រមួយ ម្ខាងដែលពណ៌បៃតងនៅលើ។ ឥឡូវនេះ លោកត្រឡប់ទៅពណ៌ម្ខាងទៀតដែលមើលពណ៌ក្រហម ដែលលោកមើលទៅ តើលោកនៅចងចាំ ឬក៏លោកអាចរៀបរាប់បានពីក្រដាសប្រាក់ទាំងនោះ ដូចម្ដេចខ្លះ?

**ឆ៖** ហើយបើខ្ញុំ បើសង្ស័យៗអាក្រដាសប្រាក់នេះឯង ក្រដាសប្រាក់ក្រហមនេះឯង ប៉ុន្តែទាល់តែមនុស្សវាច្រើន។

**ស៖** នៅពេលដែលលោកនិយាយថា--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមឱ្យកត់ចូលក្នុងប្រតិចារឹក។ សាក្សីទើបតែនិយាយថា គាត់ចាំថា ប្រហាក់ប្រហែលហ្នឹងដែរ គឺក្រដាសប្រាក់១០រៀល ដែលមាននៅលេខ ERN 00685868 បើសិនជាខ្ញុំមិនច្រឡំទេនោះ។

[១៥:០៩:៥៨]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ចៅក្រម ឡាវែន៍ អ្វីដែលគាត់បន្ថែមហ្នឹង គឺគាត់រង់ចាំ -- គាត់ចងចាំថា មានរូបមនុស្សតិចជាងហ្នឹងកំពុងភ្ជួរស្រែ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ហើយចំពោះក្រដាសប្រាក់ផ្សេងទៀត លោកសាក្សី ថាតើបីសន្លឹកទៀត តើលោកស្គាល់ថាក្រដាសប្រាក់ហ្នឹងថាជាអ្វីដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

គឺថាៗសំណួរសួរថាមើលទៅស្រដៀងអ្វីហ្នឹង គឺថាមិនមានសារៈប្រយោជន៍ទេ គឺថាសាក្សីគឺថាក្រដាសប្រាក់នោះ គឺថាត្រូវបានប្រើក្នុងរបបចាស់ របប លន់ នល់។ គឺថាសំណួរនេះមិនផ្តល់ជាអត្ថប្រយោជន៍ទេ លើកលែងតែមេធាវីមានសំណួរផ្សេងទៀតឲ្យសាក្សីឆ្លើយអស់ពីលទ្ធភាពដែលគាត់ស្គាល់។ លើកលែងតែផ្តល់ក្រដាសប្រាក់គ្រប់ប្រភេទទាំងអស់ ដើម្បីឲ្យគាត់កំណត់អត្តសញ្ញាណ។ ដូច្នេះ ខ្ញុំឃើញថាការអនុវត្តសួរដេញដោលនេះហាក់ដូចជាដល់ទីបញ្ចប់ទៅហើយ។

[១៥:១១:១២]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា ខ្ញុំមិនស្របជាមួយមតិលោកសហព្រះរាជអាជ្ញាទេ។ អ៊ីចឹងលោកសាក្សី នៅពេលដែលខ្ញុំសួរដើម្បីបង្ហាញភស្តុតាងនេះ លោកប្រធានគឺថាចង់បង្ហាញឲ្យច្បាស់ថាតើអ្វីជាក្រដាសប្រាក់កម្ពុជាប្រជាធិបតេយ្យបោះពុម្ពមុនឆ្នាំ១៩៧៥ ឬក៏គាត់បានឃើញក្រដាសប្រាក់ផ្សេងដែលត្រូវបានចេញ ឬក៏បោះពុម្ពដោយ រស់ ញឹម នៅក្នុងភូមិភាគពាយ័ព្យ។ នេះហើយជាគោលបំណងខ្ញុំក្នុងការផ្តល់ភស្តុតាងនោះ បង្ហាញភស្តុតាង សួរឲ្យចេញជាភស្តុតាងនោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ៊ីចឹងក្រដាសប្រាក់ផ្សេងទៀត លោកសាក្សី បីសន្លឹងផ្សេងទៀត តើលោកស្គាល់ណាមួយទេ ក្នុងចំណោមបីផ្សេងទៀតនោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ជាថ្មីម្តងទៀតលោកប្រធាន ការជំទាស់ដដែល។ ប្រសិនបើចង់បង្ហាញច្បាស់ ថាត្រូវតែរៀបចំឲ្យបានគ្រប់ក្រដាសប្រាក់ដែលខ្មែរក្រហមបានចេញឲ្យសាក្សីបានពិនិត្យ។ ពីព្រោះយើងមិនអាចនឹងបង្ហាញភស្តុតាងអ្វីច្បាស់ទេ បើយើងមិនបានក្រដាសប្រាក់គ្រប់ប្រភេទនោះ។ សួរថាតើគាត់ស្គាល់ក្រដាសប្រាក់មកពីរបបចាស់ គាត់ស្គាល់។ ប៉ុន្តែបើសិនថាស្គាល់តែក្រដាសប្រាក់មកពីរបបចាស់ មិនបង្ហាញភស្តុតាងអ្វីទេ។

[១៥:១២:៣៩]

**លោក វ៉ិចទ័រ កូប៉េ៖**

នៅក្នុងកំណត់ហេតុស្តាប់សួរគាត់នោះ នៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺថា ERN 00733053 គាត់ឆ្លើយថា៖ "ខ្ញុំមិនស្គាល់ទេ ថ្នាក់លើបានប្រាប់ខ្ញុំថា គេបានចេញ ហើយឃើញថាមានរូបមនុស្សជួតក្បាលនឹងក្រម៉ា ហើយនិង ហើយគេបានបង្ហាញក្រដាសប្រាក់បីសន្លឹក គឺសុទ្ធតែក្រដាស១០រៀល -- មួយសន្លឹកជាក្រដាស -- គឺក្រដាស១០ហ្នឹងពីរសន្លឹក ហើយនិងក្រដាស២០មួយ។" ហើយគាត់បាននិយាយថា គាត់ថាបានឃើញក្រដាសប្រាក់ដែលមានក្រដាស១០។ យ៉ាងហោចណាស់ក៏យើងមានមួយសន្លឹកពីរបបកម្ពុជាប្រជាធិបតេយ្យដែលដែរ។ យើងសួរថាតើដូចគ្នានឹងអ្វីដែលគាត់បានឃើញទេ អាហ្នឹងជាគោលបំណងក្នុងការបង្ហាញភស្តុតាងពីរឿងក្រដាសប្រាក់នេះមួយហើយ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបដិសេធការជំទាស់។ សាក្សីឆ្លើយនឹងសំណួរនេះ!

សូមលោកមេធាវីសួរសំណួរនេះម្តងទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកទើបតែបាននិយាយអំពីក្រដាសប្រាក់ទី៣ រាប់ពីលើចុះមកក្រោម។ ឥឡូវនេះខ្ញុំសួរសន្លឹកទី១, ទី២ ពីខាងលើ តើលោកៗស្គាល់ដែរឬទេ?

**លោក ឡុត ស្វយ៖**

**ឆ៖** បាទ សន្លឹកទី២ ខ្ញុំអត់ដែលបានឃើញទេ ពីរសន្លឹកនេះ។ ព្រោះខ្ញុំបានឃើញគេបង្ហាញខ្ញុំ

នោះ គឺសន្លឹក១០ក្រហម។ ក្រដាស១០ក្រហមហើយក្រាស ហើយមានមនុស្សស្រីជួតក្បាលកន្សែង ហើយច្រូតស្រូវ ហើយនិងមនុស្សប្រុសម្នាក់ទៀតនោះ លីចបកាប់ដី។

**ស៖** អ៊ីចឹងត្រឡប់ទៅរកក្រដាសប្រាក់ទី៣ រាប់ពីលើចុះមកក្រោម នៅលើទំព័រនេះ ដែលលោករៀបរាប់ថា ប្រហែលជាដូចបាទ--

**ប្រធានអង្គជំនុំ៖**

សូមមេធាវីបន្តសំណួរថ្មីទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ ហើយខ្ញុំនឹងព្យាយាមបង្ហាញពីក្រដាសប្រាក់ដែលលោកសាក្សីបានឃើញ ហើយតើលោកចងចាំអ្វីខ្លះ អំពីក្រដាសប្រាក់នេះ ពីព្រោះលោកបាននិយាយថា ឃើញរូបមនុស្សច្រើននាក់ភ្ជួរស្រែ ហើយតើលោកបាននិយាយថា ឃើញរូបយោធានៅលើក្រដាសប្រាក់ដែលលោកបានឃើញហ្នឹង តើលោកចាំរឿងហ្នឹងទេ?

**លោក ឡុត ស្ឈួយ៖**

**ឆ៖** បាទ ខ្ញុំអត់ដែលបាននិយាយអ៊ីចុះផង។ នឹកអត់ឃើញទេ។

[១៥:១៦:៤៩]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ គឺថាក្រដាសប្រាក់ទី៣ ដែលលោកចាំថា បានឃើញនៅក្នុងឆ្នាំ១៩៧៧ ឬ៧៨ នោះ តើក្រដាសសន្លឹកទី៣ហ្នឹង អ៊ីចឹងមែនទេ ថាលោកបានឃើញ?

**ឆ៖** បាទ ក្រដាសនុ៎ង វាក្រហមដូចអ៊ីចេះឯង ពណ៌ហ្នឹងឯង ប៉ុន្តែទាស់វាមនុស្សតិចជាងនេះ មនុស្សច្រូតស្រូវ។

**ស៖** សូមអរគុណលោកសាក្សី។ ប្រធានបទចុងក្រោយរបស់ខ្ញុំ ខ្ញុំមានសំណួរមួយចំនួន គឺសំណួរទាក់ទងអំពីរឿងប្រពន្ធរបស់លោក។ លោកបានប្រាប់ទៅអ្នកស៊ើបអង្កេតមជ្ឈមណ្ឌលឯកសារកម្ពុជាថា ប្រពន្ធរបស់លោកជាប្រធានពេទ្យស្រុក។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ប្រពន្ធខ្ញុំជាប្រពន្ធពេទ្យស្រុក ពេទ្យស្រុកភ្នំស្រុក។

**ស៖** តើលោកចាំទេ គាត់បានឡើងធ្វើជាប្រធានពេទ្យស្រុកហ្នឹងនៅឆ្នាំណា ឬក៏ខែណា ពេលណា?

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សំណួរនេះក្រៅវិសាលភាពហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំដូចមិនច្បាស់ថាខ្ញុំយល់ទេ។ មូលហេតុដែលខ្ញុំសួរហ្នឹង ខ្ញុំបំភ្លឺ ខ្ញុំសួរអំពីប្រពន្ធគាត់ថាជាប្រធានពេទ្យស្រុក ចង់ដឹងថា តើគាត់ដឹងអំពីរបៀបដែលគេប្រើថ្នាំដូចម្ដេច ការថែទាំសុខភាពហ្នឹង គេធ្វើម៉េចនៅក្នុងស្រុក។ អានេះជាគោលបំណងរបស់ខ្ញុំ ជាមានសំណួរមួយចំនួន ទាក់ទងអំពីបញ្ហាសុខភាពហើយនិងជំងឺជាដើម។ ខ្ញុំគិតថា គាត់ហើយនិងប្រពន្ធគាត់ដែលជាប្រធានមន្ទីរពេទ្យស្រុកហ្នឹង គឺថាអាចនឹងប្រាប់ព័ត៌មានច្រើន។ ហើយខ្ញុំគិតថានៅក្នុងវិសាលភាព។ ប្រសិនបើលោកប្រធានអនុញ្ញាតខ្ញុំ ខ្ញុំនឹងបន្តលោកប្រធាន។

[១៥:១៩:៣២]

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីសួរបន្តទៀត។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកចាំដែរឬទេ ប្រពន្ធលោកបានធ្វើជាប្រធានមន្ទីរពេទ្យស្រុកហ្នឹង នៅពេលណា?

**លោក ឡុត សួយ៖**

**ឆ៖** ខ្ញុំចាំអត់បានផង។ អង្កាល់ពេលគេ -- ព្រោះគេចូល ១៧ មករា នេះឯង -- ១៧ មេសា។ ជាអ្នកថ្មី បានគេឡើងធ្វើប្រធានពេទ្យស្រុកនេះ កាលនោះខ្ញុំក៏អត់ទាន់បានៗប្រពន្ធខ្ញុំទេ។ ខ្ញុំបានប្រពន្ធខ្ញុំចំនួនប្រហែលមួយខែ ក៏គេដកចេញប្រពន្ធខ្ញុំចេញពីអង្គភាពពេទ្យនោះទៅនៅតាមសហករណ៍វិញ ព្រោះច្បាប់របស់គេឲ្យតែបានប្រពន្ធហើយ គេដកចេញហើយ។

**ស៖** តើលោកដឹងទេ ថាគាត់បានរៀនសូត្រខាងពេទ្យដែរឬទេ ជាប្រវត្តិសិក្សារបស់គាត់ខាងពេទ្យនោះ?

**ឆ៖** ពេលនោះខ្ញុំដឹងអត់ដល់ដែរ។

[១៥:២១:១៥]

**ស៖** តើគាត់បានចូលរួមក្នុងការព្យាបាលអ្នកជំងឺ នៅពេលដែលគាត់ធ្វើ -- នៅពេលដែលលោកធ្វើការនៅត្រពាំងថ្មហ្នឹង តើលោកដឹងថាគាត់បានចូលរួមក្នុងការព្យាបាលអ្នកជំងឺដែរទេ?

**ឆ៖** បាទ ពេលដែលខ្ញុំមកលេង ខ្ញុំឃើញគេមានការព្យាបាលអ្នកជំងឺនៅក្នុងកន្លែងពេទ្យគេហ្នឹង។

**ស៖** តើលោកចាំអ្វីខ្លះ អំពីរបៀបដែលគាត់ព្យាបាលអ្នកជំងឺនោះ តើគាត់ប្រើថ្នាំបុរាណ ឬក៏ថ្នាំប្រភេទអ្វីដែរ?

**ឆ៖** ពេលដែលព្យាបាលអ្នកជំងឺនោះ គឺប្រើនូវថ្នាំប្រភេទបុរាណ។ គ្រូខ្មែរបុរាណយើង បុកឫសឈើ ឫសព្រៃ ហើយកើតជាថ្នាំ សូនៗកើតជាថ្នាំទៅ ហើយនិងស្មោរថ្នាំច្រកដប ដើម្បីការព្យាបាលឲ្យអ្នកជំងឺ បើកឲ្យពេទ្យ។

**ស៖** ទោះបីជាលោកមិនដឹងច្បាស់អំពីការអប់រំ ការរៀនសូត្ររបស់ប្រពន្ធលោកទេ នៅពេលដែលលោកឃើញគាត់កំពុងធ្វើការនោះ តើគាត់ជាពេទ្យដែលមានជំនាញក្នុងការព្យាបាលអ្នកជំងឺ? ក្រោយពីការព្យាបាលទៅ តើអ្នកជំងឺហ្នឹងជា ឬក៏ធូរស្រាលដែរឬទេ?

**ឆ៖** ដែលខ្ញុំបានឃើញ នោះគឺអ្នកជំងឺដែលធ្ងន់ៗនោះ ឃើញគាត់ព្យាបាលបានជា ដោយសារគាត់ចេះថ្នមមើលអ្នកជំងឺ ហើយនិងថ្នាំសង្កូវគាត់ចេះដាក់ ឲ្យលេប ឲ្យផឹក។

[១៥:២៣:៤៧]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណច្រើនលោកសាក្សី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយបាទ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក

ខៀវ សំផន។ ខ្ញុំមានសំណួរមួយចំនួន សួរទៅកាន់លោក ហើយសហភាតារបស់ខ្ញុំ លោក គង់ សំអុន ក៏មានសំណួរដែរ។ ជាបឋមខ្ញុំសូមត្រឡប់មកនិយាយពីចំណុចមួយ ដែលលោកបានពិភាក្សាជាមួយលោក ចៅក្រម ឡាវ៉ែន៍ កាលនៅថ្ងៃនេះ នៅពេលដែលគាត់សួរសំណួរទៅលោក ហើយនិងកាលពីម្សិលនៅប្រហែលជាម៉ោងដប់បី សែសិបបីនាទី លោកបានឆ្លើយដែរ គឺនៅខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមចូលទៅដល់តំបន់លោក។ ហើយលោកបាននិយាយថា ប្រហែលជានៅក្រោយម៉ោងដប់បីសែសិបបីនាទីបន្តិច សវនាការពីម្សិលមិញនេះ គឺលោកបាននិយាយថា៖ “នៅពាក់កណ្ដាលឆ្នាំ១៩៧៥ ពួកគេបានបែងចែកពួក១៧មេសាហ្នឹង ហើយបញ្ជូនទៅស្រុកផ្សេងៗ”។ ហើយព្រឹកមិញនេះ ពេលដែលឆ្លើយទៅចៅក្រម ឡាវ៉ែន៍ លោកបានឆ្លើយថា៖ “អ្នកដែលគេចាត់ទុកថាជាអ្នក១៧មេសានោះ មិនត្រូវបានបញ្ចូលទៅក្នុងកងទ័ពស្រុកទេ ក៏ប៉ុន្តែអាច -- ក្នុងថ្នាក់តំបន់ទេ ក៏ប៉ុន្តែអាចបញ្ចូលទៅទ័ពស្រុកបាន”។ តើខ្ញុំធ្វើសង្ខេបទាំងអម្បាលម៉ាននេះ ជាការត្រឹមត្រូវដែរឬទេ ឬក៏ខ្ញុំយល់លោកខុស?

[១៥:២៥:៤៨]

**លោក ឡុត ស្វយ៖**

**ឆ៖** ខ្ញុំសូមឲ្យលោកមេធាវីសួរខ្ញុំម្តងទៀត ស្តាប់អត់បានច្បាស់។

**ស៖** ខ្ញុំចាប់ផ្តើមម្តងទៀត ហើយនិងនិយាយខ្លីៗជាងហ្នឹង។ សំណួរទី១របស់ខ្ញុំគឺថា នៅក្នុងឆ្នាំ១៩៧៥ តើពួក១៧មេសាត្រូវបានគេបញ្ចូលឲ្យធ្វើកងទ័ពដែរឬទេ?

**ឆ៖** បាទ ១៧មេសា ថ្ងៃ១៧មេសានេះ ដែលបានចូលទៅក្នុងកងទ័ពនោះគឺគេបញ្ចូល បានគេរើសបញ្ចូលធ្វើជាកងទ័ពតំបន់។ ពេលនោះ គេអត់បានស្រាវជ្រាវពីរឿងប្រវត្តិថា យើងអ្នកចេះអ្នកល្ងង់ទេ។ ដល់ពេលរយៈកាលក្រោយមកនេះ បានគេបែងចែក ការកងទ័ពតំបន់នេះ គឺគេចម្រាញ់យកតែអ្នកចាស់ ហើយអ្នកថ្មីគេក៏ចែករំលែកមកតាមស្រុក ព្រះនេត្រព្រះ និងស្រុកភ្នំស្រុក។ ពេលនោះ ស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះ អ្នកណាដែលគេដឹងប្រវត្តិយើងអ្នកចេះដឹងចេះអក្សរ គេក៏ដកចេញពីកងទ័ព ឲ្យមកនៅតាមសហករណ៍វិញខ្លះ។

**ស៖** តើលោកត្រូវបានគេចាត់ទុកថា ជាអ្នក១៧មេសា ឬក៏ប្រជាជនចាស់?

**ឆ៖** ១៧មេសានេះ គឺជាប្រជាជនថ្មីដែលគេរំដោះយើងបានទូទាំងប្រទេសនេះ គឺគេហៅយើងដែលនៅតំបន់ជាមួយទាហាន លន់ នល់ នេះ គេហៅយើងប្រជាជនថ្មី។ បានគេហៅយើង ១៧មេសា។ គេនៅដីខាងរំដោះនោះ គេហៅប្រជាជនចាស់។

[១៥:២៨:២៣]

**ស៖** អ៊ីចឹងសំណួរខ្ញុំហ្នឹងគឺខ្ញុំចង់ដឹងថា អង្គាល់នោះលោកនៅក្នុងប្រភេទប្រជាជនអី? ប្រជាជនចាស់ ឬក៏ប្រជាជនថ្មី?

**ឆ៖** ខ្ញុំពេលនោះ ខ្ញុំនៅជាប្រភេទប្រជាជនថ្មី។

**ស៖** អ៊ីចឹង ជាការត្រឹមត្រូវដែរឬទេ គឺថាលោកត្រូវបានគេតែងតាំង ឬក៏បញ្ចូលទៅក្នុងកងទ័ពស្រុក? អ៊ីចឹងជាការត្រឹមត្រូវដែរឬទេ គឺថាពេលណាមួយនោះ គេយកលោកធ្វើជាទ័ពស្រុក?

**ឆ៖** ពេលដែលបែងចែកនៅកន្លែងស្វាយនេះ ក៏គេបែងចែកកម្លាំងគ្នាទៅ ចែកទៅខាងស្រុក។ ដល់គេរាប់ទៅ បានពួកខ្ញុំបែងចែកទៅខាងភ្នំស្រុក។ ដកពីកងតំបន់មកនៅជាមួយពួកកងស្រុក ឈ្មោះពួក តាណាក។

**ស៖** ខ្ញុំសូមអរគុណដែលបានឆ្លើយបញ្ជាក់នេះ។ ឥឡូវខ្ញុំសូមផ្តោតសំខាន់ទៅលើពេលដែលលោកធ្វើការជាអ្នកយាមនៅលើទំនប់ត្រពាំងថ្ម។ លោកបានឆ្លើយតបទៅនឹងសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា លោកមានអាវុធកាន់នៅលើទំនប់នោះ។ ក៏ប៉ុន្តែខ្ញុំដូចជាយល់ថា កាលណោះលោកមិនដឹងថាប្រើកាំភ្លើងហ្នឹងយ៉ាងម៉េចទេ។ អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ តើលោកមិនដែល -- គេមិនដែលបង្រៀនលោកថា ត្រូវប្រើកាំភ្លើងហ្នឹងយ៉ាងម៉េចទេឬ ពេលដែលគេប្រគល់កាំភ្លើងឲ្យលោកកាន់នោះ?

**ឆ៖** ពេលដែលគេ -- ពេលនោះគេអត់ដែលបង្រៀនយើងថាបាញ់ក្រាបយ៉ាងណាទេ។ គ្រាន់តែគេហុចកាំភ្លើងមកយើង ក៏ស្ពាយទៅ។ ការដែលយើងចេះដឹង គឺចេះដឹងអំពីគ្នាយើង សួរគ្នាយើងទៅបើកសោអានេះ បាញ់អានោះ។ ពួកវាអត់ៗដែលមានសាលារៀន និងសាលាហាត់គុនអីទេ។

[១៥:៣១:១៣]

**ស៖** តើលោកមិនដែលធ្លាប់ប្រើកាំភ្លើងហ្នឹងទេឬ?

**ឆ៖** ខ្ញុំចាប់ផ្តើម ខ្ញុំអត់ដែលបានប្រើ បានស្គាល់ទេ ព្រោះខ្ញុំនៅតែរៀន។ ពេលដែលដាច់ខាតនោះឯង បានៗស្គាល់កាំភ្លើងនឹងគេ។

**ស៖** លោកបានឆ្លើយថា លោកនៅក្នុងកងមួយដែលគេឲ្យទៅធ្វើការនៅត្រពាំងថ្ម តើនៅក្នុងកងហ្នឹងៗអង្គភាពហ្នឹងលោកមានតួនាទីអ្វីជាក់លាក់ដែរឬទេ ឬក៏លោកគ្រាន់តែជាអ្នកយាមម្នាក់តែប៉ុណ្ណោះ?

**ឆ៖** ខ្ញុំបាទជាអ្នក -- គេថាយុទ្ធជននៅក្នុងក្រុម អត់មានតួនាទីជាស្អីទេ។ ព្រោះយាមនុ៎ង ក៏មិន

មែនយាមតែខ្ញុំដែរ គេចាត់តាំងក្រុមនេះក្រុមនោះទៅយាម ក៏ទៅទាំងខ្ញុំទៅ។ បើប៉ះក្រុមខ្ញុំក៏ខ្ញុំទៅ ប៉ះក្រុមគេក៏គេទៅ។

**ស៖** តើលោកមានអំណាចលើប្រធានកងចល័តហ្នឹងទេ នៅពេលដែលលោកយាមលើទំនប់នុ៎ង?

**ឆ៖** ពេលនោះ ដែលខ្ញុំយាមលើទំនប់នោះ គឺខ្ញុំមានការងារភារកិច្ចដាច់ពីគ្នា គឺភារកិច្ចខ្ញុំ គឺក្នុងក្រុមរបស់ខ្ញុំ គឺមានមុខសញ្ញាមួយតែការពារទំនប់កុំឲ្យបាក់។ ហើយផ្នែកកងចល័ត គឺគេប្រធានចល័តគឺគេការពារកូនចៅគេ ដើម្បីលើកទំនប់នោះឲ្យស្អាត ឲ្យរួច។ គឺមិនដែលបានទំនាក់ទំនងគ្នាទេ។

[១៥:៣៤:០៣]

**ស៖** នៅពេលដែលលោកនិយាយថា លោកមិនមានទំនាក់ទំនងជាមួយប្រធានកងហ្នឹង អ៊ីចឹងលោកចង់និយាយថា លោកមិនធ្លាប់និយាយជាមួយពួកគាត់ទេឬ ក្នុងការងាររបស់លោកជាអ្នកយាមហ្នឹង?

**ឆ៖** បាទ ព្រោះការងារខ្ញុំអ្នកយាមនេះ គឺអត់មានពេលទៅអង្គុយលេង និយាយជាមួយគេទេ ខ្លាចខាតការងាររបស់គេ ព្រោះការងាររបស់គេ គេកំពុងជំរុញរែកដីឲ្យជឿនលឿន។

**ស៖** តើនៅក្នុងលក្ខខណ្ឌហ្នឹងជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា នៅពេលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្មហ្នឹង លោកមិនដែលធ្លាប់ធ្វើការជាមួយកងចល័តនោះទេ ដើម្បីរែកដីនោះ? តើខ្ញុំនិយាយអ៊ីចឹងជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំស្ដាប់អត់បានផង។

**ស៖** ខ្ញុំចោទសំណួរហ្នឹងម្ដងទៀត អត់បញ្ហាអីទេ។ នៅពេលដែលលោកធ្វើជាអ្នកយាមនៅត្រពាំងថ្មនោះ លោកមិនដែលជួយកងចល័តទេ ក្នុងការរែកដីហ្នឹង តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។ ខ្ញុំមិនដែលបានចុះទៅជួយរែកដីរែកអីគេទេ។

**ស៖** តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា លោកហូបចុកនៅកងរបស់លោក។ ខ្ញុំមិនដឹងថាលោកហៅក្រុមលោកនោះយ៉ាងម៉េចទេ ថាជាកងវរសេនាតូច ថាលោកហូបចុកជាមួយទាហានគ្នាលោកទេ ហើយលោកមិនមែនហូបចុកជាមួយអ្នកធ្វើការក្នុងកងចល័តនៅ ដែលរែកដីនៅទំនប់ត្រពាំងថ្មនុ៎ងទេ។ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំស្ដាប់អត់ទាន់ទេ។ សូមឲ្យនិយាយម្ដងទៀត។

**ស៖** ពេលដែលលោកហូបចុកនោះ លោកហូបចុកជាមួយតែទាហានគ្នាលោកតែប៉ុណ្ណោះទេ ឬក៏ពេលខ្លះនោះដែលធ្លាប់ដែរ គឺលោកធ្លាប់ហូបចុកជាមួយនឹងអ្នកធ្វើការនៅក្នុងកងចល័តដែលរែកដីនុំងដែរ?

**ឆ៖** ពេលដែលការហូបចុកនោះ ខ្ញុំអត់ដែលបានហូបចុកជាមួយក្នុងកងចល័តទេ។ ហូបចុកតែជាមួយគ្នាខ្ញុំឯលើទំនប់ឯណោះ។

[១៥:៣៧:៣១]

**ស៖** លោកសាក្សី ខ្ញុំចោទសំណួរទាំងអស់នេះ ព្រោះថាមានសំណួរមួយចំនួន ដែលគេសួរលោកទាក់ទងទៅនឹងលក្ខខណ្ឌការងារ ហើយនិងរបបហូបចុក ហើយលោកបានឆ្លើយមួយចំនួន -- ផ្តល់ចម្លើយមួយចំនួន។ ហើយខ្ញុំចង់អានចម្លើយមួយចំនួន ដើម្បីឲ្យលោកស្តាប់ គឺចម្លើយរបស់សាក្សីមុន ដែលគាត់និយាយថា គាត់បានធ្វើការជាប្រធានក្រុមកងចល័តមួយ ដែលគាត់បាននិយាយខុសពីលោកបន្តិចទាក់ទងនឹងរបបអាហារហូបចុកនេះ។ អ៊ីចឹង ខ្ញុំចង់ឲ្យលោកផ្តល់សេចក្តីអត្ថាធិប្បាយទាក់ទងទៅនឹងចម្លើយរបស់គាត់ គឺសាក្សី កាន ថុល ដែលនៅសវនាការថ្ងៃទី១០ សីហា ឆ្នាំ២០១៥ នេះមុនម៉ោងដប់ប្រាំ សាមសិបប្រាំមួយនាទីបន្តិច គាត់បានឆ្លើយថា ពេលនោះគាត់និយាយអំពីរបបអាហារនៅទំនប់ហ្នឹង។ គាត់និយាយដូចតទៅនេះ៖ “ពីដំបូងម្នាក់ៗទទួលរបបអាហារបីដងក្នុងមួយថ្ងៃ គឺបីកំប៉ុងក្នុងមួយថ្ងៃ អង្ករបីកំប៉ុងក្នុងមួយថ្ងៃ”។ ហើយក្រោយមកបន្តិច គាត់បានឆ្លើយទៀតថា៖ “ពេលក្រោយមកគេបានកាត់បន្ថយរបបអាហារ គឺទទួលបានតែពីរកំប៉ុងក្នុងមួយថ្ងៃទេ ហើយជួនកាលខ្វះជាងហ្នឹង តិចជាងហ្នឹងទៀត គឺមកដល់ត្រឹមតែមួយកំប៉ុងកន្លះទៀងផង”។ អ៊ីចឹងនៅពេលដែលលោកនេះនៅពេលដែលគេសួរសំណួរលោកទាក់ទងនឹងរបបអាហារ ដែលគេផ្តល់ឲ្យអ្នកធ្វើការនៅលើការដ្ឋានហ្នឹង ខ្ញុំដូចជាយល់បានថា លោកបាននិយាយថា ត្រឹមតែមួយកំប៉ុង អង្ករមួយកំប៉ុងក្នុងមួយថ្ងៃនោះទេ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកហូបចុកជាមួយទាហានគ្នាលោកតែប៉ុននុំងទេ ឬក៏ថា ជាការត្រឹមត្រូវក្នុងការនិយាយថា លោកមិនដឹងថា របបអាហារគេនោះមានប៉ុនណានោះទេ បរិមាណប៉ុន្មានអីប៉ុន្មានលោកមិនដឹងទេ?

**ឆ៖** ពីព្រោះខ្ញុំដែលនៅលើទំនប់នេះ គេឲ្យហូបតែក្នុងមួយថ្ងៃមួយកំប៉ុង។ ដល់ពួកកងចល័តនេះ ដែលការសេដ្ឋកិច្ចចុះទន់ខ្សោយ បាននៅមួយកំប៉ុង ឬកន្លះកំប៉ុង។ ជួនពេលថ្ងៃណាដាច់ គ្មានការបើកទេ អត់មានអង្ករបើកបានឲ្យទេ។

[១៥:៤០:២១]

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេហ្នឹងថា ប្រហែលលោកនិយាយពីបទពិសោធន៍របស់លោកក្នុងឋានៈជាទាហាននៅកងវរសេនាតូចហ្នឹង ដែលបានឈរជើងនៅ -- អនុសេនាតូចដែលបានឈរជើងនៅទំនប់ត្រពាំងថ្ម លោកមិនបាននិយាយពីបទពិសោធន៍អ្នកផ្សេងទៀតទេ អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំអត់បាននិយាយពីរឿងគេអ្នកផ្សេងទេ ប៉ុន្តែរឿងតែការងារដែលនៅលើខ្នងទំនប់ គឺមានពួកខ្ញុំយាមទឹក ហើយនិងកងចល័ត អាហ្នឹងខ្ញុំការដឹងមិនដល់។ ទើបនឹងខ្ញុំដឹងចុងក្រោយ ពួកចល័តគេនិយាយថា ថ្ងៃនេះអត់បានបើកអង្ករទេ ដាច់អង្ករ អង្ករដឹកមកមិនទាន់ មានតែបបរ។ អានេះខ្ញុំឮតាមពួកចល័តគេនិយាយ។

**ស៖** តើនៅពេលណាមួយ ក្នុងរយៈពេលដែលលោកមានវត្តមាននៅទំនប់ហ្នឹង គឺលោកបានកាន់តំណែងជាប្រធានកងមួយ គឺថាកងយោធារបស់លោកហ្នឹង។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំស្តាប់អត់បានផង។ សូមឲ្យនិយាយឲ្យដាច់ៗពីគ្នា។

**ស៖** ខ្ញុំសួរលោកម្តងទៀត តើនៅពេលណាមួយនោះ គឺថាលោកបានក្លាយជាប្រធានកងមួយ អាចថាជាកងទ័ព ឬក៏កងចល័ត កងអីផ្សេងទៀតនៅការដ្ឋានទំនប់ត្រពាំងថ្មហ្នឹង? លោកមានធ្លាប់ចូលកាន់តំណែងជាប្រធានទេ?

**ឆ៖** មួយរយៈកាលកន្លងមក ខ្ញុំអត់ដែលបានឡើងជាប្រធាននឹងគេទេ។ មានតែការធ្លាក់ទេ មានតែគេដកចេញពីយោធាទៅនៅតាមចល័ត។

[១៥:៤៣:០៣]

**ស៖** ខ្ញុំចោទសំណួរនេះទៅលោកនោះ គឺថាយើងមានសាក្សីម្នាក់ដែលមកផ្តល់សក្ខីកម្មនៅទីនេះថ្ងៃមុខដែលគាត់មានបទពិសោធន៍ខុសពីលោក គឺសាក្សី 2-TCW-937 នៅក្នុងឯកសារ E3/9008។ ERN ជាភាសាបារាំងគឺ 01123741 ហើយជាភាសាខ្មែរគឺ 00728838, ERN ជាភាសាអង់គ្លេសគឺ 00731149។

**កញ្ញា អង់តា ហ្គីសសេះ**

មុននឹងអានសម្រង់នេះទៅកាន់លោកសាក្សី ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ពីព្រោះថា ខ្ញុំមិនអាចផ្តល់ឈ្មោះសាក្សីនេះ ដែលគាត់មិនទាន់បានមកផ្តល់សក្ខីកម្មនៅទីនេះទេ។ អ៊ីចឹងខ្ញុំផ្តល់ទំព័រទី១ ទៅគាត់ដើម្បីឲ្យគាត់ដឹង ថាតើសាក្សីហ្នឹងមានឈ្មោះអ្វីដែរ ហើយឲ្យគាត់អានឈ្មោះសាក្សីហ្នឹង។ សុំការ

អនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីរដ្ឋបាលយកឯកសារនេះជូនសាក្សី!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី មុននឹងចោទសំណួរទៅកាន់លោកជាបន្តបន្ទាប់ ខ្ញុំសូមបញ្ជាក់ប្រាប់លោកថា លោកមិនអាចអានឈ្មោះលោកសាក្សីហ្នឹងបានទេ។ ខ្ញុំគូសពណ៌លឿងពីលើហើយ អ៊ីចឹងសូមកុំឲ្យអានប្រាប់ឈ្មោះនេះឲ្យសាធារណជនដឹង។ ខ្ញុំគ្រាន់តែឲ្យលោកស្គាល់ឈ្មោះសាក្សីហ្នឹងទេ។ ឥឡូវបើសិនជាលោកស្គាល់ឈ្មោះគាត់ហើយហ្នឹង ខ្ញុំសូមអានសម្រង់មួយដែលគាត់ឆ្លើយនៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា។ សំណួរដែលគេចោទសួរគាត់ហ្នឹង គឺខ្ញុំបានផ្តល់លេខ ERN ហើយៗអម្បាញ់មិញ។ “សំណួរ៖ តើលោកស្គាល់ ជុំ សេង ហើយនិង ឡុត សួយ ដែរឬទេ?” ចម្លើយរបស់សាក្សីនុំង គាត់ឆ្លើយថា៖ “ខ្ញុំស្គាល់ សួយ ក៏ប៉ុន្តែខ្ញុំសឹងតែភ្លេចគាត់ទៅហើយ។ តើ សួយ ហ្នឹងធ្វើអីដែរ? ចម្លើយ៖ គាត់ហ្នឹងប្រធានកងតូចមួយ។” សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងសំណួររបស់ខ្ញុំ ខ្ញុំចង់ដឹងថា តើលោកធ្លាប់ជាប្រធានកងតូចមួយដែរឬទេ? សូមឲ្យឆ្លើយថា បើថាធ្លាប់ធ្វើ ឆ្លើយថា “ធ្លាប់ធ្វើ” បើមិនធ្លាប់ធ្វើទេ ឆ្លើយថា “អត់” ទៅបានហើយ។

[១៥:៤៦:០៦]

**ឆ៖** ខ្ញុំផ្សាយឈ្មោះកណ្តាលមុខតុលាការ ខ្ញុំអត់ដែលបានជាប់ឈ្មោះកងតូច ឬជាប្រធានអីមួយទេ។ បើខ្ញុំនិយាយមិនត្រង់ សូមឲ្យលោកព្រះនៅទឹកដីនេះ កាច់ខ្ញុំចុះ។ ខ្ញុំអត់មានតួនាទីអីនឹងគេទេ មានតួនាទីតែយុទ្ធជនតែមួយមុខ។

**ស៖** ខ្ញុំមិនសុំឲ្យលោកស្បថដល់ថ្នាក់ហ្នឹងទេ។ ដោយៗសារលោកឃើញឈ្មោះសាក្សីហ្នឹងហើយ តើលោកស្គាល់គាត់ទេ? ហើយសូមបញ្ជាក់ជូនលោកមួយសាទៀត សូមកុំឲ្យប្រាប់ឈ្មោះគាត់ដល់សាធារណជនដឹង កុំបង្ហើបឲ្យគេដឹង។ លោកសាក្សី គ្រាន់ជាសំណួរសាមញ្ញទេ អ៊ីចឹងបើលោកមិនដឹងថា បុគ្គលរូបហ្នឹងជាអ្នកណានោះទេនោះ លោកគ្រាន់តែឆ្លើយថា ខ្ញុំមិនដឹងទេ មិនស្គាល់គាត់ទេ។ អត់មាន សំណួរនេះអត់មានដាក់អន្ទាក់លោកអីទេ បើលោកមិនដឹង លោកថាមិនស្គាល់ ឬក៏មិនដឹងអីអ៊ីចឹងទៅ។

**ឆ៖** បាទ រូបៗនេះឈ្មោះនេះ ខ្ញុំអត់ដែលបានស្គាល់ផង។

**សៈ** លោកបានឆ្លើយថា នៅក្នុងការងាររបស់លោកនៅត្រពាំងថ្មហ្នឹង លោកមានមុខងារជាអ្នកផ្សៀងផ្ទាត់ថា កុំឲ្យមានទំនប់ហ្នឹងប្រេះធ្លាយ ហើយនិងរាយការណ៍ទៅថ្នាក់ដឹកនាំទំនប់នុំង ដើម្បីឲ្យមានក្រុមគេអ្នកជួសជួលហ្នឹងមកធ្វើ បើសិនករណីដែលមានប្រេះធ្លាយ។ អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ តើក្រៅពីការងាររាយការណ៍ទៅប្រធានការដ្ឋាននោះ លោកក៏ត្រូវធ្វើជូនដំណើរដល់ក្រុមការងារអ្នកដែលធ្វើការងារដែលការងារគេនោះ គឺមកជួសជុលកន្លែងដែលប្រេះ ឬក៏ធ្លាយហ្នឹង? លោកមានធ្វើអ៊ីចឹងដែរទេ គឺថារាយការណ៍ផង ហើយជូនដំណើរអ្នកមកជួសជុលផង?

[១៥:៤៩:០៦]

**ឆៈ** បាទ ដែលខ្ញុំរាយការណ៍ឲ្យថ្នាក់លើ ថ្នាក់លើក៏ឲ្យកម្លាំងមកនេះ មកជួសជុលនេះ ខ្ញុំក៏បានដឹកនាំកម្លាំងនោះ ទៅបង្ហាញនៅកន្លែងដែលបាក់ ដែលប្រេះ។ កងកម្លាំងគេចល័ត គេៗរែកដីបំពេញបន្ថែម។

**សៈ** អ៊ីចឹងខ្ញុំត្រូវយល់ថា បន្ទាប់មកទៀត លោកមិនបានជូនកងដែលជួសជុលទេ ឬក៏យ៉ាងម៉េច? ខ្ញុំត្រូវយល់ថាយ៉ាងម៉េច យល់ថា លោកមិនដែលនាំក្រុមដែលគេមកជួសជុលទំនប់ហ្នឹងទេ ឬក៏យ៉ាងណា?

**ឆៈ** គឺខ្ញុំ ពេលកងចល័តមក គឺខ្ញុំត្រូវជូនគេទៅកន្លែងដែលជួសជុលទំនប់នោះ ដែលទំនប់នោះវាប្រុងបាក់។

**សៈ** អ៊ីចឹងក្នុងមុខងាររបស់លោកហ្នឹង ជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា លោកធ្វើការជាច្រើនហ្នឹង គឺឈរជើងនៅកន្លែងអាងទឹកហ្នឹងតែម្តង។ អ៊ីចឹងមែនទេ?

**ឆៈ** បាទ គេបានដកពួកខ្ញុំមួយក្រុមឲ្យនៅឈរជើងយាមទឹកនោះ ជាមួយនឹងកងចល័តចំនួនប្រហែល១០០នាក់នេះ សម្រាប់ការពារទឹកអាង ខ្លាចទឹកជំនន់មកវាបាក់។

**សៈ** តើលោកមានចាំឈ្មោះដែលកន្លែងលោកឈរជើងដែរឬទេ នៅក្នុងក្របខ័ណ្ឌនៃការយាមកាមរបស់លោកនៅទីនោះហ្នឹង?

**ឆៈ** គឺខ្ញុំឈរជើងនៅនឹងស្ពានទី១ អែបភូមិត្រពាំងថ្ម។

[១៥:៥១:៥៥]

**សៈ** នៅក្នុងចម្លើយរបស់លោក ដែលលោកផ្តល់ជូនទៅមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង ខ្ញុំមិនដឹងថា លោកនិយាយពីស្ពានដូចគ្នាដែរឬទេ គឺថា ERN ជាភាសាបារាំងគឺថា ឯកសារ E3/906

ERN ជាភាសាបារាំងគឺ 01123683, ERN ជាភាសាខ្មែរ 00733027, ERN ជាភាសាអង់គ្លេសគឺ 00728728។ សំណួរដែលគេសួរទៅលោកដូចតទៅនេះ៖ “តើទាហានហ្នឹងយាមពេញមួយទំនប់ហ្នឹង តែម្តង ឬយ៉ាងម៉េច?” ចម្លើយលោកឆ្លើយថា៖ “ទេ គេឲ្យឈរជើងតែមួយកន្លែងទេ ហើយនៅស្ពានហ្នឹង នៅកន្លែងនោះ ហើយគេឈរជើងនៅកន្លែងនេះ។” ក្រោយមកទៀតលោកឆ្លើយថា៖ “នៅកន្លែងស្រី”។ សំណួរអ៊ីចឹងថា -- សំណួរគេសួរបន្តទៀតថា៖ “នៅពេលដែលយាមហ្នឹង យាមគ្រប់ទាំងអស់ហ្នឹង យ៉ាងម៉េច? បាទ ពេលវេនយើងហ្នឹង យើងដើររហូតទៅដល់កំបោរឯណោះ”។ អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ តើកំបោរហ្នឹងនៅឯណាដែរ បើធៀបទៅនឹងកន្លែងស្ពាន១រន្ទះបាញ់? លោកធ្លាប់ -- តើលោកដឹងទេ ថាប្រវែងចម្ងាយពីគ្នាប៉ុន្មានណាដែរ នៅពេលកាលដែលលោកធ្វើការជាអ្នកយាមនៅទីនុំង ពីកំបោរទៅស្ពានរន្ទះបាញ់ហ្នឹង?

**ឆ៖** បាទ ខ្ញុំអត់ដែលបានទៅយាមនៅកន្លែងកំបោរទេ។ ខ្ញុំយាមតែអាងត្រពាំងថ្មនេះ ទាល់ប្រជាជនធ្វើឡើងរួច ស្អាត បានខ្ញុំ បានមេគេដកខ្ញុំឲ្យមកនៅនឹងឈូកអាងវិញ។

**ស៖** ការបំភ្លឺទី១ ទាក់ទងនឹងចម្លើយរបស់លោកអំមិញ នៅពេលដែលលោកឆ្លើយនៅក្នុងចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថា៖ “ខ្ញុំដើររហូតទៅដល់កំបោរ”។ លោកចង់សំដៅទៅលើអ្វីដែរ ពេលលោកឆ្លើយអង្គាល់នោះថាដើរដល់កំបោរនេះ?

[១៥:៥៤:៣៧]

**ឆ៖** ដែលគេដែល១គ្នាខ្ញុំដើរដល់កំបោរនេះ គឺគាត់ប្រើខ្ញុំឲ្យទៅមើលទំនប់ចំនួនគ្នា១០នាក់។ បានពេលល្ងាចឡើងបានខ្ញុំដក បានខ្ញុំដើរមកត្រពាំងថ្មវិញ។ ពេលនោះគឺបោះជំរំរបស់ តាវ៉ាល់ គាត់នៅជំរំនៅអាងរន្ទះបាញ់យើងនេះ ចាប់ពីស្រុកស្រេះ ទៅទល់នឹងភ្នំកំបោរ ទើបនឹងចាប់ផ្តើមលើក។

**ស៖** អ៊ីចឹង តើខ្ញុំត្រូវយល់ថា នៅក្នុងការយាមកាមរបស់លោកហ្នឹងការដើរទៅដល់កំបោរនេះ គឺថាជាករណីលើកលែងទេ ហើយជាទូទៅនោះ លោកនៅតែឈរជើងនៅតែក្បែរស្ពាននុំងទេ។ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ការបំភ្លឺមួយទៀត។ តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា នៅពេលដែលលោកឈប់ធ្វើការនៅទំនប់ត្រពាំងថ្មក្នុងឋានៈជាអ្នកយាមហើយនោះ គឺលោកថាក្រោយពេលដែលគេចាប់ប្រធានលោកហើយហ្នឹង គឺលោកត្រូវបានបញ្ជូលទៅក្នុងកងចល័តមួយ។ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរ

ឬទេ? ចេញពីអ្នកយាម ហើយក្រោយមកគេចាប់មេលោក ហើយក្រោយមកទៀត លោកត្រូវបានគេបញ្ជូលទៅក្នុងកងចល័តតាមក្នុងភូមិ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** តើលោកអាចបញ្ជាក់បានទេថា តើលោកធ្វើការនៅក្នុងកងចល័តភូមិហ្នឹង គឺនៅទីតាំងជាក់លាក់ណាដែរ? លោកអាចបញ្ជាក់ជូនតុលាការបានទេ?

**ឆ៖** ខ្ញុំនៅទីតាំងនៅក្នុងភូមិពោធិ៍វាំបុណ្យយើង គេហៅត្រពាំងអម្ពិល អែមភូមិពោធិ៍វាំបុណ្យជាស្រុករបស់ ជាស្រុក – ជាភូមិរបស់ប្រពន្ធខ្ញុំ ចល័តភូមិ។

[១៥:៥៧:១៥]

**ស៖** តើភូមិហ្នឹងនៅចម្ងាយប៉ុន្មានដែរពីទំនប់ត្រពាំងថ្មហ្នឹង?

**ឆ៖** ចម្ងាយពីទំនប់ត្រពាំងថ្មចំនួនប្រហែល៥គីឡូ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណដែលបានឆ្លើយបញ្ជាក់ទាំងអស់នេះ។ លោកប្រធាន ខ្ញុំឥឡូវសួរចប់ប្រធានបទទី១ ហើយខ្ញុំគិតថា ប្រហែលជាដល់ម៉ោងត្រូវសម្រាកហើយក្នុងពេលនេះ ឬក៏លោកប្រធានសម្រេចធ្វើយ៉ាងណាបន្តទៀត?

**ប្រធានអង្គជំនុំ៖**

លោក! គាត់នៅបន្តទៀត? លោក គង់ សំអុន មានសំណួរបន្តទៀត។

សូមអរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសមស្របនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកទៅបន្តធ្វើនៅថ្ងៃព្រហស្បតិ៍ ទី១៣ ខែសីហា ឆ្នាំ២០១៥ ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ឡូត សួយ បញ្ចប់ ហើយនិងផ្តើមស្តាប់សក្ខីកម្មដែលមានរហស្សនាម 2-TCW-937 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

[១៥:៥៨:៤៣]

អង្គជំនុំជម្រះអរគុណលោក ឡូត សួយ ដំណើរការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃព្រហស្បតិ៍

ទី១៣ ខែសីហា ឆ្នាំ២០១៥ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោក ឡុត សួយ វិលត្រឡប់ទៅកាន់កន្លែងគាត់ស្នាក់នៅវិញចុះ និងសូមអញ្ជើញគាត់ និងមេធាវីប្រឹក្សាត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនានេះវិញ នៅថ្ងៃព្រហស្បតិ៍ ទី១៣ ខែសីហា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃព្រហស្បតិ៍ ទី១៣ ខែសីហា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញសម្រាក៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥៩ នាទី)*